# សូមគោរពជូនពរបវរសួស្តីមហាប្រសើរ
# ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាបុណ្យរំដោះ
# អនុស្សាវរីយ៍លើកទី ៣៥ ទិវាជ័យជម្នះ ៧ មករា

( ៧.១.១៩៧៩ ~ ៧.១.២០១៤ )



**សម្តេចអគ្គមហាពញាចក្រី**

**ហេង សំរិន**

ប្រធានរដ្ឋសភា

ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា



**សម្តេចអគ្គមហាធម្មពោធិសាល**

**ជា ស៊ីម**

ប្រធានព្រឹទ្ធសភា

ប្រធានគណបក្សប្រជាជនកម្ពុជា



**សម្តេចអគ្គមហាសេនាបតីតេជោ**

**ហ៊ុន សែន**

នាយករដ្ឋមន្ត្រី

អនុប្រធានគណបក្សប្រជាជនកម្ពុជា

យើងខ្ញុំសូមសម្តែងគារវភក្តី និងកតញ្ញុតាធមិដ៏ជ្រាលជ្រៅបំផុតជូន **សម្តេចទាំងបី** អគ្គមគ្គុទ្ទេសក៏នៃប្រជាជនកម្ពុជា ដែលបានពុះពារលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាញាណ ក្នុងការបម្រើប្រជាជាតិខ្មែរ ដើម្បីឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សន្តិភាព សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម ។

សូមគោរពជូនពរ **សម្តេចទាំងបី** សូមបានប្រកបដោយសុខភាពបរិបូរ កាយពលមាំមួន បញ្ញា-ញាណភ្លឺថ្លា ជន្មាយុយឺនយូរ ដើម្បីដឹកនាំមាតុភូមិកម្ពុជា និងគណបក្សប្រជាជនកម្ពុជា ឱ្យសម្រេចបាន ជោគជ័យកាន់តែធំធេងឡើងថែមទៀត ។

**គោរពជូនដោយក្ដីកតញ្ញុតាធមិ៍ដ៏ជ្រាលជ្រៅ**

**ទស្សនាវដ្តីប្រជាជន**

# សិរីសួស្តីឆ្នាំថ្មី

## ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ២០១៤



យើងខ្ញុំសូមគោរពជូនពរបវរសួស្តី សិរីមង្គល មហាប្រសើរជូនសម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា មន្ត្រីរាជការកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងនគរបាលជាតិ និងប្រជាជនកម្ពុជានៅគ្រប់ទិសទី ព្រមទាំងអង្គទូតនិងអង្គការអន្តរជាតិនានា ដែលកំពុងបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមនៅព្រះរាជាណាចក្រកម្ពុជា សូមទទួលបាននូវជោគជ័យថ្មីៗថែមទៀត នៅក្នុងភារកិច្ច និងបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**គោរពជូនពី**

**ទស្សនាវដ្តីប្រជាជន**

# *Happy New Year*

## On the occasion of the Universal New Year 2014

*the Pracheachun Magazine would like to express its sincere best wishes to Samdechs, Your Royal Highnesses, Excellencies, Lok Chumteav, Lok Oknha, Government Officials, Royal Armed Forces, Military Police, National Police, Compatriots, Diplomatic Mission and International Organizations in the Kingdom of Cambodia good health, wealth, happiness, prosperity and every success.*

*from the Pracheachun magazine*

# និពន្ធនាយក EDITORIAL

# ពូនជ្រំស្មារតី៧មករា បន្តអនុវត្តកំណែទម្រង់ដោយដាច់ខាត

## Further Growing 7 January Spirit, Resolutely Implementing Reforms

ទិវាជ័យជម្នះ ៧ មករា ឆ្នាំ ១៩៧៩ ត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា ថាជាថ្ងៃដែលប្រជាជនកម្ពុជាត្រូវបានសង្គ្រោះឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ប៉ុល ពត ដ៏យង់ឃ្នងបំផុត ហើយចាប់ផ្តើមពីពេលនោះ មាតុភូមិកម្ពុជាត្រូវបានស្តារ និងកសាងឡើងវិញពីលេខសូន្យរហូតឈានមកដល់ដំណាក់កាលអភិវឌ្ឍន៍ដូចសព្វថ្ងៃនេះ ។ ឆ្ពោះទៅថ្ងៃ៧ខែមករា ឆ្នាំ២០១៤ ខាងមុខនេះ ប្រជាជនកម្ពុជាទូទាំងប្រទេសកំពុងចូលរួមអបអរសាទរយ៉ាងក្លៀវក្លាខួបអនុស្សាវរីយ៍លើកទី ៣៥ នៃទិវាជ័យជម្នះ ៧ មករា ស្របពេលដែលស្ថានការណ៍ទូទៅនៃព្រះរាជាណាចក្រកម្ពុជាកំពុងបន្តវិវត្តជាវិជ្ជមានដែលអនុគ្រោះដល់ដំណើរការពង្រឹងសន្តិភាព ស្ថិរភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ បានប្រព្រឹត្តទៅដោយជោគជ័យ ។ លើមូលដ្ឋានលទ្ធផលនៃការបោះឆ្នោតរដ្ឋសភានីតិកាលទី៥និងរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ត្រូវបានបង្កើតឡើងស្របតាមរដ្ឋធម្មនុញ្ញហើយកំពុងបំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវចំពោះប្រជាជនជាម្ចាស់ឆ្នោត ទោះបីជាគណបក្សប្រឆាំងបន្តធ្វើពហិការកិច្ចប្រជុំសភា ហើយជំរុញរាល់សកម្មភាពប្រឆាំងដោយមិនគោរពច្បាប់យ៉ាងណាក្តី ។

នៅពេលដែលយើងកំពុងតែមើលឃើញផ្ទាល់នឹងភ្នែកនូវការអភិវឌ្ឍយ៉ាងធំធេងរបស់មាតុភូមិយើងនាពេលនេះ ហើយសម្លឹងទៅក្រោយ ដើម្បីរំឭកឡើងវិញនូវអ្វីដែលយើងបានឃើញ និងបានដឹងក្នុងអំឡុងពេលចាប់ពីខែមករា ឆ្នាំ ១៩៧៩ មកដល់ពេលនេះ យើងពិតជាមានមោទនភាពណាស់ចំពោះសមិទ្ធផលនៃការប្រឹងប្រែងក្នុងការស្តារ និងកសាងប្រទេសរបស់យើងដែលត្រូវ រលាយខ្ទេចខ្ទីគ្មានសល់អ្វី ទៅជាទឹកដីមួយដែលមានការរីកចម្រើន និងស្រស់បំព្រងនេះ ។ ប្រជាជនកម្ពុជាម្នាក់ៗ ជាពិសេសយុវជនជំនាន់នេះប្រាកដជាបានយល់ដឹង និងចងចាំនូវប្រវត្តិសាស្ត្រកម្ពុជារយៈពេល ៣៥ ឆ្នាំចុងក្រោយនេះ តាមរយៈការធ្លាប់បានឆ្លងកាត់ការស្តាប់ពាក្យដំណាលប្រាប់របស់ចាស់ទុំ ឬ បានសិក្សានៅក្នុងសាលារៀន ។ កម្ពុជាបានធ្លាក់ទៅក្នុងជ្រោះនៃមហាវិនាសកម្ម ដែលបង្កដោយសង្គ្រាមដ៏រ៉ាំរ៉ៃ និងការសម្លាប់រង្គាល និងកម្ទេចអ្វីៗគ្រប់យ៉ាងក្នុងរបបប្រល័យពូជសាសន៍ ការបែកបាក់ជាតិដ៏ធ្ងន់ធ្ងរដោយសារតែ មហិច្ឆតាលោភអំណាចរបស់អ្នកនយោបាយ និងការជ្រៀតជ្រែកពីសំណាក់មជ្ឈដ្ឋានខាងក្រៅមួយចំនួន ។ ផលវិបាកនៃសង្គ្រាមនិងរបបប្រល័យពូជសាសន៍មិនត្រឹមតែធ្វើឱ្យទឹកដីត្រូវបំផ្លាញខ្ទេចខ្ទីរប៉ុណ្ណោះទេ តែបានធ្វើឱ្យប្រជាជនយើងដែលនៅសេសសល់ពីការ

The Cambodian history has inscribed the victory on 7 January 1979 as the day that the Cambodian people are rescued from the regime of the Pol Pot's genocide. The Cambodian motherland was then restored and reconstructed from scratch and makes its way to the current stage of development. Longing for 7 January 2014, the Cambodian people in the whole country are celebrating energetically the 35th anniversary of the 7 January victory while the Kingdom of Cambodia continues to evolve positively in favor of the process of strengthening of peace, stability, democracy and socio-economic development after the successful organization of the fifth legislative term of the National Assembly's elections. Based on the results of the elections, the Royal Government for the fifth legislative term of the National Assembly, formed in conformity with the Constitution, has been fulfilling responsibly its tasks for the voters, though the opposition party boycotts the National Assembly session and abides by no law in furthering their opposition activities.

While seeing with our own eyes the developments of the motherland at the present time and recalling what we had seen and known since 7 January 1979 up to the present, we are so proud for achievements scored in the efforts to restore and construct our country from complete ruins to a land of fresh progresses. Every Cambodian, especially those belonged to the younger generation, certainly know and remember about the Cambodian history in the last 35 years, either by going through it or by listening to recollection by elder generation or learning in school. Cambodia fell into the abyss of great destruction caused by protracted war, systematic killing, complete destruction under the regime of the genocide, and, furthermore, severe national division because of ambition for power of politicians and interference from certain external circles.

Consequences of war and genocidal regime not only destroyed our country but also took away from the remaining people confidences in themselves. Over the past 35 years, under the leadership of the Cambodian People's Party, our people have put the most difficult phase behind and stepped into the phase of development in all fields in peace, stability, national unity and democracy. We have healed the wound deep in the hearts of our people, while rebuilding the strand of solidarity and national unity under the Constitution and the cool shade of our revered HM the King. Every Cambodian has a share in this victory and therefore benefits from it.

On the contrary, opposition politicians and ill-willed circles who have nurtured ambition to seek every means to take power have not been happy with these achievements. They always deny the historic meaning of 7 January victory and achievements scored in the course of building and defending the motherland under the leadership of the Cambodian People's Party. They make endless propaganda of deceiving history, especially among the youth circle, making them uncertain of the country's history, forgetting its bitter past and misunderstanding the leadership of the Cambodian People's Party – all of which would put the Cambodian future in a severe danger. Furthermore, their propaganda causes division among the youth, discriminates political color among them and instills spirit of extremist nationalism while waging anger with neighboring countries.

Immediately, after the elections, they further embolden their controversial acts in areas of politics, law, socio-economic and international relations, coupling with anarchic demonstrations aimed at building up pressure on the Cambodian People's Party to serve their political ambition. Actions of the

កាប់សម្លាប់ស្ទើរតែត្រូវបាត់បង់ជំនឿលើខ្លួនឯងថែមទៀត ។ ឆ្លងកាត់រយៈពេល ៣៥ ឆ្នាំមកនេះ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ប្រជាជនយើងបានឆ្លងផុតនូវដំណាក់កាលដ៏លំបាកបំផុត ឈានមកដល់ដំណាក់កាលមានការអភិវឌ្ឍលើគ្រប់វិស័យ ក្នុងសន្តិភាពស្ថិរភាព ឯកភាពភាជាតិ និងប្រជាធិបតេយ្យ ។ យើងបានផ្សារស្នាមរបួសស្នាមបែកបាក់នៅក្នុងជម្រៅបេះដូងនៃប្រជាជន កសាងបានមកវិញនូវផ្លូវសាមគ្គីភាព ឯកភាពជាតិ នៅក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ និងក្រោមម្លប់ដ៏ត្រជាក់នៃអង្គព្រះមហាក្សត្រជាទីសក្ការៈ ។ ប្រជាជនកម្ពុជាម្នាក់ៗសុទ្ធតែបានចូលរួមចំណែកនៅក្នុងជ័យជម្នះនេះ និងបានទទួលមនុញ្ញផលទាំងអស់នេះគ្រប់ៗគ្នា ។

ផ្ទុយទៅវិញក្រុមអ្នកនយោបាយប្រឆាំង និងមជ្ឈដ្ឋានអគតិខ្លះដែលចិញ្ចឹមទុកជានិច្ចនូវមហិច្ឆតាដណ្ដើមអំណាចតាមគ្រប់វិធីនោះ ពួកគេមិនបានរីករាយជាមួយនឹងសមិទ្ធផលទាំងអស់នេះឡើយ ។ ពួកគេតែងបដិសេធអត្ថន័យជាប្រវត្តិសាស្ត្រនៃជ័យជម្នះ ៧ មករា និងរាល់សមិទ្ធផលនៃបុព្វហេតុកសាង និងការពារមាតុភូមិ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ។ ពួកគេបានឃោសនាបំភ្លៃប្រវត្តិសាស្ត្រឥតឈប់ឈរ ជាពិសេសក្នុងមជ្ឈដ្ឋានយុវជនឱ្យស្រពេចស្រពិលចំពោះប្រវត្តិសាស្ត្ររបស់ជាតិខ្លួន បំភ្លេចអតីតកាលដ៏ឈឺចាប់ និងយល់ខុសលើការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ដែលនឹងបង្កជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរសម្រាប់អនាគតនៃកម្ពុជា ។ មិនតែប៉ុណ្ណោះ ពួកគេឃោសនាបំបែកបំបាក់ក្នុងចំណោមយុវជន បែងចែកពណ៌សម្បុរនយោបាយរវាងគ្នានិងគ្នា បំផុសសតិអារម្មណ៍ជាតិនិយមជ្រុល បង្កកំហឹងជាមួយប្រជាជាតិជិតខាង ។ ចំពោះមុខនេះក្រោយពេលបោះឆ្នោត ពួកគេកាន់តែជំរុញសកម្មភាពប្រទូសរ៉ាយយ៉ាងកឃ្លើនឡើង ទាំងលើទិដ្ឋភាពនយោបាយ ច្បាប់ សេដ្ឋកិច្ច សង្គម និងទំនាក់ទំនងអន្តរជាតិ ក្នុងនោះរួមមានការធ្វើបាតុកម្មតាមដងផ្លូវយ៉ាងអនាធិបតេយ្យ សំដៅបង្កសម្ពាធលើគ្រប់ផ្នែកមកលើគណបក្សប្រជាជនកម្ពុជា ដើម្បីបម្រើមហិច្ឆតានយោបាយរបស់ពួកគេ ។ សកម្មភាពរបស់គណបក្សប្រឆាំងកំពុងតែរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមានរបស់កម្ពុជា និងឆន្ទៈរបស់ប្រជាជនជាម្ចាស់ឆ្នោត ដែលមានគោលដៅផ្ដួលរំលំតាមរយៈការប្រើប្រាស់នូវអ្វីដែលគេបានហៅថាជា "អំណាចប្រជាជន" នោះ ។ ប៉ុន្តែពួកគេពិតជាគ្មានឱកាសណាអាចសម្រេចនូវមហិច្ឆតានេះបានឡើយ ។

រយៈពេល ៣៥ ឆ្នាំមកនេះ មន្ត្រីគណបក្សប្រជាជនកម្ពុជានៅគ្រប់ថ្នាក់ សុទ្ធតែបានដឹងច្បាស់ហើយថា អ្នកមានបំណងកម្ចាត់គណបក្សប្រជាជនកម្ពុជាពីនយោបាយមានចំនួនយ៉ាងច្រើន ទាំងនៅខាងក្នុងប្រទេស ទាំងនៅខាងក្រៅ ហើយតទៅមុខទៀតក៏គេនៅតែប៉ុនប៉ងផ្ដួលរំលំ មិនថាតាមវិធីណាឡើយ ។ នេះជាសារជាតិ និងជាគោលបំណងឥតប្រែប្រួលរបស់ពួកគេ ។ ប៉ុន្តែប្រការសំខាន់បំផុតដែលមន្ត្រីគណបក្សប្រជាជនកម្ពុជាគ្រប់រូបគួរយល់ដឹង ដើម្បីការពារការដឹកនាំរបស់គណបក្សនោះ គឺការលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច មិនធ្វេសប្រហែល មិនស្កប់ស្កល់នឹងជ័យជម្នះ យកចិត្តទុកដាក់បង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្ស ខិតខំអភិវឌ្ឍសមត្ថភាពរបស់ខ្លួន និងកែលម្អរាល់ចំណុចខ្វះខាតដែលធ្វើឱ្យប្រជាជនមិនពេញចិត្តឱ្យបានទាន់ពេលវេលា ។ ធ្វើដូច្នេះទើបអាចឆ្លើយតបបានទៅនឹងសំណូមពរនៃការដឹកនាំក្នុងសភាពការណ៍ថ្មី ដែលមានការប្រែប្រួល រីកចម្រើនឥតឈប់ឈរ ។ ការមានមោទនភាពពេកចំពោះ

តទៅទំព័រទី ២៧

opposition party seriously violate the Constitution and existing laws of Cambodia and wills of the voters as they aim at toppling down through the so called "people's power." They would not stand a chance to realize such ambition of theirs.

Over the past 35 years, all-level officials of the Cambodian People's Party are fully aware that there are those – both inside and outside the country - who have intended to wipe out the Cambodian People's Party from politics and will continue to nurture the intention by all means. It is their nature and unchangeable intention. The most important factor that every official of the Cambodian People's Party should understand in defending the party's leadership is to raise high their precautions always, not to neglect and be satisfied with the victory. They have to focus on augmenting efficiency in the implementation of the Party's political platform, making efforts to develop personal capability and improving shortcomings to match satisfactory responses in a timely manner to our people's demands.

By doing so, the Party will be able to respond to the demand for leadership in the new situation that is evolving ceaselessly. Being proud with what we have achieved would easily risk losing vigilance and being stagnant. This would in fact be a backward situation in the face of evolving progress. In its 35 years of leadership, though the Cambodian People's Party has many great qualities, there would be unavoidably subjective and objective shortcomings, especially the objective ones. Through the results of the elections of the fifth legislative term of the National Assembly, it is clear that the Cambodian people would like the new Royal Government to respond to the basic issues that are relating to their livelihood and strengthening cleanliness, social justice and equality.

In this understanding, officials of all levels of the Cambodian People's Party must absorb the new context and make further efforts to strengthen unity in view, position and action aimed at concentrating forces in the implementation of political platform and rectangular strategy phase-iii and ensuring effective results in implementing resolutely wide-ranging and deepening reforms, and the fight against corruption. Aiming to achieve these objectives, the 7 January spirit will stay as a strong and un-faltered impetus to achieve further achievements for the country and people, and to neutralize controversial tricks of the oppositions in all states and circumstances.

Basing on these only will guarantee always the significant meaning of the 7 January victory and the Cambodian People's Party's role in the Cambodian society and nation./.

*THE PRACHEACHUN MAGAZINE*

# ធាតុពិតនៃល្បិចកលប្រទូសរ៉ាយរបស់គណបក្សប្រឆាំង

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅនេះ បានប្រព្រឹត្តទៅក្នុងបរិយាកាសប្រកបដោយសន្តិភាព និងមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានវាយតម្លៃប្រកបដោយភាពវិជ្ជមានក្រៃលែង ហើយបានលើកទឹកចិត្តដល់ដំណើរអនុវត្តប្រជាធិបតេយ្យ និងការបោះឆ្នោតនៅកម្ពុជា ។ លើមូលដ្ឋានលទ្ធផលជាផ្លូវការនៃការបោះឆ្នោតដែល គ.ជ.ប បានប្រកាសបន្ទាប់ពីបានដោះស្រាយរាល់បណ្ដឹងតវ៉ាទាំងឡាយរួចរាល់ហើយនោះ គឺរដ្ឋសភានីតិកាលទី ៥ ត្រូវបានបង្កើតឡើងហើយ ដែលមានសមាជិកចំនួន១២៣រូប ។នៅថ្ងៃទី ២៣ ខែកញ្ញា តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ដូចប្រការដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ រដ្ឋសភានីតិកាលទី៥ បានបើកសម័យប្រជុំដំបូង ដោយមានព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់នៃអង្គព្រះមហាក្សត្រជាទីសក្ការៈ ។ បន្ទាប់មកសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ព្រឹទ្ធសមាជិកនៃរដ្ឋសភា បានប្រកាសសុពលភាពរបស់អ្នកតំណាងរាស្ត្រទាំង ១២៣ រូប ។ នៅថ្ងៃ ទី ២៤ ខែកញ្ញា រដ្ឋសភាបន្តបើកសម័យប្រជុំក្រោមអធិបតីភាពសម្ដេចព្រឹទ្ធសមាជិករដ្ឋសភា ស្របតាមរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដើម្បីបោះឆ្នោតជ្រើសតាំងក្បាលម៉ាស៊ីនដឹកនាំរដ្ឋសភា និងផ្ដល់ការទុកចិត្តដល់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៥ នេះ ដែលមានសម្ដេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ទោះបីជាអ្នកតំណាងរាស្ត្រទាំង ៥៥ រូបនៃគណបក្សសង្គ្រោះជាតិធ្វើពហិការកិច្ចប្រជុំនេះក្ដី ។ ថ្ងៃទី ២៥ ខែកញ្ញា គណៈរដ្ឋមន្ត្រីបានបើកកិច្ចប្រជុំដំបូងរបស់ខ្លួន ដោយបានប្រកាសចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ សម្រាប់អនុវត្តក្នុងរយៈពេល ៥ ឆ្នាំបន្តទៀត (២០១៣-២០១៨) ។ បានន័យថា ក្បាលម៉ាស៊ីនដឹកនាំនៃរដ្ឋសភានីតិកាលទី ៥ និងរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភាត្រូវបានបង្កើតឡើងរួចហើយ ហើយបាននិងកំពុងបំពេញការងាររបស់ខ្លួនយ៉ាងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដើម្បីបម្រើប្រជាជនជាម្ចាស់ឆ្នោត ។ ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនានានៃបណ្ដាប្រទេសក្នុងតំបន់ និងពិភពលោកបានផ្ញើសារអបអរសាទរចំពោះគណបក្សប្រជាជនកម្ពុជាដែលបានទទួលជោគជ័យក្នុងការបោះឆ្នោតនេះ និងបានអបអរសាទរគាំទ្រសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលត្រូវបានជ្រើសតាំងជាថ្មីជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងនីតិកាលទី ៥ នេះ។ ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃបណ្ដាប្រទេសបានបញ្ជាក់ច្បាស់នូវឆន្ទៈបន្តពង្រីងពង្រីកកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

ប៉ុន្តែគណបក្សប្រឆាំង និងមជ្ឈដ្ឋានអគតិមួយចំនួនបានប្រើប្រាស់គ្រប់វិធីប៉ុនប៉ងបំផ្លាញលទ្ធផលនៃការបោះឆ្នោត តាមរយៈការបញ្ឆេះចលនាបាតុកម្មមហាជន និងបណ្ដាសកម្មភាពដទៃទៀតសំដៅផ្លាស់ប្ដូរសភាពការណ៍នៅកម្ពុជា។ ពួកគេបានប្រមាថ រំលោភបំពានតួនាទីរបស់ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ និងហ៊ានរហូតដល់ ប្រមាថស្ថាប័នព្រះមហាក្សត្រថែមទៀតផង តាមរយៈការមួលបង្កាច់ចំពោះភាពត្រឹមត្រូវនៃលទ្ធផលបោះឆ្នោត និងការប្រកាសថា កិច្ចប្រជុំរដ្ឋសភាក្រោមព្រះរាជាធិបតីភាពនៃអង្គព្រះមហាក្សត្រនៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣ គឺខុសរដ្ឋធម្មនុញ្ញ ហើយការបង្កើតរាជរដ្ឋាភិបាលនីតិកាលទី ៥ ក៏ខុសរដ្ឋធម្មនុញ្ញដែរ ។ ដោយឡែក នៅថ្ងៃទី ៦ ខែតុលា ក្នុងរបស់ដែលហៅថា "សមាជប្រជាជន" ដែលធ្វើនៅទីលានប្រជាធិបតេយ្យ ក៏ដូចសេចក្ដីថ្លែងការណ៍របស់ពួកគេជាបន្តបន្ទាប់មកទៀតនៅតាមកន្លែងនានា គណបក្សសង្គ្រោះជាតិបានធ្វើការទាមទារជាច្រើនចំណុច ដោយរួមមានការស្នើដោយខុសច្បាប់ឱ្យបង្កើតនូវអ្វីដែលហៅថា គណៈកម្មការឯករាជ្យមួយ ដើម្បីស្វែងរកយុត្តិធម៌ជូនម្ចាស់ឆ្នោត ការទាមទារឱ្យរំលាយ គ.ជ.ប ភ្លាមៗ ការទាមទារឱ្យមានតុល្យភាពអំណាចក្នុងរដ្ឋសភា ។ល ។ ពួកគេបានជំរុញការធ្វើបាតុកម្មតាមដងផ្លូវ ដោយមិនគោរពច្បាប់ មិនស្ដាប់ការណែនាំរបស់អាជ្ញាធររាជធានី ខេត្ត រហូតដល់គំរាមបិទច្រកផ្លូវចេញចូលរាជធានីថែមទៀត ។ ចុងក្រោយនេះ កាលពីថ្ងៃ ១០ ធ្នូ ពួកគេបានទាមទារឱ្យសម្ដេចតេជោ **ហ៊ុន សែន** ចុះចេញពីតំណែង និងឱ្យរៀបចំការបោះឆ្នោតជាថ្មីឡើងវិញ ។ រាល់ការទាមទារទាំងអស់នេះកំពុងរំលោភបំពានយ៉ាងធ្ងន់ធ្ងរបំផុតលើរដ្ឋធម្មនុញ្ញ គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងឆន្ទៈរបស់ប្រជាពលរដ្ឋភាគច្រើនលើសលប់ ។

គ.ជ.ប គឺជាស្ថាប័នធម្មនុញ្ញមួយមានលក្ខណៈឯករាជ្យ អព្យាក្រឹត ដែលមានតួនាទីរៀបចំចាត់ចែង និងត្រួតពិនិត្យការបោះឆ្នោតរហូតដល់ការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ ។ ច្បាប់មិនអនុញ្ញាតឱ្យបង្កើតគណៈកម្មការណាមួយផ្សេងពីនេះ ដើម្បីគ្រប់គ្រងលើដំណើរការបោះឆ្នោតទេ ។កម្ពុជាជារដ្ឋអធិបតេយ្យ ជានីតិរដ្ឋដែលមានច្បាប់ មានយន្តការយុត្តាធិការច្បាស់លាស់សម្រាប់រៀបចំដំណើរការបោះឆ្នោត និងដោះស្រាយវិវាទក្នុងដំណើរការបោះឆ្នោត ។ ការស្នើឱ្យបង្កើតយន្តការថ្មីណាមួយគឺជាការបំពានលើរដ្ឋធម្មនុញ្ញ និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលបានបង្ហាញច្បាស់ថា គឺមានតែ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញប៉ុណ្ណោះដែលមានសមត្ថកិច្ចក្នុងការដោះស្រាយរាល់វិវាទទាក់ទងនឹងដំណើរការនៃការបោះឆ្នោត ។ពួកគេបានចោទប្រកាន់អំពីការលួចបន្លំសន្លឹកឆ្នោត ប៉ុន្តែនៅក្នុងការបោះឆ្នោតនេះមានអ្នកសង្កេតការណ៍បោះឆ្នោតជាង ៤ ម៉ឺននាក់ ជាពិសេស

ភ្នាក់ងាររបស់បណ្តាគណបក្សនយោបាយនៅតាមការិយាល័យបោះ ឆ្នោតទាំងជាង ១៩ 000 នៅទូទាំងប្រទេស ដែលក្នុងនោះសុទ្ធតែមាន ម្នាក់ជាភ្នាក់ងាររបស់គណបក្សសង្គ្រោះជាតិដែលបានចុះហត្ថលេខា ទទួលស្គាល់លើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតក្នុងការិយាល័យ និមួយៗរួចហើយ ។ ការដោះស្រាយបណ្តឹង តវ៉ាចំពោះលទ្ធផលនៃការ បោះឆ្នោតនៅតាមការិយាល័យនានា ត្រូវបានអនុវត្តយ៉ាងម៉ត់ចត់តាម ច្បាប់ និងនីតិវិធីរបស់ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ ប្រកបដោយ លក្ខណៈចំហ តម្លាភាព និងយុត្តិធម៌ ។ លទ្ធផលនៃការដោះស្រាយ បណ្តឹងតវ៉ាបានបង្ហាញថា ទោះបីមានកង្វះខាតតិចតួចខាងបច្ចេកទេស ក្តី ក៏ពុំបានធ្វើឱ្យប៉ះពាល់ដល់ លទ្ធផលនៃការបោះឆ្នោតឡើយ ។ ហេតុ នេះការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត គឺត្រូវបានបញ្ចប់ហើយ មិន អាចវិលថយក្រោយវិញបានឡើយ ។

ឯការទាមទារឱ្យមានតុល្យភាពអំណាចក្នុងរដ្ឋសភា គឺជាការទាម ទារដែលផ្ទុយពីលទ្ធផលនៃការបោះឆ្នោត ។ ពីព្រោះតាមរយៈលទ្ធផល នៃការបោះឆ្នោត គឺគណបក្សប្រជាជនកម្ពុជាមានសំឡេងលើសពីភាគ ច្រើនដាច់ខាតទៅទៀត ដែលជាចំនួនសំឡេងគ្រប់គ្រាន់ដើម្បីដឹកនាំរដ្ឋ សភា និងបង្កើតរាជរដ្ឋាភិបាល ។ ចំណែកគណបក្សប្រឆាំង ដែលទទួល បានអាសនៈភាគតិចក្នុងរដ្ឋសភាមិនអាចបង្កើតឱ្យមានការជាប់គាំង នៃរដ្ឋសភា និងរាជរដ្ឋាភិបាលបានឡើយ ។ បើគណបក្សមានសំឡេង ភាគតិចអាចបង្កភាពជាប់គាំងបាននោះ ពិតប្រាកដណាស់ថា មហន្តរាយនឹងកើតមានចំពោះប្រទេសជាតិ និងប្រជាជន ហើយប្រជាធិបតេយ្យក៏គ្មានតម្លៃអ្វីដែរ ។កម្ពុជាប្រកាន់យករបបរាជានិយមអាស្រ័យ សភា និងមានប្រព័ន្ធនយោបាយប្រជាធិបតេយ្យ សេរី ពហុបក្ស ដូច្នេះ បើគណបក្សណាឈ្នះឆ្នោតទទួលបានអាសនៈច្រើនជាងគេ ត្រូវតែជា គណបក្សដឹកនាំទាំងក្នុងរដ្ឋសភា និងក្នុងរាជរដ្ឋាភិបាល ។

គណបក្សប្រឆាំងក៏បានទាមទារឱ្យមានកំណែទម្រង់លើវិស័យនា នា ទាំងខាងនយោបាយ សេដ្ឋកិច្ច សង្គម ច្បាប់ និងប្រព័ន្ធតុលាការ ដែល អ្វីៗទាំងនេះមិនមែនជាចំណុចថ្មីឡើយ ព្រោះថា រាជរដ្ឋាភិបាលបានធ្វើ ហើយ កំពុងតែបន្តធ្វើ ដូចបានបញ្ជាក់ច្បាស់នៅក្នុងកម្មវិធីនយោបាយ និង "យុទ្ធសាស្ត្រចតុកោណ" ដំណាក់កាលទី ៣ ។ រាជរដ្ឋាភិបាលកម្ពុជា បានសន្យាយ៉ាងម៉ឺងម៉ាត់ក្នុងការបន្តអនុវត្តកំណែទម្រង់រដ្ឋទូលំទូលាយ និងស៊ីជម្រៅឱ្យកាន់តែខ្លាំងក្លាឡើង និងកាន់តែមានប្រសិទ្ធភាពឡើង ដែលនេះមិនមែនដើម្បីបំពេញតាមការទាមទាររបស់គណ បក្សប្រឆាំងទេ ប៉ុន្តែវាជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ក្នុង ការបម្រើប្រទេសជាតិ និងប្រជាជន ។ ទាក់ទងនឹងកំណែទម្រង់ការ បោះឆ្នោត រាជរដ្ឋាភិបាលបានប្រកាសអំពីការរៀបចំសិក្ខាសាលាជាតិ មួយនៅដើមឆ្នាំ ២០១៤ នេះ ហើយបានអំពាវនាវដល់បណ្តាគណបក្ស នយោបាយ អង្គការសង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធនានាចូលរួមក្នុងសិក្ខាសាលាជាតិនេះ សំដៅប្រមូលរាល់មតិយោបល់ដ៏ល្អៗនានា ដើម្បីធានាឱ្យការបោះឆ្នោតក្រោយៗទៀតកាន់តែ មានលក្ខណៈល្អប្រសើរឡើង ។

ឯការទាមទារឱ្យសម្តេចតេជោ **ហ៊ុន សែន** ចុះចេញពីតំណែង និងឱ្យមានការបោះឆ្នោតឡើងវិញនោះ គឺជាប្រការដែលមិនអាច ទទួលយកបានជាដាច់ខាត ព្រោះថា សម្តេចតេជោ **ហ៊ុន សែន** បានឡើងកាន់តំណែងតាមរដ្ឋធម្មនុញ្ញ បើចុះចេញមានតែតាមរដ្ឋធម្មនុញ្ញប៉ុណ្ណោះ ។ ចំពោះរដ្ឋសភា មិនអាចត្រូវរំលាយមុនអាណត្តិ បានទេ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុង រយៈពេល ១២ ខែ ( មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ) ដូច្នេះគ្មានហេតុផល និងមូលដ្ឋានច្បាប់ណាដែលតម្រូវឱ្យរំលាយរដ្ឋសភា ហើយនាយករដ្ឋ មន្ត្រីត្រូវលាលែងពីតំណែងមុនអាណត្តិនោះទេ ។

ការពិតបានបង្ហាញច្បាស់អស់ហើយ បើដូច្នោះ តើហេតុអ្វីក៏គណបក្សប្រឆាំងនៅតែមិនទទួលយកការពិតនេះ ហើយបន្តលើកឡើងនូវ ការទាមទារដដែលៗនោះ ? ទង្វើរបស់ពួកគេគឺសំដៅបិទបាំងនូវភាព បរាជ័យរបស់ខ្លួនក្នុងការបោះឆ្នោត ព្រោះថាគេបានប្រកាសត្រៀមធ្វើ ជានាយករដ្ឋមន្ត្រី និងជាប្រធានរដ្ឋសភាតាំងពីមុនបោះឆ្នោតម្ល៉េះ សំខាន់ បំផុតគឺគេត្រូវការកាន់កាប់អំណាចនៅគ្រប់ស្ថាប័នរដ្ឋ និងអាជ្ញាធរនៅ គ្រប់ថ្នាក់ ។ និយាយឱ្យច្បាស់ថែមទៀត គឺគេត្រូវការផ្តួលរំលំគណបក្ស ប្រជាជនកម្ពុជាដើម្បីដណ្តើមអំណាច ទោះតាមមធ្យោបាយណាក្តី ។ អ្វីៗដែលគេបានធ្វើ កំពុងធ្វើ និងបន្តធ្វើទៅទៀតនោះ មិនខុសអ្វីពីការ ប្រឹងស្រវេស្រវាបន្ថែមអុសទៅលើរងើកភ្លើងដែលរកកលនឹងរលត់ ទៅហើយឱ្យបន្តឆេះនោះទេដើម្បីចិញ្ចឹមសកម្មភាពរបស់ខ្លួនឱ្យនៅ រស់តទៅទៀត គឺមិនមែនដើម្បីផលប្រយោជន៍ប្រទេសជាតិ និងប្រជា ជនឡើយ ។

មកដល់ពេលនេះប្រជាជនភាគច្រើនលើសលប់បានយល់ថា គណបក្សប្រឆាំងចេះត្រឹមតែការសន្យាបោកប្រាសប្រជាជននិងបង្កការ លំបាកឱ្យសង្គមជាតិប៉ុណ្ណោះ ។ ចំណែកគណបក្សប្រជាជនកម្ពុជាកំពុង តែខិតខំអនុវត្តឱ្យបានសម្រេចនូវអ្វីដែលខ្លួនបានសន្យាចំពោះប្រជាជន ។ គ្មានមូលហេតុអ្វីដែលត្រូវទុកឱ្យប្រទេសជាតិ និងប្រជាជនក្លាយ ជាចំណាប់ខ្មាំងនៃទង្វើមិនស្របច្បាប់របស់គណបក្សប្រឆាំងនោះ ឡើយ ។ មកដល់ពេលនេះ ទោះបីជាគណបក្សប្រឆាំងមិនទទួលស្គាល់ លទ្ធផលនៃការបោះឆ្នោត មិនទទួលស្គាល់រដ្ឋសភា និងរាជរដ្ឋាភិបាល ដែលកើតចេញពីការបោះឆ្នោតយ៉ាងណាក៏ដោយ ក៏ស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិទាំងពីរនេះកំពុងដំណើរការប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ ហើយទទួលបាននូវការគាំទ្រពីប្រជាជនភាគ ច្រើនលើសលប់ព្រមទាំងសហគមន៍អន្តរជាតិ ។/

# មិទ្ទិញអបអរខួបអនុស្សាវរីយ៍លើកទី ៣៥ ថ្ងៃបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា





*សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** និងលោកជំទាវអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធវិមានអនុស្សាវរីយ៍ ២ ធ្នូ និង ពិធីមិទ្ទិញអបអរខួបអនុស្សាវរីយ៍លើកទី ៣៥ ថ្ងៃបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា*

កាលពីព្រឹកថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៣ សំណង់វិមានអនុស្សាវរីយ៍ ២ ធ្នូដ៏ធំស្កឹមស្កៃ ដែលសាងសង់ឡើងនៅភូមិជើងឃ្លូ ឃុំ ២ ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ជាកន្លែងចាប់បដិសន្ធិនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា (បច្ចុប្បន្នបានប្តូរឈ្មោះថា រណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា) ត្រូវបានសម្ពោធជាផ្លូវការ ។ នៅទីនោះដែរ ពិធីមហាមិទ្ទិញអបអរខួបអនុស្សាវរីយ៍លើកទី ៣៥ ថ្ងៃបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ក៏បានប្រារព្ធឡើងយ៉ាងអធិកអធមនៅបរិវេណទីតាំងជាប្រវត្តិសាស្ត្រនេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា និងលោកជំទាវ ។

អញ្ជើញចូលរួមក្នុងពិធីនោះ មានឯកឧត្តម លោកជំទាវជាមន្ត្រីថ្នាក់ដឹកនាំក្នុងជួររាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ព្រមទាំងថ្នាក់ដឹកនាំក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា សមាជិក សមាជិការណសិរ្ស មកពីបណ្តាស្ថាប័នរដ្ឋ និងរាជធានី ខេត្ត នៅទូទាំងប្រទេស ព្រមទាំងមន្ត្រីរាជការនិងមហាជនសរុបជាង ២ ម៉ឺននាក់ ទន្ទឹមនោះក៏មានការចូលរួមអបអរសាទរពីសំណាក់ប្រតិភូជាន់ខ្ពស់នៃមជ្ឈិមរណសិរ្សមាតុភូមិវៀតណាម រណសិរ្សកសាងជាតិឡាវ និងតំណាងស្ថានទូត បណ្តាប្រទេសជាមិត្តមួយចំនួនប្រចាំនៅកម្ពុជា ។

តាមរបាយការណ៍របស់គណកម្មការទទួលបន្ទុកកិច្ចការសាងសង់ ដែលបានលើកឡើងដោយឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងជាអនុប្រធានក្រុមប្រឹក្សាជាតិរណសិរ្សបានឱ្យដឹងថា វិមានអនុស្សាវរីយ៍រណសិរ្ស ២ ធ្នូនេះ បានចំណាយថវិកាសាងសង់សរុបអស់ ចំនួន ៤ លានដុល្លារអាមេរិក លើទំហំផ្ទៃដីជាង ១៣ ហិកតា មានកម្ពស់ជាង ៤០ ម៉ែត្រ។ សំណង់នេះធ្វើពីបេតុង អាមេ។ មានបណ្តោយប្រវែង ២០៧ ម៉ែត្រ ទទឹងផ្នែកធំប្រវែង ៩១,៦៥ ម៉ែត្រ និងទទឹងផ្នែកតូចប្រវែង ៦៣ ម៉ែត្រ ។ សំណង់វិមានបានរៀបចំជាខឿនធំ និងខឿនតូច តាមលំដាប់ថ្នាក់យកលំនាំតាមប្រាសាទបាភ្នំ ដាក់ឱ្យបែរមុខទៅទិសខាងកើត ដែលខឿនមានពីរលាតសន្ធឹងពីលិចទៅកើតមានប្រវែងសរុបជាង២០០ម៉ែត្រនិងខឿនធំលាតសន្ធឹងពីជើងទៅត្បូងមានប្រវែងជាង ៩០ ម៉ែត្រ។ ការសាងសង់គឺមានតួសសរវិមានមានរាងជាដងធ្នូខ្ពស់ត្រដែតឡើងលើអាកាសដែលមានកម្ពស់ ៤៣ ម៉ែត្រ ហើយនៅលើកំពូលតួសសរមានតាំងចម្លាក់យុទ្ធជន យុទ្ធនារី ២ នាក់ធ្វើពីស្ពាន់មានកម្ពស់ ៣ ម៉ែត្រ លើកដៃជ្រោងទង់ជាតិក្នុងចលនាបោះពួយទៅមុខឆ្ពោះទៅទិសខាងកើត ប្រកបដោយភាពអង់អាចក្លាហានក្នុងការប្រយុទ្ធតស៊ូរំដោះជាតិមាតុភូមិចេញពីរបបប្រល័យពូជសាសន៍ប៉ុលពត ។

ថ្លែងទៅកាន់អង្គមហាមិទ្ទិញនៅក្នុងឱកាសនោះ សម្តេចពញាចក្រី **ហេង សំរិន** បានលើកឡើងថា មហាមិទ្ទិញអបអរសាទរខួបអនុ-ស្សាវរីយ៍លើកទី ៣៥ ថ្ងៃបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានេះបានប្រព្រឹត្តទៅយ៉ាងអធិកអធម និងមានមោទនភាព រីករាយក្រៃលែង ជាមួយនឹងការដាក់សម្ពោធនូវវិមានអនុស្សាវរីយ៍ប្រវត្តិសាស្ត្រនេះសម្រាប់ជាការចងចាំនូវមហាចលនាសាមគ្គីតស៊ូសង្គ្រោះជាតិ ទាំងអ្នកជំនាន់នេះ និងជំនាន់ក្រោយៗទៀត។ ថ្វីត្បិតពេលវេលា ៣៥ ឆ្នាំបានកន្លងផុតទៅ ប៉ុន្តែយើងទាំងអស់គ្នាពិតជាមិនអាចបំភ្លេចបានរឿងរ៉ាវពីអតីតកាលដ៏ងងឹតសូន្យសុងពោរពេញទៅដោយទុក្ខវេទនាការឈឺចាប់ខ្លោចផ្សា និរាសព្រាត់ប្រាស់ ក្នុងរយៈពេល ៣ ឆ្នាំ ៨ ខែ





*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** និងលោកជំទាវ សម្ពោធវិមានអនុស្សាវរីយ៍ ២ ធ្នូ នៅភូមិជើងឃ្លូ ឃុំ ២ ធ្នូ ស្រុកស្នួល ខេត្តក្រចេះ*

២០ ថ្ងៃ ក្រោមរបបប្រល័យពូជសាសន៍ប៉ុល ពត នោះឡើយ ។

សម្តេចពញាចក្រី **ហេង សំរិន** បានមានប្រសាសន៍ថា យើងទាំងអស់គ្នាសូមចាត់ទុកមហាមិទ្ទិញនេះគឺជាព្រឹត្តិការណ៍ជាតិមួយដ៏មានសារៈសំខាន់បំផុតចំពោះបុព្វហេតុនៃការរស់រានមានជីវិតឡើងវិញរបស់មាតុភូមិ និងប្រជាជនកម្ពុជា ហើយយើងទាំងអស់គ្នា សូមប្រកាសជាឧឡារិកបន្ថែមទៀតថា រណសិរ្ស ២ ធ្នូមិនត្រឹមតែសង្គ្រោះយើងទាំងអស់គ្នាឱ្យចាកផុតពីគ្រោះមហន្តរាយនៃរបបប្រល័យពូជ-សាសន៍ប៉ុណ្ណោះទេ ប៉ុន្តែរណសិរ្ស ២ ធ្នូ នៅបានជួយស្តារកសាង និងអភិវឌ្ឍន៍សង្គមជាតិនៅគ្រប់ទិសទីធ្វើឱ្យមាតុភូមិកម្ពុជា មានការកែប្រែមុខមាត់ថ្មីជាបន្តបន្ទាប់ ។ បច្ចុប្បន្នប្រជាជនកម្ពុជាបានរស់នៅយ៉ាងសុខដុមរមនា ក្នុងសន្តិភាព និងសន្តិសុខល្អប្រសើរ ។ កម្ពុជាកំពុងមានការអភិវឌ្ឍជឿនលឿនដែលបច្ចុប្បន្នកម្ពុជាបានក្លាយជាប្រទេសនាំស្បៀងចេញ ហើយស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ១១ ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់លើពិភពលោកក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ សម្តេចពញាចក្រី ក្នុងនាមក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា បានគាំទ្រពេញទំហឹងដល់ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលក្នុងការប្រឹងប្រែងបន្តជំរុញសន្ទុះរីកចម្រើនប្រទេសជាតិប្រកបដោយចីរភាព និងការលើកតម្កើងនីតិរដ្ឋ សមធម៌ និងយុត្តិធម៌សង្គម ។

សម្តេចបានបន្តទៀតថា ដោយសារតែនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យប្រទេសជាតិមានសន្តិភាព ស្ថិរភាព និងការរីកចម្រើនលើគ្រប់វិស័យ ដោយមានបណ្តាប្រទេសជាច្រើនរឹតចំណងសាមគ្គីភាពមិត្តភាពនិងកិច្ចសហប្រតិបត្តិការជិតស្និទ្ធថែមទៀត ។ទន្ទឹមនឹងយើងទាំងអស់គ្នាបាននិងកំពុងសប្បាយរីករាយអប-អរសាទរចំពោះសមិទ្ធផលដែលសម្រេចបាននេះ យើងក៏មិនអាចបំភ្លេចបាននូវពលិកម្មនិងការបូជាអាយុជីវិតដ៏ឧត្តុង្គឧត្តមរបស់បងប្អូនជនរួមជាតិរបស់យើងនៅទូទាំងប្រទេស ដែលបានធ្វើការតស៊ូប្រយុទ្ធប្រឆាំងនឹងអំពើអមនុស្សធម៌ទាំងឡាយរបស់ពួកឃាតករកម្ពុជាប្រជាធិបតេយ្យដើម្បីឱ្យជាតិមាតុភូមិបានរស់រានឡើងវិញ ហើយថ្ងៃ២នេះការប្តេជ្ញារបស់កងទ័ពកម្ពុជា ក្នុងការការពារបូរណភាពទឹកដីនៅព្រំ-ដែនភាគខាងលិចដោយភាពអង់អាចក្លាហានគួរឱ្យគោរពកោតសរ-សើរបំផុត។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា គឺជារណសិរ្សមួយដែលត្រូវបានចារទុកជាប្រវត្តិសាស្ត្រ។ កុលបុត្រកុលធីតាខ្មែរគ្រប់ជំនាន់នៅតែចងចាំជានិច្ច មិនភ្លេចនូវគុណូបការៈដ៏អស្ចារ្យ និងធំធេងបំផុតកាលពី ៣៥ ឆ្នាំមុន នោះគឺថ្ងៃទី ២ ធ្នូ ឆ្នាំ ១៩៧៨ ជាថ្ងៃដែលប្រជាជនខ្មែរទទួលដំណឹងថាមានកងទ័ពអ្នកស្នេហាជាតិបានរួបរួមគ្នាបង្កើតឡើងជារណសិរ្សមួយដើម្បីសង្គ្រោះជាតិឱ្យចាកផុតពីទុក្ខវេទនាដែលរបបប៉ុលពតបានបង្កឡើង ។ សម្តេចបានលើកឡើងទៀតថាប្រជាជនគ្រប់រូបសុទ្ធតែយល់ច្បាស់ថាបើគ្មានថ្ងៃកំណើតរណសិរ្ស ២ ធ្នូ និងជ័យជម្នះ ៧ មករាទេនោះ យើងក៏គ្មានថ្ងៃនេះដែរ "នេះជាសច្ច-ធម៌ប្រវត្តិសាស្ត្រដែលយើងទាំងអស់គ្នាត្រូវចងចាំ" ។គួរបញ្ជាក់ដែរថាបន្ទាប់ពីប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញ និងមានការអភិវឌ្ឍជាបន្តបន្ទាប់ បច្ចុប្បន្នភូមិជើងឃ្លូដែលមានចម្ងាយប្រមាណ ១ គីឡូម៉ែត្រ ពីទីប្រជុំជនផ្សារ ២ ធ្នូ ទីរួមស្រុកស្នួលនោះ បាន និងកំពុងប្រែក្លាយជាតំបន់ទីប្រជុំជននិងកំពុងអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ ។រាជរដ្ឋាភិបាលបានធ្វើផ្លូវជាតិលេខ៧៦ឆ្លងកាត់តំបន់នេះផងដែរ។ ក្នុងបរិវេណវិមានអនុស្សាវរីយ៍រណសិរ្ស ២ ធ្នូក្រៅពីធ្វើសួន ក៏បានដាំដើមឈើជាច្រើនដើម មានប្រភេទកូនគគីរ កូនឈើទាល និងប្រភេទកូនឈើល្អៗជាច្រើនទៀត បានធ្វើការជួសជុលអគារមួយខ្នងដែលបន្សល់ទុកកាលពីសម័យនោះ ទុកសម្រាប់កម្មករចម្ការកៅស៊ូស្នាក់នៅទៀតផង ។/

# កម្ពុជា_ជប៉ុន បង្កើនកិច្ចសហប្រតិបត្តិការដល់ភាពជាដៃគូយុទ្ធសាស្ត្រ

## ❖ កិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍លើកទី ៤០ នៃទំនាក់ទំនងអាស៊ាន_ជប៉ុន និងកិច្ចប្រជុំកំពូលមេគង្គ_ជប៉ុន លើកទី ៤



*ឯកឧត្តម **ស៊ិនហ្សូ អាបេ** ទទួលស្វាគមន៍យ៉ាងកក់ក្ដៅ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន***

ចាប់ពីថ្ងៃទី ១២-១៧ ខែធ្នូ ឆ្នាំ ២០១៣ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមកិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍ទំនាក់ទំនង អាស៊ាន-ជប៉ុន លើកទី ៤០ និងកិច្ចប្រជុំកំពូលមេគង្គជប៉ុនលើកទី ៥ ព្រមទាំង ទស្សនកិច្ចការងារផ្លូវការនៅទីក្រុងតូក្យូ ប្រទេសជប៉ុន។

កិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍ ៤០ ឆ្នាំ នៃទំនាក់ទំនងភាពជាដៃគូសន្ទនាអាស៊ាន-ជប៉ុនបានប្រារព្ធពិធីបើកជាផ្លូវការនៅព្រឹកថ្ងៃទី ១៤ ធ្នូ ក្រោម ប្រធានបទ "តភ្ជាប់គំនិត តភ្ជាប់អនាគត"។

កិច្ចប្រជុំកំពូលនេះបានធ្វើការពិភាក្សាលើរបៀបវារៈសំខាន់ៗចំនួន ៧ ក្នុងនោះរួមមាន ទី១-កិច្ចសហប្រតិបត្តិការផ្នែកនយោបាយ និងសន្តិសុខ ទី២-កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច ទី៣-កិច្ចសហប្រតិបត្តិការលើបញ្ហាប្រឈមផ្នែកសង្គម សេដ្ឋកិច្ច ទី៤-កិច្ចសហប្រតិបត្តិការស្ដីពីការផ្លាស់ប្ដូរប្រជាជន និងប្រជាជននិងវប្បធម៌ ទី៥-ការផ្លាស់ប្ដូរទស្សនៈលើបញ្ហាតំបន់និងអន្តរជាតិនិង ទី៦-ការអនុម័តសេចក្ដីប្រកាសរួមស្ដីពីចក្ខុវិស័យរយៈពេលមធ្យម និងរយៈពេលវែងស្ដីពីមិត្តភាព និងកិច្ចសហប្រតិបត្តិការអាស៊ាន ជប៉ុន និងទី៧-បញ្ហាផ្សេងៗ។

នៅក្នុងកិច្ចប្រជុំកំពូលដ៏មានសារៈសំខាន់នេះ មេដឹកនាំអាស៊ាន ជប៉ុនបាន ទទួលស្គាល់ថាទំនាក់ទំនង ពិសេសរវាងអាស៊ាន និងជប៉ុន បានផ្អែកលើការយោគយល់អស់ពីដួងចិត្ត ការជឿជាក់ទៅវិញមក ការគោរព និងគោលការណ៍នានាដែលតម្រង់ទិសដៅដៃគូអាស៊ាន ជប៉ុនចាប់តាំងពីឆ្នាំ ១៩៧៣។ ជាមួយគ្នានេះ មេដឹកនាំទាំងអស់បានអះអាងសាជាថ្មីនូវសារៈសំខាន់សម្រាប់ក្នុងការបន្តគាំទ្រតួនាទីស្នូលរបស់អាស៊ាននៅក្នុងនិម្មាបនកម្មតំបន់ដែលកំពុងវិវត្ត រួមមាន អាស៊ានបូកបី កិច្ចប្រជុំកំពូលអាស៊ីបូព៌ា កិច្ចប្រជុំកំពូលរដ្ឋមន្ត្រីការពារជាតិអាស៊ាន បូកបី និងវេទិកាតំបន់អាស៊ាន នៅក្នុងដំណើរការកសាងសហគមន៍អាស៊ីបូព៌ា។ មេដឹកនាំអាស៊ានក៏បានទទួលស្គាល់នូវសារៈសំខាន់ក្នុងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការសម្រាប់អនាគតនៃទំនាក់ទំនងអាស៊ាន ជប៉ុន ក្នុងការគាំទ្រការកសាងសហគមន៍អាស៊ាន និងរួមចំណែកដល់ចក្ខុវិស័យអាស៊ានក្រោយឆ្នាំ ២០១៥។ នៅក្នុងកិច្ចប្រជុំកំពូលរំឭកខួបនេះដែរ មេដឹកនាំអាស៊ាន ជប៉ុន បានចែករំលែកនូវចក្ខុវិស័យនៃតំបន់មួយដែលផ្អែកលើមូលដ្ឋានច្បាប់មានសន្តិភាពនិងស្ថិរភាពនិងប្ដេជ្ញាសម្រេចឱ្យបាននូវចក្ខុវិស័យមួយចំនួនតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីថែរក្សាសន្តិភាព ស្ថិរភាព និងវិបុលភាព តាមរយៈការគោរពគោលការណ៍ច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាសកល។ ដោះស្រាយជម្លោះដោយសន្តិវិធីតាមរយៈកិច្ចសន្ទនា និងការពិគ្រោះយោបល់ ការមិនគំរាមកំហែងឬការប្រើប្រាស់កម្លាំង និងអនុលោមទៅតាមគោលការណ៍ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ជាសកល។ ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការត្រៀមបង្ការគ្រោះអាសន្ន ការគ្រប់គ្រងគ្រោះមហន្តរាយ និងជំនួយសង្គ្រោះ ជំនួយមនុស្សធម៌ ការពារជាតិប្រតិបត្តិការអង្គការសហប្រជាជាតិ ដើម្បីថែរក្សាសន្តិភាព ការប្រឆាំងនឹងភេរវកម្ម ចោរសមុទ្រ សន្តិសុខតាមអ៊ីនធើណែត ការមិនសាយភាយអាវុធនុយក្លេអ៊ែរ ការរំសាយ និងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរក្នុងគោលដៅសន្តិភាព ការរត់ពន្ធគ្រឿងញៀន ការរត់ពន្ធមនុស្ស និងសិទ្ធិមនុស្ស។ អះអាងសាជាថ្មីគាំទ្រ និងគោរពដល់សារៈសំខាន់នៃសន្តិសុខ និងសុវត្ថិភាព លំហសមុទ្រ សេរីភាពនាវាចរណ៍ពាណិជ្ជកម្មដែលគ្មានការរាំងស្ទះនិងស្វះស្វែងរកគ្រប់យន្តការផ្សេងៗដើម្បីដោះស្រាយជម្លោះដោយសន្តិវិធី ដោយគ្មានការគំរាមកំហែង ឬប្រើប្រាស់កម្លាំង និងអនុលោមទៅតាមគោលការណ៍ច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាសកល រួមមានអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ ១៩៨២ ស្ដីពីច្បាប់សមុទ្រ (UNCLOS)។ លើវិបុលភាពសេដ្ឋកិច្ច មេដឹកនាំអាស៊ាន ជប៉ុនបានប្ដេជ្ញាបង្កើតតំបន់ពាណិជ្ជកម្ម សេរីដែលបើកចំហ និងមានតម្លាភាពសម្រាប់តំបន់មួយប្រកបដោយសុវត្ថិភាព តាមរយៈពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យដែលមានផលប្រយោជន៍ទៅវិញទៅមក ទាក់ទងនឹងពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម និងការវិនិយោគ។ លើកកម្ពស់ និងបន្តពង្រឹងការប្រើប្រាស់ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ានជប៉ុន (AJCEP) ដើម្បីបន្តពង្រឹងកំណើនសេដ្ឋកិច្ចទាំងមូល និងការអភិវឌ្ឍដែលអំណោយផលដល់ធុរកិច្ច។ គាំទ្រដំណើរការឈានទៅសម្រេចបាននូវភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP)។ ពង្រឹងការតភ្ជាប់អាស៊ាន និងការតភ្ជាប់រវាងអាស៊ាន និងជប៉ុនព្រមទាំងកាត់បន្ថយគម្លាតអភិវឌ្ឍន៍នៅក្នុងតំបន់ ជាពិសេសតាមរយៈរបៀងសេដ្ឋកិច្ច តំបន់សេដ្ឋកិច្ចពិសេស និងតំបន់អភិវឌ្ឍន៍។ បន្តពង្រឹងកិច្ចសហប្រតិបត្តិការអនុតំបន់។ ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យសន្តិសុខថាមពល។ ពង្រឹងសមត្ថភាព និងសក្ដានុពលនៃឧស្សាហកម្ម និងធុរកិច្ច

រួមមាន សហគ្រាសធុនតូច និងមធ្យមនៅក្នុងតំបន់ ជាពិសេសនៅក្នុងវិស័យឧស្សាហកម្មកែច្នៃ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) និងថាមពល ។ លើការអភិវឌ្ឍធនធានមនុស្ស និងចីរភាពបរិស្ថាន មេដឹកនាំអាស៊ាន និងជប៉ុនបានប្ដេជ្ញាធ្វើការជាមួយគ្នាដើម្បីលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស និងជំនះឱ្យបាននូវបញ្ហាបរិស្ថាននិងសង្គម តាមរយៈជំរុញកិច្ចសហប្រតិបត្តិការលើការច្នៃប្រឌិតវិទ្យាសាស្ត្របច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) ។ ពង្រឹងភាពជាដៃគូក្នុងវិស័យកសិកម្ម ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានទឹក ។ ពង្រឹងកិច្ចសហប្រតិបត្តិការ ដោះស្រាយបញ្ហាប្រឈមនានា ដែលបណ្ដាលមកពីបម្រែបម្រួលអាកាសធាតុ គ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស និងដោយធម្មជាតិ ។ ចែករំលែកបទពិសោធន៍ និងចំណេះដឹងដើម្បីលើកកម្ពស់ប្រព័ន្ធថែទាំសុខភាព បណ្ដាញសុវត្ថិភាពសង្គម និងការចូលរួមរបស់ស្ត្រីនៅក្នុងសង្គម ។ បង្កើនការយល់ដឹងនិងចែករំលែកបទពិសោធន៍ និងចំណេះដឹងស្ដីពីសុវត្ថិភាព និងសន្តិសុខថាមពល ការប្រើប្រាស់ថាមពលប្រកបដោយចីរភាព ព្រមទាំងការលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការផ្នែកថាមពល ។ ពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ និងការបណ្ដុះបណ្ដាល ។ លើការតភ្ជាប់ប្រជាជន បណ្ដាមេដឹកនាំអាស៊ាន ជប៉ុន បានប្ដេជ្ញាថានឹងបន្តពង្រឹងការជឿទុកចិត្តគ្នាទៅវិញទៅមក និងការយោគយល់គ្នាឱ្យអស់ពីបេះដូងនៅគ្រប់កម្រិត តាមរយៈជំរុញការផ្លាស់ប្ដូរប្រជាជន ជាពិសេសក្នុងវិស័យវប្បធម៌សិល្បៈ កីឡានិងទេសចរណ៍ ។ ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំរួមមានការបណ្ដុះបណ្ដាលភាសា ការផ្លាស់ប្ដូរចំណេះដឹង ការផ្លាស់ប្ដូរបញ្ញវ័ន្ត និងអ្នកស្រាវជ្រាវជាន់ខ្ពស់ ក្នុងចំណោមសកលវិទ្យាល័យ ។ រឹតចំណងសាមគ្គីភាពក្នុងចំណោមយុវជនអាស៊ាន និងជប៉ុនដូចជាការលើកកម្ពស់ការផ្លាស់ប្ដូរថ្នាក់ដឹកនាំយុវជន និងការបង្កើតបណ្ដាញសហគ្រិនវ័យក្មេង ។ ជាមួយគ្នានេះ មេដឹកនាំអាស៊ាន ជប៉ុន បានចេញនូវសេចក្ដីប្រកាសរួមនៃកិច្ចប្រជុំរំឭកខួបអនុស្សាវរីយ៍អាស៊ាន ជប៉ុន លើខ្លឹមសាររួមស្ដីពីការរួមគ្នាដោះស្រាយបញ្ហាប្រឈមតំបន់ និងពិភពលោក ដែលក្នុងនោះ មេដឹកនាំអាស៊ាន ជប៉ុនបានប្ដេជ្ញាបំពេញនូវតួនាទីកាន់តែសកម្មជាងមុន នៅក្នុងការថែរក្សាសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ និងនៅក្នុងពិភពលោក ។ ក្នុង ន័យនេះ មេដឹកនាំអាស៊ានបានស្វាគមន៍គោលនយោបាយ សន្តិសុខរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី **ស៊ិនហ្សូ អាបេ** ដែលសំដៅរួមចំណែកយ៉ាងសកម្មថែមទៀតដល់សន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ និងសហគមន៍អន្តរជាតិ ។

កិច្ចប្រជុំកំពូលមេគង្គ ជប៉ុន លើកទី ៥ បានប្រារព្ធធ្វើនៅរសៀលថ្ងៃទី ១៤ ធ្នូ នៅផ្ទះរដ្ឋ Geihinkan ក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន ។ នៅក្នុងកិច្ចប្រជុំនេះ បណ្ដាប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃប្រទេសមេគង្គ ជប៉ុន បានធ្វើការពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការមេគង្គជប៉ុន ក្នុងរយៈពេលពាក់កណ្ដាអាណត្តិរហូតមកដល់បច្ចុប្បន្ន ដោយឈរលើមូលដ្ឋានយុទ្ធសាស្ត្រក្រុងតូក្យូសម្រាប់កិច្ចសហប្រតិបត្តិការមេគង្គ ជប៉ុន ក្នុងការពិចារណាលើលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ ជប៉ុន លើកទី ៦ ដែលបានប្រព្រឹត្តទៅកាលពីខែមិថុនា ឆ្នាំ ២០១៣ និងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចមេគង្គ ជប៉ុន លើកទី ៤ ដែលបានប្រព្រឹត្តទៅកាលពីខែសីហា ឆ្នាំ ២០១៣ ។ បណ្ដាមេដឹកនាំទាំងអស់បានទទួលស្គាល់សាជាថ្មីលើសេចក្ដីព្រាងផែនការសកម្មភាពដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រទីក្រុងតូក្យូ ២០១២ ។ ជាមួយគ្នានេះ មេដឹកនាំទាំងអស់ក៏បានអះអាងសារជាថ្មីនូវការប្ដេជ្ញាចិត្ត ដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការឆ្ពោះទៅកាន់ឆ្នាំ២០១៥ ។ នៅក្នុងកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ ថ្នាក់ដឹកនាំនៃបណ្ដាប្រទេសមេគង្គបានស្វាគមន៍ចំពោះដំណើរទស្សនកិច្ចរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី **អាបេ** មកកាន់បណ្ដាប្រទេសមេគង្គក្នុងឆ្នាំ ២០១៣ នេះ ព្រមទាំងបានស្វាគមន៍ចំពោះការអនុវត្តន៍យ៉ាងខ្ជាប់ខ្ជួននៃជំនួយ ៦០០ ពាន់លានយ៉េនជប៉ុនក្នុងគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) សម្រាប់ឆ្នាំសារពើពន្ធ ២០១៣ ដែលបានសន្យាដោយភាគីជប៉ុននៅក្នុងកិច្ចប្រជុំកំពូលមេគង្គជប៉ុន លើកទី ៤ ដែលបានប្រព្រឹត្តទៅកាលពីឆ្នាំ ២០១២ ។ ជាមួយគ្នានេះបណ្ដាមេដឹកនាំទាំងអស់ បានធ្វើការវាយតម្លៃខ្ពស់លើសកម្មភាពការងាររវាងជប៉ុន និងថៃ ក្រោមកិច្ចសហប្រតិបត្តិការមេគង្គ ជប៉ុន និងបានស្វាគមន៍នូវការបន្តភាពជាដៃគូសម្រាប់សកម្មភាពថ្ងៃអនាគត ។ នៅក្នុងកិច្ចប្រជុំនោះដែរ ថ្នាក់ដឹកនាំជប៉ុនបានស្នើនូវសេចក្ដីព្រាងច្បាប់កែសម្រួលគម្រោងអាទិភាពរបស់ជប៉ុនចំនួន ៥៧ ដែលបានដាក់ជូនដោយភាគីជប៉ុននៅក្នុងកិច្ចប្រជុំកំពូលមេគង្គជប៉ុន លើកទី ៤ ។ បណ្ដាមេដឹកនាំនៃប្រទេសក្នុងតំបន់មេគង្គបានស្វាគមន៍ចំពោះការស្នើឡើងដោយភាគីជប៉ុន ។ លើការបង្កើនការតភ្ជាប់បណ្ដាអ្នកដឹកនាំទាំងអស់បានអះអាងសាជាថ្មីថា ការខិតខំប្រឹងប្រែងក្នុងការបង្កើតការតភ្ជាប់នៅក្នុងតំបន់មេគង្គ គឺមានសារៈសំខាន់ សម្រាប់បង្កើនការតភ្ជាប់នៅក្នុងអាស៊ានដើម្បីឆ្ពោះទៅកាន់ការបង្កើតសហគមន៍ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់ស្ថាប័នដើម្បីអភិវឌ្ឍរបៀងសេដ្ឋកិច្ចបូព៌ា បស្ចឹម និងរបៀងសេដ្ឋកិច្ចខាងត្បូង ដែលអនុវត្តដោយបណ្ដាប្រទេសមេគង្គ ហើយដែលបណ្ដាថ្នាក់ដឹកនាំបានថ្លែងនូវអំណរគុណចំពោះកិច្ចសហប្រតិបត្តិការរបស់ជប៉ុនក្នុងការអភិវឌ្ឍរបៀងទាំងនោះព្រមទាំងបានរំពឹងទុកថានឹងទទួលបានជំនួយក្នុងពេលអនាគតបន្តទៀត ។ ជាមួយគ្នានេះមេដឹកនាំទាំងអស់បានអះអាងសាជាថ្មីពីសារៈសំខាន់ក្នុងការបំពេញនូវកំណាត់ផ្លូវមិនទាន់ជួសជុលនៅតាមបណ្ដារបៀងសេដ្ឋកិច្ចសំខាន់ៗ ។ ទន្ទឹមនឹងនេះ បណ្ដាមេដឹកនាំទាំងអស់ក៏បានទទួលស្គាល់ផងដែរ នូវភាពចាំបាច់នៃការអភិវឌ្ឍតំបន់ជនបទគ្រប់ជ្រុងជ្រោយ ដែលស្ថិតនៅតាមរបៀងសេដ្ឋកិច្ចទាំងអស់នោះ ។ ជាមួយគ្នានេះ បណ្ដាអ្នកដឹកនាំនៃប្រទេសមេគង្គ បានធ្វើការកត់សម្គាល់ពីការរីកចម្រើននៃកិច្ចសហប្រតិបត្តិការពន្ធគយសម្រាប់សម្រួលដល់ការងារជំនួញ ពិសេស ថ្នាក់ដឹកនាំបានអះអាងសាជាថ្មីពីសារៈសំខាន់នៃការលើកកម្ពស់នូវគំនិតផ្ដួចផ្ដើមបណ្ដាញអាស៊ានឆ្លាត សម្រាប់



*មាតុភូមិនិវត្តន៍នៃគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ដឹកនាំដោយសម្ដេចតេជោ **ហ៊ុន សែន***

ដោះស្រាយបញ្ហាសង្គម រួមមានវិស័យបរិស្ថាន ដោយការបង្កើត និងប្រើប្រាស់នូវហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ។ លើការងារអភិវឌ្ឍរួមគ្នា បណ្តាថ្នាក់ដឹកនាំទាំងអស់បានស្វាគមន៍ចំពោះការបន្តផ្តល់ជំនួយសម្រាប់ការអភិវឌ្ឍន៍ដើម្បីការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការកសាងសមត្ថភាព រួមបញ្ចូលទាំងជំនួយសម្រាប់ធ្វើគោលនយោបាយឧស្សាហកម្មផង ។ ជាមួយគ្នានេះ បណ្តាមេដឹកនាំទាំងអស់បានចែករំលែកទស្សនៈថា ជប៉ុន និងបណ្តាប្រទេសមេគង្គនឹងខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរឡើងនូវបរិស្ថានវិនិយោគ ដើម្បីលើកកម្ពស់វិនិយោគបន្ថែមទៀតមកកាន់បណ្តាប្រទេសក្នុងតំបន់មេគង្គ តាមរយៈគណៈកម្មាធិការចម្រុះដោយឈរលើមូលដ្ឋាននៃកិច្ចព្រមព្រៀងវិនិយោគដែលមានស្រាប់ ។ ជាមួយនេះ មេដឹកនាំជប៉ុនបានប្រកាសថា ជប៉ុននឹងបន្តជំរុញការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការក្នុងវិស័យវិចិត្រសិល្បៈ វប្បធម៌ និងកីឡា ក៏ដូចជាការអប់រំភាសាជប៉ុន ដើម្បីពង្រឹងបន្ថែមទៀតនូវការយល់គ្នាទៅវិញទៅមក ។ បណ្តាថ្នាក់ដឹកនាំក្នុងប្រទេសមេគង្គបានស្វាគមន៍ចំពោះការបន្ធូរបន្ថយនូវលក្ខខណ្ឌក្នុងការស្នើសុំទិដ្ឋាការសម្រាប់បណ្តាប្រទេសតំបន់មេគង្គឆ្នាំ ២០១៣ នេះ ។ ពិសេស បានសម្រេចចិត្តថានឹងខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការលើកកម្ពស់ការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន ។ ជាមួយគ្នានេះ មេដឹកនាំទាំងអស់ក៏បានស្វាគមន៍ចំពោះការផ្លាស់ប្តូរយុវជនសកម្មរវាងជប៉ុននិងបណ្តាប្រទេសក្នុងតំបន់មេគង្គតាមរយៈកម្មវិធីផ្លាស់ប្តូរជាច្រើន ដូចជា បណ្តាញជប៉ុន អាស៊ីបូព៌ាសម្រាប់ការផ្លាស់ប្តូរនិស្សិត និងយុវជន ។ ជាមួយគ្នានេះ បណ្តាមេដឹកនាំទាំងអស់បានធ្វើការសម្រេចចិត្តក្នុងការលើកកម្ពស់គម្រោងភាពជាដៃគូនៃវិស័យសាធារណៈ និងឯកជន ឆ្ពោះទៅកាន់ការអភិវឌ្ឍរចនាសម្ព័ន្ធដ៏រឹងមាំមួយនៅក្នុងតំបន់ ។ ជាមួយគ្នានេះ មេដឹកនាំទាំងអស់បានឈានទៅដល់ការសម្រេចជាកុងសង់ស៊ីសដើម្បីធ្វើការជាមួយគ្នាឆ្ពោះទៅរកកិច្ចប្រជុំលើកទី ៣ នៃសន្និសីទអង្គការសហប្រជាជាតិស្តីពីការកាត់បន្ថយហានិភ័យក្នុងពិភពលោក ដែលបណ្តាលមកពីគ្រោះមហន្តរាយ ដែលនឹងប្រព្រឹត្តទៅនៅសែនដាយ ក្នុងខែមីនា ឆ្នាំ ២០១៥ ។ ជាមួយគ្នានេះមេដឹកនាំនៃបណ្តាប្រទេស បានស្វាគមន៍ចំពោះការប្រកាសរបស់ជប៉ុនក្នុងការអនុវត្តចំនួនទឹកប្រាក់ ៩១ ពាន់លានយ៉េន នៅក្នុងគម្រោងអភិវឌ្ឍន៍ផ្លូវការ (ODA) សម្រាប់ប្រទេសមីយ៉ាន់ម៉ាត្រឹមចុងឆ្នាំសារពើពន្ធ ២០១៣ ។ ជាមួយគ្នានេះមេដឹកនាំទាំងអស់បានធ្វើការអះអាងថា កិច្ចប្រជុំកំពូលមេគង្គជប៉ុនលើកទី ៦ នឹងប្រព្រឹត្តទៅក្នុងឱកាសនៃកិច្ចប្រជុំពហុភាគីក្នុង២០១៤តាមពេលវេលាសមស្របដែលកំណត់ដោយសហប្រធានមីយ៉ាន់ម៉ា និងជប៉ុន ។

នៅថ្ងៃទី ១៥ ខែធ្នូ សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ព្រមទាំងគណៈប្រតិភូ បានបំពេញទស្សនកិច្ចផ្លូវការ ២ថ្ងៃនៅព្រះរាជាណាចក្រជប៉ុន ។ ក្នុងកិច្ចពិភាក្សាការងារនោះ សម្តេចតេជោ **ហ៊ុន សែន** និងឯកឧត្តម **ស៊ិនហ្សូ អាបេ** នាយករដ្ឋមន្ត្រីជប៉ុន បានសម្តែងការពេញចិត្តយ៉ាងខ្លាំងចំពោះទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ ដែលមានអាយុកាល ៦០ ឆ្នាំមកហើយ ។ មេដឹកនាំទាំងពីរបានធ្វើការពិភាក្សាយ៉ាងយកចិត្តទុកដាក់ក្នុងការរិះរកវិធីសាស្ត្រនានាដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឱ្យឈានដល់ចំណុចកំពូលថ្មីមួយទៀត គឺភាពជាដៃគូយុទ្ធសាស្ត្រនៃទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយគ្នា ។ មេដឹកនាំនៃប្រទេសទាំងពីរបានធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើលិខិតប្តូរសារ និងអនុស្សរណៈសំខាន់ៗចំនួន ៤ គឺ ទី១ លិខិតប្តូរសារស្តីពីគម្រោងកែលម្អផ្លូវជាតិលេខ ១ ទី២ លិខិតប្តូរសារស្តីពីគម្រោងធ្វើឱ្យប្រសើរឡើងនូវមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ ទី៣ លិខិតប្តូរសារស្តីពីគម្រោងកែលម្អសម្ភារៈសម្រាប់ការជួសជុលស្ពានរហាលខាងលិចនៃប្រាសាទអង្គរវត្ត និងទី៤ អនុស្សារណស្តីពីការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការយោធារវាងក្រសួងការពារជាតិជប៉ុន និងក្រសួងការពារជាតិកម្ពុជា ។

នៅក្នុងសន្និសីទសារព័ត៌មាននៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបន្ទាប់ពីការធ្វើមាតុភូមិនិវត្តន៍ ឯកឧត្តម **កៅ គឹមហួន** រដ្ឋមន្ត្រីប្រតិភូអមសម្តេចនាយករដ្ឋមន្ត្រីបានថ្លែងថា សម្តេចតេជោនាយករដ្ឋមន្ត្រី និងឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុនបានឯកភាពគ្នាក្នុងការកំណត់ភាពដៃគូយុទ្ធសាស្ត្រ និងបានជំរុញការផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការលើវិស័យយោធារវាងប្រទេសទាំងពីរ ដែលកិច្ចសហប្រតិបត្តិការទាំងពីរនេះមិនធ្លាប់មានពីមុនមកទេ ។ ឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុនក៏បានឯកភាពតាមសំណើរបស់សម្តេចតេជោក្នុងការបញ្ជូនក្រុមការងារបច្ចេកទេសជប៉ុនមក ដើម្បីសិក្សាក្នុងការជួយកែទម្រង់ប្រព័ន្ធបោះឆ្នោត និងបានឯកភាពបន្តជួយតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមផងដែរ ។

ឯកឧត្តម **កៅ គឹមហួន** ថ្លែងថា រដ្ឋាភិបាលជប៉ុនក៏បានឯកភាពទៅដល់ការជួយបណ្តុះបណ្តាលកម្មករកម្ពុជា អាចធ្វើការងារផ្នែកផលិតកម្ម និងខាងធុរកិច្ចផងដែរ ដោយសារសព្វថ្ងៃនេះមានអ្នកវិនិយោគជប៉ុនជាច្រើនបាន និងកំពុងមកបណ្តាក់ទុនជាបន្តបន្ទាប់នៅកម្ពុជា ដែលបញ្ហានេះបានធ្វើឡើងតាមសំណើរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីក្នុងដំណើរទស្សនកិច្ចរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុនមកកាន់កម្ពុជាកាលពីខែវិច្ឆិកា ។ រដ្ឋាភិបាលទាំងពីរបានឯកភាពគ្នាលើការសម្រួលទិដ្ឋាការសម្រាប់ប្រជាពលរដ្ឋនៃប្រទេសទាំងពីរ ដើម្បីជំរុញធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋអាចធ្វើដំណើរទៅវិញទៅមកជាពិសេសទេសចរជប៉ុនអាចមកកាន់កម្ពុជាកាន់តែច្រើនឡើង ។

ចំពោះការហោះហើរវិញ រដ្ឋាភិបាលជប៉ុនបានឯកភាពនៅក្នុងការធ្វើការចរចាទៅលើអាកាសចរណ៍ស៊ីវិលនេះ ក្នុងទិសដៅឱ្យមានការហោះហើរត្រង់ពីប្រទេសជប៉ុនមកកាន់កម្ពុជានៅពេលខាងមុខនេះ ។ ពាក់ព័ន្ធនឹងការផ្លាស់ប្តូរឬការពិគ្រោះយោបល់នេះភាគីទាំងពីរមានយន្តការរួចហើយគឺកម្រិតឧត្តមមន្ត្រីដែលនឹងធ្វើការជាបន្តបន្ទាប់រវាងប្រទេសទាំងពីរ ដែលនឹងមានការប្រជុំជាឡើងទាត់ ។ សម្តេចតេជោបានស្នើធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋកម្ពុជាអាចទៅធ្វើការបាននៅប្រទេសជប៉ុន ដែលនេះជាសំណើមួយត្រូវបានភាគីជប៉ុនយកទៅពិចារណា ។

ក្នុងទស្សនកិច្ចការងារនេះ គណៈប្រតិភូជាន់ខ្ពស់កម្ពុជាក៏បានអញ្ជើញទៅកាន់ខេត្តក្យូតូ ។ សម្តេចតេជោ **ហ៊ុន សែន** បានជំរុញឱ្យខេត្តនេះចងសម្ព័ន្ធភាពជាមួយខេត្តសៀមរាប ដោយមានប្រសាសន៍ថា ខេត្តសៀមរាបក៏ជាអតីតរាជធានីរបស់កម្ពុជា រីឯខេត្តក្យូតូក៏ជាអតីតរាជធានីរបស់ជប៉ុន មិនតែប៉ុណ្ណោះខេត្តសៀមរាបមានបេតិកភណ្ឌពិភពលោក ហើយខេត្តក្យូតូក៏ជាខេត្តដែល មានបេតិកភណ្ឌដែរ ដូច្នេះខេត្តទាំងពីរគួរតែអាចចងសម្ព័ន្ធភាពជាមួយគ្នាបាន ។

សរុបមកដំណើរទស្សនកិច្ច និងការចូលរួមកិច្ចប្រជុំកំពូលនៅទីក្រុងតូក្យូរបស់សម្តេចតេជោ **ហ៊ុន សែន** ទទួលបានជោគជ័យយ៉ាងធំធេង ។/

# សម្ដេចតេជោ : ❖ គ្មានការបោះឆ្នោតឡើងវិញទេ ❖ រួមគ្នាការពារការពុកផុយនៃប្រាសាទ ❖ ផ្ដល់ឱកាសដល់ជនពិការដើម្បីសង្គមមួយសម្រាប់យើងទាំងអស់គ្នា



*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ថ្លែងសុន្ទរកថាក្នុងពិធីបើកសន្និសីទអន្តររដ្ឋាភិបាលលើកទី ៣ ស្ដីពីអង្គរសម្បត្តិបេតិកភណ្ឌពិភពលោក នៅខេត្តសៀមរាប*

នៅក្រោយកិច្ចប្រជុំរដ្ឋសភាកាលពីព្រឹកថ្ងៃសុក្រ ទី ២០ ខែធ្នូ ឆ្នាំ ២០១៣ សម្ដេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ជាលើកដំបូងទាក់ទងទៅនឹងការលើកឡើងរបស់គណបក្សប្រឆាំងដែលទាមទារឱ្យមានការបោះឆ្នោតឡើងវិញ ការទាមទារឱ្យសម្ដេចចុះចេញពីតំណែង និងការអះអាងពីគម្រោងធ្វើបាតុកម្មបិទផ្លូវក្នុងរាជធានីភ្នំពេញ ។

សម្ដេចបានបញ្ជាក់ថា នៅកម្ពុជាមានរដ្ឋធម្មនុញ្ញមួយបានកំណត់ហើយដែលខុសពីប្រទេសដទៃ។ ប្រទេសដទៃអនុញ្ញាតឱ្យនាយករដ្ឋមន្ត្រីប្រកាសរំលាយសភា ប៉ុន្តែនៅប្រទេសកម្ពុជា មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញបានកំណត់ថា "សភាមាននីតិកាល ៥ ឆ្នាំ សភាមិនអាចរំលាយមុនអាណត្តិបានទេ លើកលែងតែរាជរដ្ឋាភិបាលត្រូវរំលាយពីរដងក្នុងរយៈពេល ១២ ខែ" ។ ដូច្នេះ នៅទីនេះនាយករដ្ឋមន្ត្រីក៏គ្មានសិទ្ធិរំលាយសភា ព្រះមហាក្សត្រក៏គ្មានសិទ្ធិរំលាយសភា ហើយសភាខ្លួនឯងក៏គ្មានសិទ្ធិរំលាយសភា ។ ដូច្នេះតើនរណាមួយមានសិទ្ធិរំលាយសភា ដើម្បីធ្វើការបោះឆ្នោតឡើងវិញ? ។

សម្ដេចបានបន្តថា "ដូច្នេះសូមអ្នកទាមទារទាំងឡាយមើលច្បាប់ឱ្យបានច្បាស់ ។ មួយទៀត ទាមទារឱ្យខ្ញុំចុះចេញពីតំណែង ។ តើខ្ញុំបានធ្វើកំហុសអ្វី? បើសិនជាសភាទម្លាក់ខ្ញុំនោះវាជារឿងមួយ ។ ក៏ប៉ុន្តែការចុះចេញពីតំណែងរបស់ខ្ញុំមិនមែនជាការចង់បានរបស់អ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា និងគាំទ្រខ្ញុំនោះទេ ។ ពិតណាស់ អ្នកដែលមិនបានគាំទ្រខ្ញុំ មិនមែនទើបតែថ្ងៃនេះទេ តាំងពីជំនាន់ក្រោយពីរំដោះពីប៉ុលពតភ្លាម ក៏គេចង់ឱ្យខ្ញុំចាកចេញពីតំណែងរួចទៅហើយ ។ អ៊ីចឹងខ្ញុំគ្មានការភ្ញាក់ផ្អើលចំពោះការទាមទារ ហើយក៏ខ្ញុំដឹងដែរថានរណាអ្នកឱ្យសរសេរអំពី "**ហ៊ុន សែន** អើយ ចាកចេញទៅ!" នោះ មិនមែនអ្នកធ្វើបាតុកម្មធម្មតាទេ ក៏ប៉ុន្តែគឺជាមេដឹកនាំនយោបាយ" ។

សម្ដេចបានគូសបញ្ជាក់ថា "ខ្ញុំឡើងតាមរដ្ឋធម្មនុញ្ញ ខ្ញុំចុះក៏ចុះតាមរដ្ឋធម្មនុញ្ញ" ។ អ៊ីចឹងសូមបញ្ជាក់ឱ្យហើយ គ្មានការបោះឆ្នោតឡើងវិញទេ ព្រោះគ្មានអ្នករំលាយសភាហើយ ក៏គ្មានយន្តការណាកំណត់អំពីការបោះឆ្នោតមុនអាណត្តិនោះទេ ហើយក្រៅពីការចែងនៅក្នុងរដ្ឋធម្មនុញ្ញក៏មានការចែងនៅក្នុងច្បាប់បោះឆ្នោត ។ ច្បាប់បោះឆ្នោតចងជាប់ជាចំណងតែម្ដង គឺនៅរៀងរាល់ថ្ងៃអាទិត្យ រៀងរាល់ ៥ ឆ្នាំម្ដងនៅថ្ងៃអាទិត្យនាសប្ដាហ៍ទី៤នៅខែកក្កដា ត្រូវធ្វើការបោះឆ្នោត ។ ដូច្នេះរដ្ឋធម្មនុញ្ញបានចងគឺមិនឱ្យមាននរណារំលាយសភា សភាខ្លួនឯងក៏មិនអាចមានសិទ្ធិរំលាយសភាដែរ លើកលែងតែបើសភាចង់រំលាយខ្លួនឯង គឺសភាត្រូវរំលាយរាជរដ្ឋាភិបាលពីរដងក្នុងរយៈពេល ១២ ខែ។ អ៊ីចឹងចំណុចនេះសូមអ្នកតវ៉ាមើលឱ្យច្បាស់ គ្មាននរណាមានសិទ្ធិទាំងអស់" ។

អំពីបាតុកម្មរបស់គណបក្សសង្គ្រោះជាតិដែលបានព្រមានថា ខ្លួននឹងធ្វើបាតុកម្មបិទផ្លូវនោះ ត្រូវបាន សម្ដេចនាយករដ្ឋមន្ត្រីព្រមានទៅវិញថា រដ្ឋាភិបាលនឹងចាត់វិធានការតាមផ្លូវច្បាប់ ។

សម្ដេចបានបញ្ជាក់ថា "ឥឡូវនិយាយដល់រឿងបាតុកម្មបិទផ្លូវ ។ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា បិទផ្លូវ តើប៉ះពាល់ដល់អ្វី? មិនមែនប៉ះពាល់ត្រឹមរាជរដ្ឋាភិបាល ត្រឹមស្ថាប័នរបស់រដ្ឋមួយចំនួនទេ គឺប៉ះពាល់ដល់ប្រជាជន ។ ជាទង្វើខុសច្បាប់ ។ ខ្ញុំសូមស្នើរាជរដ្ឋាភិបាលនឹងត្រូវឆ្លើយតបតាមវិធានការផ្លូវច្បាប់ហើយ ។ វាគ្មានជម្រើសណាផ្សេងក្រៅពីនោះទេ ។ សូមប្រជាពលរដ្ឋជៀសឱ្យឆ្ងាយអំពីទង្វើអំពាវនាវឱ្យមានការបិទផ្លូវ ។ បិទផ្លូវ គឺជាការបិទឈាមខ្លួនឯង!" ។

ជាមួយនឹងការគូសបញ្ជាក់ខាងលើសម្ដេចក៏បានបន្ថែមថារាជរដ្ឋា-



*ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ អញ្ជើញចូលរួមក្នុងសន្និសីទអន្តររដ្ឋាភិបាលលើកទី ៣ ស្ដីពីអង្គរសម្បត្តិបេតិកភណ្ឌពិភពលោក*

ភិបាលមានការអត់ធ្មត់គោរពសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែរាជរដ្ឋាភិបាលនឹងមិនយល់ព្រមណាមួយ អំពីបញ្ហាទាក់ទិនជាមួយនឹងការដែលជាទង្វើខុសច្បាប់ បង្កអស្ថិរភាពសម្រាប់ប្រជាពលរដ្ឋនោះទេ។

សម្តេចតេជោបានសង្កត់ធ្ងន់ថា "យើងមិនអាចទទួលយកបានលើទង្វើណាក៏ដោយដែលពាក់ព័ន្ធទៅនឹងការបំផ្លាញលើសន្តិសុខរបស់ជាតិ ហើយខ្ញុំសូមស្នើឱ្យមានការប្រុងប្រយ័ត្នចំពោះបាតដៃទី ៣ "។

នៅក្នុងខែធ្នូនេះដែរ សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកម្មវិធីសំខាន់ៗមួយចំនួន ជាអាទិ៍ :

-កាលពីថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៣ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីបើកសន្និសីទអន្តររដ្ឋាភិបាលលើកទី ៣ ស្តីពីអង្គរសម្បត្តិបេតិកភណ្ឌពិភពលោក ដែលបានរៀបចំធ្វើនៅសណ្ឋាគារសុខាអង្គរ ខេត្តសៀមរាប។ ពិធីនេះក៏មានការអញ្ជើញចូលរួមពីសំណាក់លោកជំទាវ **អូរេលីហ្វី លីប៉េតទី** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងគមនាគមន៍នៃសាធារណរដ្ឋបារាំង និងលោក **យ៉ាស៊ូម៉ា សាណាហ្គាមីណេ** អនុរដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសជប៉ុន ព្រមទាំងភ្ញៀវជាតិ និងប្រតិភូអន្តរជាតិជាច្រើនរូប។

មានប្រសាសន៍ក្នុងពិធីនេះ សម្តេចតេជោបានវាយតម្លៃខ្ពស់ចំពោះសន្និសីទអន្តររដ្ឋាភិបាលលើកទី ៣ ស្តីពីអង្គរ និងស្វាគមន៍ចំពោះគណៈប្រតិភូទាំងអស់ដែលបានអញ្ជើញចូលរួម ដោយបានចាត់ទុកថា វត្តមាននេះនឹងជួយបន្តពង្រឹងបន្ថែមទៀតដល់សាមគ្គីភាព និងការប្តេជ្ញាចិត្តបំពេញការងាររួមគ្នាក្នុងចំណោមប្រទេសនានាដើម្បីសម្រេចឱ្យបាននូវគោលដៅរួមនៃការរក្សាការពារបេតិកភណ្ឌមនុស្សជាតិគឺអង្គរ។ សម្តេចបានបញ្ជាក់ថា អ្វីដែលយើងបានប្រឹងប្រែងរួមគ្នាកន្លងមកនេះគឺក្នុងគោលដៅជួយសង្គ្រោះអង្គរ ហើយអ្វីដែលនឹងកើតមកជាមួយនោះ គឺការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្នុងទិសដៅធានាសម្រេចឱ្យបាននូវគោលដៅដ៏ពិសិដ្ឋនេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តពង្រឹង និងពង្រីកសមិទ្ធផលនានាដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងមកតាមរយៈការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់សង្គម។

សម្តេចតេជោបន្តថា សម្បត្តិវប្បធម៌ខ្មែរគឺជាដួងព្រលឹងរបស់កម្ពុជា ។ ជាក់ស្តែងអង្គរ គឺជានិមិត្តរូបជាតិ ដោយប្រាង្គប្រាសាទអង្គរវត្តដ៏ល្បីល្បាញត្រូវបានផ្តិតនៅលើទង់ជាតិរបស់កម្ពុជា ។ កម្ពុជា ជាប្រទេសតែមួយគត់នៅក្នុងពិភពលោកដែលមានអង្គរជាបេតិភណ្ឌជាតិផង និងជាបេតិកភណ្ឌពិភពលោកផង ហើយបានស្ថិតនៅលើទង់ជាតិរបស់ខ្លួន។ ដូច្នេះយុទ្ធនាការអង្គរមិនត្រឹមតែជាការអភិវឌ្ឍ និងអភិរក្សបេតិកភណ្ឌវប្បធម៌ប៉ុណ្ណោះទេប៉ុន្តែជាការរួមចំណែកយ៉ាងពិតប្រាកដ ក្នុងការខិតខំសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍកម្ពុជាទៀត



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អញ្ជើញជាអធិបតីក្នុងទិវាជនពិការកម្ពុជាលើកទី ១៥ និងជនពិការអន្តរជាតិលើកទី ៣១*

ផង។ សម្តេចបានអំពាវនាវដល់គណៈប្រតិភូដែលតំណាងឱ្យសហគមន៍អន្តរជាតិទាំងអស់ដែលមានវត្តមាននៅក្នុងសន្និសីទនេះ សូមបន្តការប្តេជ្ញាចិត្តរបស់ខ្លួនសាជាថ្មីបន្ថែមទៀត សម្រាប់សកម្មភាពការងារនៃទសវត្សថ្មីក្នុងការការពារនិងអភិរក្សរមណីយដ្ឋានអង្គរដោយរួមជាមួយអាជ្ញាធរជាតិអប្សរា។ ក្នុងនោះ ចាំបាច់ត្រូវគិតគូររួមគ្នាអំពីវិធីសាស្ត្រនិងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗបន្ថែមទៀតដើម្បីធានាឱ្យការគ្រប់គ្រងរមណីយដ្ឋានបេតកភណ្ឌពិភពលោក ត្រូវបានអនុវត្តទៅតាមក្រមសីលធម៌ និងប្រតិបត្តិស្តីពីការអភិរក្ស និងការអភិវឌ្ឍ ដូចដែលបានកំណត់នៅក្នុង ( ធម្មនុញ្ញអង្គរ) ។

សម្តេចបន្តថា ទីក្រុងសៀមរាបជាទីក្រុងដែលបង្កប់ទៅដោយរតនសម្បត្តិមិនអាចកាត់ថ្លៃបាន ជាមួយនឹងសំណង់អគារប្រកបដោយរចនាបថស្ថាបត្យកម្មបុរាណ វត្តអារាមប្រវត្តិសាស្ត្រ និងប្រព័ន្ធជលសាស្ត្របុរាណដ៏មានប្រសិទ្ធភាពនៅក្នុងបរិវេណនៃប្រពន្ធ័បេតិកភណ្ឌដ៏ប្រពៃរុងរឿងនេះ។ ក្នុងន័យនេះ សម្តេចយល់ថា មានសមាសធាតុសំខាន់និងមិនអាចផ្តាច់ចេញពីគ្នាបានចំនួនបួនដែលបង្កើតបានជាទេសភាពអង្គរនោះគឺ ប្រាសាទ ទឹក ព្រៃឈើ និងប្រជាជន។ ចំពោះមុខគឺយើងត្រូវរួមគ្នាគិតគូរ និងយកចិត្តទុកដាក់ខ្ពស់ចំពោះសមាសធាតុទាំងអស់នេះ។ សម្តេចបានស្នើឱ្យអាជ្ញាធរជាតិអប្សរា និងអ្នកជំនាញវ័យក្មេងកម្ពុជាព្រមទាំងភាគីពាក់ពន្ធ័ទាំងអស់ រួមគ្នាប្រយុទ្ធប្រឆាំងនឹងការពុកផុយថ្មប្រាសាទ និងការខូចខាតរូបចម្លាក់ដែលអាចបង្កឡើងដោយការបំពុលបរិយាកាស។

សម្តេចបានបន្ថែមទៀតថា ទោះបីជាមានការព្រួយបារម្ភអំពីហានិភ័យនានាចំពោះរមណីយដ្ឋាន និងប្រាង្គប្រាសាទ ដែលបណ្តាលមកពីចំនួនភ្ញៀវទេសចរមកទស្សនាច្រើនលើសលប់ក៏ដោយ ក៏យើងគប្បីមានការប្រុងប្រយ័ត្នដោយមិនត្រូវយល់ក្នុងន័យអវិជ្ជមានណាមួយចំពោះកំណើនខ្ពស់នៃចំនួនភ្ញៀវទេសចរណ៍នោះឡើយ។ រមណីយដ្ឋានអង្គរមានផ្ទៃក្រឡាសរុបរហូតដល់ ៤ ម៉ឺនហិកតា ហើយប្រាង្គប្រាសាទដែលភ្ញៀវមកទស្សនាមានចំនួនយ៉ាងច្រើន។ ដូច្នេះបញ្ហាសំខាន់ស្ថិតនៅត្រង់ថា តើត្រូវធ្វើយ៉ាងណាដើម្បីគ្រប់គ្រងបែងចែក






*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជួបសំណេះសំណាលជាមួយជនពិការ និងអញ្ជើញពិនិត្យផលិតផលនានាដែលផលិតដោយជនពិការ*

លំហូរភ្ញៀវ និងរៀបចំទីកន្លែងឱ្យភ្ញៀវបានមកទស្សនារមណីយដ្ឋាននេះប្រកបដោយរបៀបរៀបរយ ។

គួររំឭកថា សន្និសីទអន្តររដ្ឋាភិបាលលើកទី ១ ស្តីពីអង្គរបានប្រព្រឹត្តទៅកាលពីខែតុលា ឆ្នាំ ១៩៩៣ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។ សន្និ-សីទលើកទី ២ នាខែវិច្ឆិកា ឆ្នាំ ២០០៣ នៅទីក្រុងប៉ារីស ប្រទេសបារាំង ។

-ថ្ងៃទី ១០ ខែធ្នូ សម្តេចតេជា **ហ៊ុន សែន** បានអញ្ជើញចូលរួមក្នុងទិវាជនពិការកម្ពុជាលើកទី ១៥ និងជនពិការអន្តរជាតិលើកទី ៣១ ក្រោមប្រធានបទ "លុបបំបាត់ឧបសគ្គនានា និងផ្តល់ឱកាសដល់ជនពិការ ដើម្បីសង្គមមួយសម្រាប់យើងទាំងអស់គ្នា" ដែលបានប្រារព្ធនៅសាលមហោស្រពកោះពេជ្រ ។

មានប្រសាសន៍ក្នុងឱកាសនោះសម្តេចតេជោ បានបង្ហាញពីបំណងនៃការដាក់បញ្ចូលគ្រូបង្រៀននៅតាមអង្គការនានាចូលទៅក្នុងក្របខណ្ឌរដ្ឋ ។ ធ្វើបែបនេះ គឺក្នុងគោលបំណងឱ្យពួកគេទទួលបានប្រាក់ខែពីរដ្ឋផង និងបានទទួលប្រាក់ឧបត្ថម្ភពីអង្គការផង ។ សម្តេចបន្តថា ឆ្នាំ ២០១៤ រាជរដ្ឋាភិបាលបានសម្រេចឱ្យជ្រើសរើសគ្រូបង្រៀនក្របខណ្ឌរដ្ឋចំនួន ៦ ០០០ នាក់ ដែលឆ្នាំមុនៗជ្រើសរើសតែ ៥ ០០០ នាក់ប៉ុណ្ណោះ ហើយនៅឆ្នាំ២០១៥ចំនួន៧០០០នាក់ ។ដូចនេះយើងអាចបញ្ចូលគ្រូៗដែលស្ថិតនៅតាមអង្គការនានាទូទាំងប្រទេស ឱ្យចូលជាក្របខណ្ឌគ្រូតែម្តងមិនអាចបញ្ចូលអង្គការមួយហើយអង្គការមួយទៀតមិនបញ្ចូលនោះទេ ។

សម្តេចនាយករដ្ឋមន្ត្រីក៏បានស្នើឱ្យក្រសួងអប់រំ យុវជន និងកីឡា រៀបចំចងក្រងនូវឯកសារអក្សរស្ទាបសម្រាប់ជនពិការ ដែលអង្គការគ្រួសារថ្មីបានបង្កើតឡើងសម្រាប់បង្រៀនកុមារពិការភ្នែក ដើម្បីឱ្យឯកសារនេះត្រូវបានបោះពុម្ព និងមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា និងត្រូវធ្វើឯកភាពរូបនីយកម្មនៃសញ្ញាភាសា "គ" រួចហើយរៀបចំឱ្យទៅជាសញ្ញារួម ។ ការធ្វើបែបនេះនឹងជួយធ្វើឱ្យជនពិការ គ ថ្លង់ អាចធ្វើការទំនាក់ទំនងជាមួយអ្នកមិនពិការបាន និងអ្នកមិនពិការក៏អាចទំនាក់ទំនងជាមួយអ្នកពិការបានទូលំទូលាយផងដែរ ។

ក្នុងវេទិកានេះ សម្តេចប្រមុខរាជរដ្ឋាភិបាលក៏បានអំពាវនាវឱ្យបញ្ចប់រាល់ការមាក់ងាយចំពោះជនពិការ ទូទៅនិងបានជំរុញឱ្យក្រសួងស្ថាប័ន ទាំងរដ្ឋ និងឯកជនត្រូវតែជ្រើសរើសយកជនពិការចូលបម្រើការងារតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលដែលបានកំណត់ គឺស្ថាប័នរដ្ឋឱ្យបាន ២% និងស្ថាប័នឯកជនឱ្យបាន ១ % ក្នុងរយៈពេល ៣ ឆ្នាំ ។ ស្ថាប័នរដ្ឋត្រូវតែធ្វើមុនឯកជន ។

សម្តេចក៏បានជំរុញឱ្យមានការគិតគូច្រើនថែមទៀតដល់ការរៀបចំមធ្យោបាយ ការបង្កលក្ខណៈងាយស្រួល សម្រាប់ជនពិការចេញចូលតាមទីកន្លែងសាធារណៈរបស់រដ្ឋ និងឯកជន ទាំងមធ្យោបាយដឹកជញ្ជូន កន្លែង ធ្វើការ ផ្លូវថ្នល់ កន្លែងលំហែកាយ គ្រឹះស្ថានអប់រំ សណ្ឋា-គារ មន្ទីរពេទ្យ ។ល។ ត្រូវគិតគូរអំពីលទ្ធភាព ដើម្បីឱ្យជនពិការភ្នែក និងជនពិការ គ ថ្លង់ អាចទំនាក់ទំនងនឹងព័ត៌មាននានានៅក្នុងសង្គម ព្រមទាំងទទួលបានការអប់រំ និងបណ្តុះបណ្តាលមុខជំនាញ ។ ត្រូវធ្វើការផ្សព្វផ្សាយភាសាសញ្ញាតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ព្រមទាំងពង្រីកលទ្ធភាពប្រើប្រាស់បច្ចេកទេសព័ត៌មានវិទ្យាដល់ជនពិការ ។ ត្រូវគោរព និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការដែលជាច្បាប់សំខាន់ សំដៅការពារសិទ្ធិសេរីភាព និងផលប្រយោជន៍ជនពិការ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ និងស្តារលទ្ធភាពពលកម្ម កាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីធានាលទ្ធភាពនៃការចូលរួមដ៏ពេញលេញ និងស្មើភាពរបស់ជនពិការក្នុងសកម្មភាពនានារបស់សង្គម ។

គួរបញ្ជាក់ថា យោងតាមជំរឿនទូទៅប្រជារាស្ត្រឆ្នាំ ២០០៨ ប្រទេសកម្ពុជាមានជនពិការចំនួន ១៩២ ៥៣៨ នាក់ ស្មើនឹង ១,៤៤% នៃចំនួនប្រជាជនសរុប ក្នុងនោះបុរស ៥៦,៣% និងស្ត្រីមាន ៤៣,៧% ។ កុមារពិការមានអាយុដល់ ១៨ ឆ្នាំមាន ១៧,៧២% ។ ជនពិការដោយសារមីនមានចំនួន ៦៤ ២២៤ នាក់ ស្មើនឹង ៣៣,៣៦ % ។/

# បុណ្យសមុទ្រនៅខេត្តកែប និងកិច្ចប្រជុំអន្តរជាតិនៅរមណីយដ្ឋានឋានសួគ៌បូកគោ បង្ហាញនូវជំហានដ៏រឹងមាំនៃវិស័យទេសចរណ៍កម្ពុជា



សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ពិនិត្យពិព័រណ៍ផលិតផលនានា

ព្រះរាជាណាចក្រកម្ពុជា បានបំពេញតួនាទីជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍អន្តរជាតិជាប្រវត្តិសាស្ត្រមួយប្រកបដោយជោគជ័យនាដើមខែធ្នូឆ្នាំ ២០១៣ កន្លងទៅ នៅលើទឹកដីខេត្តកំពត និងខេត្តកែប ដែលជាតំបន់ទេសចរណ៍ វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិមួយនៃកម្ពុជា។ ខេត្តទាំងពីរស្ថិតក្នុងចំណោមខេត្តចំនួនបួនដែលមានឆ្នេរសមុទ្រ និងត្រូវបានប្រសិទ្ធនាមថាជា " តារារះនាទិសនិរតី "។

រយៈពេល ៤ ថ្ងៃ ចាប់ពីថ្ងៃទី ៥ ដល់ថ្ងៃទី ៨ ខែធ្នូ មានព្រឹត្តិការណ៍ធំៗសំខាន់ចំនួន៤ត្រូវបានប្រារព្ធធ្វើនៅរមណីយដ្ឋានឋានសួគ៌បូកគោនៃខេត្តកំពត និងរមណីយដ្ឋានខេត្តកែប ។ព្រឹត្តិការណ៍ទាំងនោះគឺ ១.មហាសន្និបាតលើកទី៩ នៃក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើពិភពលោក ២.កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី ២ ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យទេសចរណ៍ និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាមលើកទី ២ , ៣.កិច្ចប្រជុំលើកទី ៣២នៃក្រុមការងារទេសចរណ៍នៃមហាអនុតំបន់មេគង្គ និង៤. គឺការរៀបចំបុណ្យសមុទ្រ ។ពិធីនេះមានការអញ្ជើញចូលរួមដ៏ខ្ពង់ខ្ពស់ពីសំណាក់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លោក**ហ្គាលីប ហ្គរ**(Galip Gur) ប្រធានក្លឹបឆ្នេរសមុទ្រស្អាតបំផុតលើពិភពលោក គណៈប្រតិភូឆ្នេរចំនួន ២៩ ឆ្នេរ មកពី ១៨ ប្រទេស សរុបជាង ១០០ នាក់ គណៈប្រតិភូរដ្ឋមន្ត្រីទេសចរណ៍នៃប្រទេសឡាវ-មីយ៉ាន់ម៉ា និងវៀតណាម ព្រមទាំងប្រតិភូអមដំណើរជាច្រើនរូប ។

ថ្ងៃទី ៥ ធ្នូ នារសៀលថ្ងៃដំបូងនៃកម្មវិធី គណៈប្រតិភូទាំងអស់បានចូលរួមទស្សនាដោយក្ដីរំភើបរីករាយនូវការប្រណាំងទូកនៅបឹងធម្មជាតិនៃរមណីយដ្ឋានឋានសួគ៌បូកគោ ។ទូកដែលប្រណាំងនៅពេលនោះមានចំនួន ១២ គូ ក្នុងនោះទូកកានូទេសចរណ៍ចំនួន ២ គូ ទូក កាយ៉ាក់ចំនួន ៤ គូ ទូកប្រពៃណីចំនួន ២ គូ ទូកកានូ ៤ គូ។ ជាមួយនឹងអាកាសធាតុត្រជាក់ស្រិប ក្រៅពីការទស្សនានូវទស្សនីយភាពនៅលើផ្ទៃបឹងធម្មជាតិដ៏ល្វឹងល្វើយ ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់អាចគយគន់នូវទេសភាពដ៏ស្រស់ត្រកាលនៃរមណីយដ្ឋានធម្មជាតិភ្នំបូកគោទាំងមូល ។ គណៈប្រតិភូត្រូវបានរៀបចំទៅទស្សនានូវតំបន់ទេសចរណ៍សំខាន់ៗនៅទីនោះ ។

ថ្ងៃទី ៦ ខែធ្នូ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បាន អញ្ជើញចូលរួមបើកមហាសន្និបាតលើកទី ៩ នៃក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើពិភពលោក កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី ២ ( រដ្ឋមន្ត្រីទេសចរណ៍)( CLMV ) និងកិច្ចប្រជុំក្រុមការងារមហាអនុតំបន់មេគង្គលើកទី ៣២ ( ក្រុមការងារ GMS ) នាសណ្ឋាគារឋានសួគ៌បូកគោ ។ មហាសន្និបាតលើកទី ៩ នៃក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើពិភពលោកលើកនេះមានប្រធានបទ "សមុទ្រខៀវស្រងាត់ ទីក្រុងបៃតង" ។

មានប្រសាសន៍ក្នុងពិធីនោះ សម្ដេចតេជោបានថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាភិបាល និងសមាជិកនៃក្លឹបឆ្នេរសមុទ្រស្អាតបំផុតលើពិភពលោក ដែលបានគាំទ្រឆ្នេរសមុទ្រកម្ពុជា និងបានយល់ព្រមដាក់បញ្ចូលឆ្នេរសមុទ្រកម្ពុជាទាំងមូលជាសមាជិកពេញសិទ្ធិរបស់ក្លឹប ។ការចូលជាសមាជិកក្លឹបនេះ បានស្ដែងឱ្យឃើញពីរបត់ថ្មីនៃការប្រែប្រួលមុខមាត់ជាបន្តបន្ទាប់របស់តំបន់សមុទ្រកម្ពុជាទាំងលើទិដ្ឋភាពសង្គម សេដ្ឋកិច្ច ទេសចរណ៍ នគរូបនីយកម្ម និងបរិស្ថាន ដែលជាកត្តាកំណត់ទទួលស្គាល់ជាអន្តរជាតិនៃឆ្នេរសមុទ្រកម្ពុជាទាំងមូលប្រវែង ៤៤០ គីឡូម៉ែត្រ គ្របដណ្ដប់លើខេត្តទាំងបួនរបស់កម្ពុជារួមមាន : ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប ក្រោមឈ្មោះរួមមួយថា "ឆ្នេរសមុទ្រកម្ពុជា" ។សម្ដេចបានបន្តទៀតថា ប្រការនេះបានធ្វើឱ្យតំបន់ឆ្នេរកម្ពុជាបាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ ជាប៉ូលសេដ្ឋកិច្ចទី ២ ក្នុងការទាក់ទាញវិនិយោគសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិបន្ទាប់ពីរាជធានីភ្នំពេញ ។សម្ដេចបានបញ្ជាក់ថារាជរដ្ឋាភិបាលក្នុងអាណត្តិថ្មីនេះនឹងខិតខំប្រឹងប្រែងលើកិច្ចការ




កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី ២ ( រដ្ឋមន្ត្រីទេសចរណ៍)( CLMV ) និងកិច្ចប្រជុំក្រុមការងារមហាអនុតំបន់មេគង្គលើកទី ៣២ ( ក្រុមការងារ GMS )



*ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំអន្តរជាតិ នៅសណ្ឋាគារឋានសួគ៌បូកគោ*

ពារ និងអភិរក្សបរិស្ថាន និងធនធានធម្មជាតិដោយឈរលើគោលការណ៍"ការអភិវឌ្ឍបម្រើឱ្យការអភិរក្ស រីឯការអភិរក្សបម្រើឱ្យការអភិវឌ្ឍ"។ សម្តេចសូមគាំទ្រការពិភាក្សាលើប្រធានបទនៃមហាសន្និបាតលើកទី ៩ ស្តីពី "សមុទ្រខៀវស្រងាត់ ទីក្រុងបៃតង"។

ដោយឡែកទាក់ទងទៅនឹងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ CLMV និងកិច្ចប្រជុំក្រុមការងារ GMS សម្តេចតេជោបានលើកឡើងថា សម្តេចសូមស្នើឱ្យមានការពិភាក្សាទាំងក្នុងក្របខណ្ឌកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម (CLMV) និងក្របខណ្ឌអនុតំបន់មេគង្គ (GMS) ឱ្យមានការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរតំបន់លើការតភ្ជាប់ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ការសម្រួលការធ្វើដំណើរ ការអភិវឌ្ឍផលិតផលទេសចរណ៍ឆ្នេរសមុទ្ររួមគ្នា។ ក្នុងក្របខណ្ឌតំបន់នេះដែរ សម្តេចសូមឱ្យមានការគិតគូរលើការបង្កើតផលិតផលទេសចរណ៍រួមគ្នាពង្រឹងគុណភាព និងលើកកម្ពស់សេវាទេសចរណ៍រួមគ្នា ព្រមទាំងជំរុញការតភ្ជាប់ច្រករបៀងខាងត្បូង ដែលតភ្ជាប់គោលដៅទេសចរណ៍សំខាន់នៅភាគអាគ្នេយ៍ប្រទេសថៃ ភាគនិរតីប្រទេសកម្ពុជា និងភាគខាងត្បូងប្រទេសវៀតណាម តាមរយៈផ្លូវអាស៊ានហាយវ៉េលេខ ១២៣ និងការតភ្ជាប់ជាមួយបណ្តាប្រទេសអាស៊ាននានាតាមរយៈនាវាចរណ៍អាស៊ាន។ ក្នុងស្មារតីនេះសម្តេចសូមស្នើឱ្យរដ្ឋមន្ត្រីទេសចរណ៍ CLMV ពិភាក្សាលើការសម្រួលបែបបទ និងនីតិវិធីឆ្លងកាត់ ជាពិសេសសម្រាប់ភ្ញៀវទេសចរដែលឆ្លងកាត់ពីគោលដៅជិតខាងក្នុងតំបន់ឆ្នេរសមុទ្រ នៃប្រទេសទាំងបី (កម្ពុជា-ថៃ-វៀតណាម) ឱ្យទៅជាតំបន់ទេសចរណ៍ពិសេសសម្រាប់ ៣ ប្រទេស។

ដោយឡែកទាក់ទងកម្ពុជាវិញ សម្តេចនាយករដ្ឋមន្ត្រីបានទាញការចាប់អារម្មណ៍ថា"ការពង្រឹងភាពជាដៃគូគឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍក្នុងយុគសម័យបច្ចុប្បន្ន"។ដូច្នេះក្រសួងទេសចរណ៍ គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា ត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាបង្កើតឡើងនូវវេទិការួមអចិន្ត្រៃយ៍មួយ ដោយយកគំរូនៃវេទិកា ICC-អង្គរ សម្រាប់តំបន់ឆ្នេរ ដោយឈរលើគោលការណ៍ ៤ P (Public-People-Private-Partnership)ដែលជាវេទិការួមមួយដើម្បីផ្តល់លទ្ធភាពប្រមូលផ្តុំគ្រប់ភាគីពាក់ព័ន្ធអាច "រួមគិត រួមធ្វើ រួមទទួលខុសត្រូវ" ទាំង អស់គ្នាដោយពិភាក្សាផ្តល់យោបល់ និងរួមគ្នាអភិវឌ្ឍន៍ទេសចរណ៍ ក៏ដូចជាការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាឱ្យមានចីរភាព។ សម្តេចបានបន្តថា ក្នុងស្មារតីនេះ សម្តេចសូមឱ្យវិស័យឯកជន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានាសូមចូលរួមជាមួយរដ្ឋាភិបាល ដើម្បីបង្កើតនិងអភិវឌ្ឍផលិតផលទេសចរណ៍រួមគ្នាបង្កើតនូវខ្សែទស្សនកិច្ចរួមគ្នា និងការអភិវឌ្ឍទេសចរណ៍តាមនាវារួមគ្នាជាដើម ។ ត្រូវសិក្សារៀបចំឱ្យមានយន្តការអភិវឌ្ឍន៍គោលដៅទេសចរណ៍តំបន់ឆ្នេររួមគ្នា ដោយឈរលើភាពជាដៃគូរវាងរដ្ឋ និងឯកជន ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗរួមគ្នា ការពង្រឹង និងលើកកម្ពស់គុណភាពសេវារួមគ្នាក្នុងបុព្វហេតុធ្វើឱ្យឆ្នេរស្អាត ស័ក្តិសមនឹងកិត្តិនាម "ឆ្នេរសមុទ្រកម្ពុជា . តារារះនាទិសនិរតី"។

ជាមួយការជំរុញឱ្យមានការអភិវឌ្ឍស្របតាមប្លង់មេដែលបានស្នើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្តេចក៏បានស្នើឱ្យការអភិវឌ្ឍនៅលើកោះត្រូវតែជាការអភិវឌ្ឍប្រកបដោយសមធម៌ដើម្បីធ្វើឱ្យប្រជាជនមូលដ្ឋានអាចទទួលផលប្រយោជន៍បានពីការអភិវឌ្ឍនេះ។ លើសពីនេះចាំបាច់ត្រូវអនុវត្តនយោបាយ"ស្បៃកខ្លា"ដោយធានាថា ការអភិវឌ្ឍមិនប៉ះពាល់ដល់ការតាំងលំនៅ និងជីវភាពរបស់ប្រជាជនមូលដ្ឋាន ។សម្តេចបានបន្តថា ដើម្បីឆ្លើយតបទៅនឹងកំណើនដ៏ឆាប់រហ័សនៃភ្ញៀវទេសចរ និងលើកកម្ពស់គុណភាពសេវាទេសចរណ៍ឱ្យស័ក្តិសមជា "ឆ្នេរសមុទ្រកម្ពុជាៈ តារារះនាទិសនិរតី" ក្រសួងទេសចរណ៍គួររៀបចំបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ជំនាញឆ្នេរសមុទ្រឱ្យបានឆាប់។ សម្តេចក៏បានថ្លែងអំណរគុណចំពោះទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍដែលកំពុងសហការជាមួយក្រសួងទេសចរណ៍ក្នុងការបង្កើតសាលាបណ្តុះបណ្តាលនេះនៅតំបន់ឆ្នេរសមុទ្រកម្ពុជាផងដែរ ។

សម្តេចបានលើកឡើងទៀតថា ក្រសួងទេសចរណ៍ត្រូវយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍទេសចរណ៍មុជក្រោមសមុទ្រដែលជាផលិតផលទេសចរណ៍កំពុងលេចធ្លោ និងគាំទ្រនូវរាល់គម្រោងនៃការអភិវឌ្ឍទាំងឡាយដែលពាក់ពន្ធ័នឹងវិស័យនេះ ដូចជាការបង្កើតឧទ្យានក្រោមសមុទ្រជាដើម ដើម្បីការពារ និងអភិរក្សធនធានជីវៈចម្រុះ ធានានិរន្តរភាពប្រព័ន្ធអេកូឡូស៊ីក្រោមសមុទ្រ ចូលរួមចំណែកអភិវឌ្ឍវិស័យទេសចរណ៍ ដើម្បីជាប្រយោជន៍ដល់ប្រជាជនដែលអាស្រ័យផលពីធនធានធម្មជាតិទាំងនេះ ដោយគួរជ្រើសរើសយកតំបន់កោះរ៉ុង កោះរ៉ុងសន្លឹម និងតំបន់ជុំវិញឆ្នេរអូរត្រេះ សម្រាប់ការអភិវឌ្ឍជំហានដំបូង។ ក្នុងន័យនេះ ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា ត្រូវសហការជាមួយភាគីពាក់ព័ន្ធរៀបចំបទដ្ឋានគតិយុត្តិបង្កើត និងកំណត់ឧទ្យានក្រោមសមុទ្រកម្ពុជា ។

ជាមួយគ្នានេះសម្តេចតេជោ ក៏បានដាក់ចេញនូវកម្មវិធីថ្នាក់ជាតិមួយហៅថាយុទ្ធនាការសម្អាតឆ្នេរក្រោមប្រធានបទ "ស្រឡាញ់ផ្ទៃសមុទ្រខៀវស្រងាត់ ថែរក្សាឆ្នេរខ្សាច់" ដោយមានការរៀបចំជាប្រចាំ សប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីបំផុសចលនាមហាជនចូលរួមក្នុងការសម្អាតឆ្នេរ តាមរយៈការបញ្ជ្រាបការយល់ដឹងដល់ប្រជាជន និងភាគីពាក់ព័ន្ធនានាអំពីសារៈសំខាន់នៃតំបន់ឆ្នេរសមុទ្រ និងកំណត់យករៀងរាល់ថ្ងៃទី ១១ ខែកក្កដា ដែលជាថ្ងៃប្រកាសជាផ្លូវការដាក់បញ្ចូលឆ្នេរសមុទ្រកម្ពុជាជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ជាទិវាជាតិសម្អាតឆ្នេរ។

តាមរយៈមហាសន្និបាតលើកទី ៩ នៃក្លឹបឆ្នេរសមុទ្រស្អាតបំផុតលើសកលលោក គណៈប្រតិភូចូលរួមបានសម្តែងនូវការគាំទ្រទាំងស្រុងចំពោះអនុ-





*ទិដ្ឋភាពផ្សេងៗក្នុងពិធីបុណ្យសមុទ្រនៅឆ្នេរសមុទ្រកែប និងរមណីយដ្ឋានឋានសួគ៌បូកគោ*

សាសន៍របស់សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា ។ មហាសន្និបាតបានអនុម័ត និងប្រកាសជាផ្លូវការជាសមាជិកពេញសិទ្ធិរបស់ក្លឹបនូវឆ្នេរចំនួនពីរទៀតគឺ ឆ្នេរសាការូន(Sakarun) របស់ប្រទេសក្រូអាតស៊ី និងឆ្នេរម៉ាតស៊ូស៊ីម៉ា(Matsushima) របស់ប្រទេសជប៉ុន ដែលធ្វើឱ្យក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកមកដល់បច្ចុប្បន្នមានសមាជិកពេញសិទ្ធិចំនួន ៣៦ មកពីប្រទេសចំនួន ២៥ ។ មហាសន្និបាតក៏អនុម័ត និងទទួលស្គាល់ជាបេក្ខភាពថ្មីនូវឆ្នេរចំនួនពីរទៀត គឺឆ្នេរតូយ៉ាម៉ា(Toyama) របស់ប្រទេសជប៉ុន និងឆ្នេរណេហ្គួ-អាល់ហូស៊ីម៉ា (Nekour Al Hoceima) របស់ប្រទេសម៉ារ៉ូក ។

គួររំឭកថា ឆ្នេរសមុទ្រកម្ពុជាត្រូវបានបញ្ចូលជាសមាជិកពេញសិទ្ធិក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើពិភពលោកកាលពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១១ នៅប្រទេសសេណេហ្គាល់ ។ តាំងពីពេលនោះមក ឆ្នេរសមុទ្រកម្ពុជាត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី ៤ ប្រសិទ្ធនាមឱ្យថាជា"តារារះនាទិសនិរតី" ។ ដើម្បីអបអរសាទរចំពោះសមិទ្ធផលនេះ កម្ពុជាបានសម្រេចឱ្យមានការរៀបចំពិធីបុណ្យសមុទ្រជាលើកដំបូងកាលពីចុងឆ្នាំ ២០១១ នៅក្រុងព្រះសីហនុ ។ ប៉ុន្តែនៅឆ្នាំ២០១២ពិធីនេះពុំបានរៀបចំទេ ដោយសារកម្ពុជាទាំងមូលចូលរួមកាន់មរណទុក្ខ **ព្រះបរមរតនកោដ្ឋព្រះមហាវីរក្សត្រ** ។ នៅឆ្នាំ ២០១២ អ្នកទេសចរអន្តរជាតិបានចូលមកទស្សនាតំបន់ឆ្នេរកម្ពុជាមានជាង ២៨ ម៉ឺននាក់ និងទេសចរក្នុងស្រុកមានជាង ១ លាន ៨ សែននាក់ ។ សម្រាប់រយៈពេល ១០ ខែ ចាប់ពីខែមករាមក ក្នុងឆ្នាំ ២០១៣ នេះ ចំនួនអ្នកទេសចរអន្តរជាតិមកទស្សនាតំបន់ឆ្នេរកម្ពុជាមានចំនួនជិត ៤២ ម៉ឺននាក់ ។ តាមការព្យាករណ៍នៅឆ្នាំ ២០១៥ តំបន់ឆ្នេរសមុទ្រកម្ពុជាអាចនឹងទទួលបានទេសចរអន្តរជាតិប្រមាណមួយលាននាក់ និងប្រមាណពីរលាននាក់នៅឆ្នាំ ២០២០ ។

ដោយឡែកកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី ២ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យទេសចរណ៍ និង កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី ២ ដែលហៅកាត់ថា កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទេសចរណ៍CLMV នោះ បានឯកភាពគ្នាខ្ពស់ក្នុងការជំរុញយុទ្ធនាការឃោសនា ផ្សព្វផ្សាយរួមគ្នា "ប្រទេសបួនគោលដៅតែមួយ (Four Countries,One Destination)" និងជំរុញសម្រេចផែនការទាក់ទាញទេសចរណ៍អន្តរជាតិឱ្យបាន ២៥ លាននាក់ នៅឆ្នាំ ២០១៥ (ដែលក្នុងនោះទេសចរណ៍ផ្ទៃក្នុង CLMV មានចំនួន ៤ លាននាក់) ដោយជំរុញការតភ្ជាប់ និងការសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនឱ្យបានកាន់តែប្រសើរឡើង ។ កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ CLMV លើកទី ៣ នឹងប្រព្រឹត្តទៅនៅឆ្នាំ ២០១៥ ខាងមុខ នៅទីក្រុងម៉ាន់ដាឡេ ប្រទេសមីយ៉ាន់ម៉ា ។ ប្រទេសមីយ៉ាន់ម៉ានឹងធ្វើជាប្រធាននៃកិច្ចប្រជុំនេះ ។

គួរបញ្ជាក់ថាប្រតិភូចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍CLMV នេះមាន : កម្ពុជាជាម្ចាស់ផ្ទះដឹកនាំដោយឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ប្រទេសឡាវដឹកនាំដោយឯកឧត្តម Chaleune Wa rinthrasak រដ្ឋមន្ត្រីក្រសួងព័ត៌មាន វប្បធម៌ និងទេសចរណ៍ ប្រទេសមីយ៉ាន់ម៉ា ដឹកនាំដោយឯកឧត្តម Sai Kyaw Onh ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសណ្ឋាគារ និងទេសចរណ៍ និងប្រទេសវៀតណាមដឹកនាំដោយឯកឧត្តម Nguyen Van Tuan រដ្ឋមន្ត្រីក្រសួងវប្បធម៌ កីឡា និងទេសចរណ៍ ។

ទាក់ទងនឹងកិច្ចប្រជុំលើកទី ៣២ នៃក្រុមការងារទេសចរណ៍នៃមហាអនុតំបន់មេគង្គ ដែលហៅកាត់ថា កិច្ចប្រជុំក្រុមការងារទេសចរណ៍ GMS នោះ ក៏បានឯកភាពគ្នាខ្ពស់ជំរុញការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងតំបន់(២០១១-២០១៥) ដោយផ្តោតលើការងារផ្សព្វផ្សាយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍ ។

ដោយឡែក បុណ្យសមុទ្របានប្រារព្ធធ្វើរយៈពេលបីថ្ងៃគឺពីថ្ងៃទី ៦ ដល់ទី ៨ ខែធ្នូ នៅតំបន់ឆ្នេរខេត្តកែប ។ ពិធីជាផ្លូវការបានប្រព្រឹត្តទៅនៅល្ងាចថ្ងៃទី ៧ ខែធ្នូ ក្រោមអធិបតីភាពឯកឧត្តម **សុខ អាន** ឧប នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងមានការចូលរួមពីសំណាក់គណៈប្រតិភូនៃក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើពិភពលោក គណៈប្រតិភូរដ្ឋមន្ត្រីទេសចរណ៍ CLMV គណៈប្រតិភូ GMS ឯកអគ្គរាជទូត រដ្ឋទូត តំណាងទូតទេសចរអន្តរជាតិ ទេសចរជាតិយ៉ាងច្រើនកុះករ ។

គួរបញ្ជាក់ថា ក្នុងឱកាសនៃការប្រារព្ធពិធីសំខាន់ៗនៅរមណីយដ្ឋានឋាន






សួគិបូកគោ និងបុណ្យសមុទ្រនៅខេត្តកែបនេះ សណ្ឋាគារផ្ទះសំណាក់ទាំងអស់នៅខេត្តកំពត និងខេត្តកែប បានពេញទៅដោយភ្ញៀវ ។ មន្ត្រីជំនាញបានធ្វើការប៉ាន់ស្មានថា មានមនុស្សមិនតិចជាង ១០ ម៉ឺន បានចូលរួម និងទៅទស្សនាតំបន់ឆ្នេរសមុទ្រកម្ពុជាអំឡុងនៃការរៀបចំពិធីនេះ ។

ក្នុងពិធីបុណ្យសមុទ្រឆ្នាំនេះដែរ គណៈកម្មការអន្តរស្ថាប័នបានរៀបចំសកម្មភាពសំខាន់ៗមួយចំនួន ដែលក្នុងនោះមាន : ក្បួនព្យុះហយាត្រាបង្ហាញពីមធ្យោបាយធ្វើដំណើរបៃតង ដូចជារថយន្តអគ្គិសនីរបស់ក្រុមហ៊ុន ហេងអភិវឌ្ឍន៍ ទោចក្រយានយន្តអគ្គិសនីរ៉ឺម៉កអគ្គិសនី និងមនុស្សយន្តចាក់សំរាម ដែលស្រាវជ្រាវ និងផលិតឡើងដោយក្រុមនិស្សិត និងសាស្ត្រាចារ្យនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងសាកលវិទ្យាល័យន័រតុន សកម្មភាពកីឡាលើទឹក និងកីឡាលើឆ្នេរ មហោស្រព ម្ហូបអាហារ ស្រា ភេសជ្ជៈ និងការតាំងពិព័រណ៍ ការប្រកួតរូបភាពសមិទ្ធផល និងគម្រោងអភិវឌ្ឍន៍តំបន់ឆ្នេរ ការប្រគំតន្ត្រី ការសម្តែងទស្សនីយភាពសិល្បៈ ការបាញ់កាំជ្រួចអបអរ និងពិធីបុណ្យដាំដើមឈើគុជមិត្តភាព( ទេសចរម្នាក់ ដើមឈើមួយដើម) ។

ចំពោះសកម្មភាពកីឡា ដែលរៀបចំដោយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជានោះ នៅថ្ងៃទី ៦ ខែធ្នូ មានការបង្ហាញប្រភេទកីឡាហោះហើរ (Airo Show) ប្រភេទកីឡាលើទឹក (Open Water) និងប្រភេទកីឡាបាល់ទះលើឆ្នេរខ្សាច់ (Beach-Volley) ។ ថ្ងៃទី ៧ ធ្នូ ដែលជាថ្ងៃទី ២ នៃពិធីបុណ្យ មានការរត់ប្រណាំងកំសាន្ត (Fun Run) ចម្ងាយ ៣ និង ៥ គីឡូម៉ែត្រ ។ ការរត់ប្រណាំងនេះ មានអ្នកចូលរួមមិនតិចជាង ១ 000 នាក់ទេ ។ ការហែលទឹកចម្ងាយឆ្ងាយ គឺ ៥ គីឡូម៉ែត្រនៅក្នុងសមុទ្រ ។ មានកីឡាករ-កីឡាការិនីអាជីពជាង ៦0 នាក់ ចូលរួមប្រកួតហែលទឹកចម្ងាយឆ្ងាយនេះ ។ ការបង្ហាញពីកីឡាម៉ូតូលើទឹក (Jetsky)កីឡាទូកក្តោង (Sailing) លោតឆ័ត្រយោង និងកីឡាហោះហើរ (ParaChute and Airo Show) រួមជាមួយកម្មវិធីប្រដាល់ក្បាច់គុនបូរាណខ្មែរដែលមានចំនួន ៦ គូ ។ សម្រាប់ថ្ងៃទី ៨ ធ្នូ ដែលជាថ្ងៃចុង ក្រោយនោះមានការប្រកួតកីឡាទ្រីយ៉ាត្លុង(ដែលមានកីឡា ៣ ប្រភេទបញ្ចូលគ្នា គឺហែលទឹក ជិះកង់ និងរត់ប្រណាំង) ។ សម្រាប់ការប្រកួតក្នុងពិធីនេះ គឺតម្រូវឱ្យហែលទឹក ២00 ម៉ែត្រ ប្រណាំងកង់ ១0 គីឡូម៉ែត្រ និងរត់ ៣ គីឡូម៉ែត្រ ។

ឯកឧត្តម **ថោង ខុន** បានមានប្រសាសន៍ទាក់ទងទៅនឹងបុណ្យសមុទ្រ និងតំបន់ឆ្នេរសមុទ្រកម្ពុជានោះថា "ប្រសិនជាចង់អភិវឌ្ឍតំបន់ឆ្នេរមួយប្រកបដោយការទទួលខុសត្រូវខ្ពស់ យើងមិនអាចកាត់ផ្តាច់ទំនាក់ទំនងដ៏ស្អិតរមួតរវាងឆ្នេរសមុទ្រ និងទីក្រុងជាប់ឆ្នេរឡើយ ។ ឆ្នេរសមុទ្រល្អស្អាតខៀវស្រងាត់ សម្បូរដោយជីវៈចម្រុះ និងទីក្រុងដែលមានសេវាកម្មទេសចរណ៍ល្អ និងមានសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ បរិស្ថានល្អ ពិតជានឹងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរបានល្អប្រសើរ ។ ទីក្រុងមានការអភិវឌ្ឍប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមិនបង្កផលប៉ះពាល់មកលើតំបន់ឆ្នេរសមុទ្រឡើយ ។ ដូចនេះដើម្បីធានាថា ការអភិវឌ្ឍទីក្រុងមិនបង្កផលប៉ះពាល់អវិជ្ជមានមកតំបន់ឆ្នេរ ចាំបាច់ណាស់ត្រូវតែអភិវឌ្ឍទីក្រុងនោះឱ្យក្លាយជាទីក្រុងបៃតង(EcoCity/GreenCity)ដោយគោរពតាមគោលការណ៍ និងស្តង់ដាទីក្រុងស្អាត ។ ទីក្រុងបៃតង មិនត្រឹមតែអាចកាត់បន្ថយផលប៉ះពាល់មកលើតំបន់ឆ្នេរប៉ុណ្ណោះទេ តែថែមទាំងជួយទាក់ទាញទេសចរឱ្យមកកំសាន្តតំបន់ឆ្នេរថែមទៀតផង" ។/





# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស




ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ឯកឧត្តមបណ្ឌិត **ខួន ញឹុល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជា-ជនកម្ពុជា អនុប្រធានទី១រដ្ឋសភា ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំការងារជាមួយក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្ត និងគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ធំ ។ ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ខួន ញឹុល** បានឧបត្ថម្ភថវិកាចំនួន ១000 ដុល្លារ ជូនដល់គណបក្សមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត និង ១000 ដុល្លារ ជូនស្នាក់ការគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ធំ សម្រាប់រៀបចំពិធីមិទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៣៥ ទិវាជ័យជម្នះ ៧ មករា ឆ្នាំ ២០១៤ នៅខេត្តកំពង់ធំ ។




*ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៣ នាសាលប្រជុំខេត្តស្វាយរៀង លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំបូកសរុបការងារចុះជួយខេត្តនៃតំណាក់កាលទី ៦ លើកទី ១ និងលើកទិសដៅសម្រាប់អនុវត្តបន្តតំណាក់កាលទី ៦ លើកទី ២ ដោយបានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ នៃក្រុមការងារចុះជួយខេត្ត ស្រុក ឃុំ ប្រមាណ១000នាក់ ។លោកជំទាវ**ម៉ែន សំអន**បានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ឯកឧត្តមលោកជំទាវនៃក្រុមការងារចុះជួយខេត្តស្រុកឃុំដែលបានយកអស់កម្លាំងកាយចិត្តក្នុងការការពារ កសាងអភិវឌ្ឍន៍មូលដ្ឋានឱ្យរីកចម្រើន និងរក្សាបានភាពសុខដុមរមនាជូនប្រជាជនបានល្អប្រសើរ ។ លោកជំទាវបានផ្តាំផ្ញើដល់មន្ត្រីគណបក្សគ្រប់លំដាប់ថ្នាក់ ត្រូវបន្តយកចិត្តទុកដាក់ពង្រីកស្នាដៃបន្ថែមទៀត ដើម្បីរក្សាភាពរឹងមាំរបស់គណបក្សប្រជាជនកម្ពុជា ជាពិសេសការពង្រឹងសាមគ្គីភាពផ្ទៃក្នុងឱ្យកាន់តែរឹងមាំ ។*



ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ ឯកឧត្តម **យឹម ឆៃលី** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងលោកជំទាវ បានអញ្ជើញចូលរួមសម្ពោធឆ្លងសាលាធម្មសភា និងសមិទ្ធផលនានានៅវត្តរតនារាម(វត្តផ្សារកណ្តាល)សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ សាលាធម្មសភានោះ មានទំហំ ២៥ ម៉ែត្រ គុណ ៣៥ ម៉ែត្រ កម្ពស់ ២០ ម៉ែត្រ កុដិ ១ ខ្នង កម្ពស់ ២ ជាន់ រូបសំណាកនៃសត្វ ១២ របស់ឆ្នាំ ដងទង់ ១ គូ ទេពប្រណម្យ ៧៦ រូប បង្គន់អនាម័យ ១ ខ្នង ផ្ទះបាយ ១ ខ្នង និងចាក់សាបទីធ្លា ។ សរុបចំណាយថវិកា ២៤១.៨៤៨ ដុល្លារអាមេរិក ។

*ថ្ងៃទី ១៨ ខែធ្នូឯកឧត្តម **ត្រាំ អ៊ីវតឹក** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសហការី អមដំណើរដោយបុគ្គលិកក្រុមហ៊ុនសំណង់សៀងហៃគ្រុប ខូអិលធីឌី បានចុះត្រួតពិនិត្យវឌ្ឍនភាពនៃការស្ថាបនាផ្លូវជាតិលេខ ៩ ប្រវែង ១៤៣,៣ គីឡូម៉ែត្រ តភ្ជាប់ពីថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែងទៅដល់ក្រុងព្រះវិហារ ខេត្តព្រះវិហារ ។*





ថ្ងៃទី ១៣ ខែធ្នូ ឯកឧត្តម **អ៊ី ឈាន** អភិបាលខេត្តប៉ៃលិន រួមជាមួយសប្បុរសជនថៃនៃសមាគមមិត្តអ្នកចំការជនជាតិថៃប្រមាណជិត ២00 នាក់ បាននាំឧបករណ៍សម្រាប់ក្មេងលេង សម្ភារៈកីឡានិងសម្ភារៈសិក្សាជាច្រើនផ្តល់ជូនសាលាបឋមសិក្សាអូរអិល ភូមិអូរអិល ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ។

# គោលដៅយុទ្ធសាស្ត្រ ៤ និងវិស័យអាទិភាព ៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣

*នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៣ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៥ បានបើកសម័យប្រជុំដំបូងរបស់ខ្លួននៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** *។ នៅក្នុងសម័យប្រជុំនេះសម្តេចតេជោនាយករដ្ឋមន្ត្រីបានប្រកាសចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តការពារ និងកសាងមាតុភូមិឆ្ពោះទៅរកអនាគតដ៏រុងរឿង ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជន ដែលបានសម្តែងចេញតាមរយៈការបោះឆ្នោតថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ ។ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ រាជរដ្ឋាភិបាលបានលើកឡើងនូវគោលដៅយុទ្ធសាស្ត្រ ៤ និងវិស័យអាទិភាព ៤ ដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោម :*

## គោលដៅយុទ្ធសាស្ត្រ ៤ :

ទី១- ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ប្រមាណ ៧% ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចឱ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបានអត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ ។

ទី២- បង្កើតការងារឱ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អ និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងការទាក់ទាញ និងការជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគ ទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគមកពីក្រៅប្រទេស ។

ទី៣- សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង ១% ក្នុងមួយឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុង "គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា" ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ។

ទី៤-បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង ។

## វិស័យអាទិភាព ៤ :

ទី១-ការអភិវឌ្ឍធនធានមនុស្ស ដែលនឹងធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ ដែលកាន់តែបើកចំហតាមរយៈ (១).ការបណ្តុះបណ្តាលពលករឱ្យមានជំនាញ និងផលិតភាពខ្ពស់ តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃបន្ថែមខ្ពស់ (២).ការរៀបចំក្របខណ្ឌគតិយុត្តិ និងកសាងស្ថាប័នអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលឆ្លើយតបទៅនឹងចំណុចទី ១ ខាងលើ (៣).ការលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមនៅក្នុងកិច្ចការនេះនិង(៤).ការពង្រឹងគុណភាពនៃការអប់រំនិងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

ទី២-ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍និងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីកសាងប្រព័ន្ធឡូជិស្ទិកដ៏រស់រវើក តាមរយៈការសាងសង់បណ្តាញដឹកជញ្ជូនពហុសណ្ឋាន ក្នុងគោលដៅធានាឱ្យបាននូវការតភ្ជាប់ផ្ទៃក្នុងប្រទេស និងការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ព្រមទាំងឆ្លើយតបបានទៅនឹងការរីកចម្រើនផ្នែកនគរូបនីយកម្ម ដែលនឹងនាំមកនូវ (១). ការកាត់បន្ថយថ្លៃដឹកជញ្ជូន (២).ការបង្កើនភាពអាចទុកចិត្តបាន និងភាពស័ក្តិសិទ្ធិ (៣).ការពង្រឹងភាពប្រកួតប្រជែង និង(៤).ការបង្កើនការវិនិយោគ និងពាណិជ្ជកម្ម ។ ម្យ៉ាងវិញទៀតរាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពក្នុងការពង្រីកសមត្ថភាពផលិត និងផ្គត់ផ្គង់ថាមពលពីប្រភពដែលមានតម្លៃកាន់តែទាប និងពង្រីកបណ្តាញចែកចាយ សំដៅធានាសន្តិសុខថាមពល ភាពអាចទុកចិត្តបានក្នុងការផ្គត់ផ្គង់ថាមពល ព្រមទាំងថ្លៃសមរម្យ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍ ។

ទី៣-ការបន្តអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្មតាមរយៈ (១).ការបង្កើនតម្លៃបន្ថែមនៃការផលិត និងការនាំចេញអង្ករ ពិសេសការផ្តោតលើអង្ករក្រអូប អង្ករសរីរាង្គ និងកសិផលមានតម្លៃខ្ពស់ឯទៀត ដូចជា កៅស៊ូ ស្វាយចន្ទី ពោត សណ្តែកបាយ សណ្តែកសៀង ល្ង ម្រេច សូត្រ ផ្លែឈើ កាហ្វេ បន្លែបង្ការ និងផ្កា ជាដើម (២). ការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្មដែលទីផ្សារត្រូវការ ដូចជា សាច់ ត្រី ផលិតផលទឹកដោះគោជាដើម (៣).ការជំរុញលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិឧស្សាហកម្ម និង(៤).ការបង្កើនផលិតភាព ទំនើបកម្មកសិកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម ។

ទី៤-ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ និងកែលម្អបរិយាកាសវិនិយោគ តាមរយៈ(១).ការបន្តអនុវត្តការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ដើម្បីធានាយុត្តិធម៌សង្គម ព្រមទាំងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ សុចរិតភាព តម្លាភាព និងគណនេយ្យភាព (២).ការបន្តអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ព្រមទាំងពង្រឹងស្ថាប័នត្រួតពិនិត្យ ដើម្បីបង្ខិតសេវាសាធារណៈឱ្យជិតប្រជាជនលើកកម្ពស់កិច្ចដំណើរការប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងធានាបាននូវតុល្យភាពក្នុងការអនុវត្តអំណាច (៣).ការបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាប្រសិទ្ធភាពក្នុងការវិភាជ និងការប្រើប្រាស់ថវិកា និង (៤).ការបង្កើនភាពទាក់ទាញចំពោះការវិនិយោគក្នុងនោះមានការកាត់បន្ថយថ្លៃដើម និងរបាំងធុរកិច្ច ការពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តដល់ការវិនិយោគ ការពង្រឹងភាពជឿទុកចិត្ត និងភាពអាចប៉ាន់ប្រមាណបានក្នុងការធ្វើធុរកិច្ច ព្រមទាំងការផ្តោតការយកចិត្តទុកដាក់លើកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស ។/

# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

## ចំណូលពន្ធដារ ខែវិច្ឆិកា

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឱ្យដឹងថា នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១៣ កន្លងមកនេះ ពន្ធដារប្រមូលបានចំណូលពន្ធបង់ចូលថវិកាចំនួន២២២,២៩ពាន់លានរៀល ឬប្រមាណ៥៥,៥លានដុល្លារអាមេរិក ។ ចំណូលនេះបើប្រៀបធៀបនឹងចំណូលពន្ធដារខែវិច្ឆិកា ឆ្នាំ ២០១២ កន្លងទៅ គឺមានការកើនឡើងប្រមាណ ១១,៤% ។

សរុបរយៈពេល១១ខែនៃឆ្នាំ ២០១៣ នេះ ប្រាក់ពន្ធដារប្រមូលបានមានចំនួន ៣ ២០០,៦៧ ពាន់លានរៀល ឬប្រមាណ ៨០០ លានដុល្លារ ស្មើនឹង ៩២,៤%នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣ ។ បើប្រៀបធៀបនឹងរយៈពេល ១១ ខែដូចគ្នាក្នុងឆ្នាំ ២០១២ ឃើញថា ប្រាក់ចំណូលដែលសម្រេចបានមានកំណើន ១៧,៣% ។

តាមការវិភាគប្រភេទពន្ធ គឺចំណូលក្នុងឆ្នាំ ២០១៣ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជាពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ២៦,៤% ពន្ធលើប្រាក់ចំណេញកើនឡើងប្រមាណ ១៨,៣% អាករលើតម្លៃបន្ថែម កើនឡើងប្រមាណ ១៩,៧% និងអាករ ពិសេសកើនឡើងប្រមាណ ១៥,២% ។

បើពិនិត្យតាមវិស័យក៏ឃើញថាចំណូលក្នុងឆ្នាំ២០១៣មានការកើនឡើងស្ទើរគ្រប់សកម្មភាពក្នុងនោះ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ ២០,៤% ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២៧,៣% ផ្នែកទូរគមនាគមន៍កើនឡើងប្រមាណ ២៥,២% ផ្នែកផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៣១,៦% ផ្នែកនីហរ័ណ-អាហរ័ណ កើនឡើងប្រមាណ ១៩,៨% ស្ថាបត្យកម្ម និងសំណង់កើនឡើងប្រមាណ២៨% ផ្នែកផលិតសម្លៀកបំពាក់៤៧,៣% ផ្នែកដឹកជញ្ជូន និងទេសចរណ៍ ៣៤,៥% អាកាសយានដ្ឋាន និងកំពង់ផែកើនឡើងប្រមាណ៨០,៣% សណ្ឋាគារ និងផ្ទះសំណាក់កើនឡើងប្រមាណ១៩,៥% លក់គ្រឿងយន្តស្មើនឹង ២៤២,៩% ផលិតម្ហូបអាហារ ស្មើនឹង ៤៨,៩% ផ្នែកគ្រឿងអេឡិចត្រូនិច ស្មើនឹង ៤០,៣% និងផលិតផលគ្រឿងចក្រ ស្មើនឹង ៦២,៤% ។

## ការនាំចេញសម្លៀកបំពាក់ ១១ ខែ

ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ថារយៈពេល ១១ ខែ នៃឆ្នាំ ២០១៣ នេះ កំណើននៃការនាំចេញផលិតផលវិស័យកាត់ដេរនៅកម្ពុជាគឺមានតម្លៃប្រមាណ ២២% ។ ការនាំចេញមានតម្លៃប្រមាណ ៥,០៧ ពាន់លានដុល្លារ ខណៈ ដែលកាលពីរយៈពេលដដែលឆ្នាំ ២០១២ មានតម្លៃត្រឹម ៤,១៥ ពាន់លានដុល្លារ ។

ក្រៅពីទីផ្សារនាំចេញទៅអាមេរិក និងសហគមន៍អឺរ៉ុបហើយនោះ ពាណិជ្ជកម្មលើផលិតឧស្សាហកម្មកាត់ ដេរកម្ពុជាក៏ពង្រីកការនាំចេញទៅកាន់បណ្តាប្រទេសផ្សេងៗ ដូចជា ជប៉ុន ចិន កាណាដា និងបណ្តាប្រទេសនៅអាស៊ីមួយចំនួនទៀតផងដែរ ។

ការនាំចេញទៅសហរដ្ឋអាមេរិកមានតម្លៃជិត ២ ពាន់លានដុល្លារ ។ ទៅអឺរ៉ុបប្រមាណ ១,៨ ពាន់លានដុល្លារ និងបណ្តាប្រទេសផ្សេងៗមានតម្លៃប្រមាណជាង ១ ពាន់លានដុល្លារ ។

## ពាណិជ្ជកម្មកម្ពុជា_ជប៉ុនរយៈពេល ១០ ខែ

អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (Jetro) បានអះអាងថា នៅក្នុងរយៈពេល ១០ ខែឆ្នាំ ២០១៣ នេះ ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ជប៉ុន មានតម្លៃ ៦៦៩,៧ លានដុល្លារអាមេរិក ខណៈដែលរយៈពេលដូចគ្នានាឆ្នាំ ២០១២ មាន-តម្លៃត្រឹមតែ ៥៣៨ លានដុល្លារ ។ ពោលគឺកើនឡើងជាង ២៤,៤% ។

នៅក្នុងរយៈពេល ១០ ខែនេះការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារនៅក្នុងប្រទេសជប៉ុន មានតម្លៃ ប្រមាណ ៤៩៤,២ លានដុល្លារ គឺមានការកើនឡើងប្រមាណ ៤៣,៣% ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំ ២០១២ ដែលមានតម្លៃត្រឹមតែ ៣៤៤,៨ លានដុល្លារ ។

សម្រាប់ការនាំចេញរបស់ជប៉ុនមកកាន់ទីផ្សារកម្ពុជាវិញនោះនៅក្នុងរយៈពេល ១០ ខែមានតម្លៃត្រឹមតែ ១៧៥,៥ លានដុល្លារ គឺថយចុះ ៩,២% ធៀបនឹង រយៈពេលដដែលឆ្នាំ ២០១២ ដែលមានតម្លៃ ១៩៣,២ លានដុល្លារ ។

រហូតមកដល់ពេលនេះទំនិញដែលកម្ពុជានាំចេញទៅកាន់ជប៉ុន មានដូចជាផលិតផលរោងចក្រកាត់ដេរ ផលិតផលកសិកម្ម ដែលរួមមាន ម្រេច ជលផល អង្ករមួយចំនួនជាដើម ។ ដោយឡែកជប៉ុននាំចេញមកកាន់ទីផ្សារនៅក្នុងប្រទេសកម្ពុជារួមមាន ផលិតផលអេឡិចត្រូនិច យានយន្ត និងគ្រឿងម៉ាស៊ីន ។

កាលពីឆ្នាំ ២០១២ កន្លងទៅនេះ ពាណិជ្ជកម្មទ្វេភាគីរបស់ប្រទេសទាំងពីរមានតម្លៃប្រមាណ ៦៤១ លានដុល្លារ ក្នុងនោះកម្ពុជានាំចេញទៅជប៉ុនមានតម្លៃ ៤០៥ ៨ លានដុល្លារ និងជប៉ុននាំចេញមកកាន់កម្ពុជាវិញមានតម្លៃ ២៣៥,២ លានដុល្លារ ។

## វិស័យសំណង់រយៈពេល ១០ ខែ

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានបញ្ជាក់ថា ពីខែមករាដល់ខែតុលាឆ្នាំ ២០១៣ វិស័យសំណង់ស្រូបបានទឹកប្រាក់វិនិយោគសរុបចំនួន ២ ៤៨៣ លានដុល្លារអាមេរិក ជាមួយនឹងគម្រោងសរុបចំនួន ១ ៣៧០ គម្រោង គឺមានការកើនឡើង ៣០% បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ ២០១២ ។ ទំហំវិនិយោគ និងគម្រោងក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ មានចំនួន ១ ៤៩៤គម្រោង គិតជាទឹកប្រាក់សរុបចំនួនត្រឹម តែ ១ ៩២៣ លានដុល្លារ ។

រហូតមកដល់ពេលនេះ វិស័យសំណង់កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច ហើយការកើនឡើងនូវវិស័យសំណង់នាពេលនេះ គឺដោយសារតែកំណើនសេដ្ឋកិច្ចជាតិ ជាពិសេសគឺស្ថិរភាពនយោបាយ ។

ក្រុមហ៊ុនប៊ុណ្ណារៀលធីគ្រុបដែលជាក្រុមហ៊ុនឯកជនរកស៊ីវិស័យអចលន-វត្ថុមួយបានអះអាងថា ស្ថិរភាពនយោបាយនៅក្រោយការបោះឆ្នោតនេះ វាជាកត្តាមួយដែលនាំឱ្យវិនិយោគិនលើវិស័យអចលនទ្រព្យកាន់តែមានទំនុកចិត្តទៅទៀត ។ សកម្មភាពទិញលក់អចលនទ្រព្យគឺនៅធម្មតា ហើយតម្លៃក៏នៅប្រក្រតី ។ ដោយឡែក សំណង់វិញនៅពេលនេះគឺមានភាពវិជ្ជមាន ។ នៅក្នុងឆ្នាំ ២០១៤ ខាងមុខ ស្ថានភាពនៃវិស័យសំណង់ និងអចលនទ្រព្យនឹងកាន់តែប្រសើរទៅទៀត ។

ក្នុងរយៈពេលដូចគ្នានេះដែរធនាគារពាណិជ្ជចំនួនពីរបានអះអាងថា កំពុង

តនៅទំព័រទី ២៣

# ឆ្នាំ ២០១៣ ការវិនិយោគរបស់ជប៉ុននៅកម្ពុជាកើនឡើងគួរឱ្យកត់សម្គាល់

កម្ពុជា-ជប៉ុន មានទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ ហើយទំនាក់ទំនងនេះបានរីកចម្រើនឥតឈប់ឈរស្របជាមួយនឹងការរំឭកខួប៦០ឆ្នាំនៃការបង្កើតចំណងការទូតរវាងប្រទេសទាំងពីរនៅឆ្នាំ ២០១៣ នេះ។ ក្នុងឆ្នាំនេះដែរព្រះចៅអធិរាជនៃប្រទេសជប៉ុន បានព្រះរាជទានគ្រឿងឥស្សរិយយសថ្នាក់ខ្ពស់បំផុតនៃប្រទេសជប៉ុន Grand Cordon of the Order of the Rising Sun ជូនសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានរួមចំណែកយ៉ាងធំធេងក្នុងការលើកស្ទួយមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ហើយថ្មីៗនេះ ឯកឧត្តម **ស៊ិនហ្ស៊ូអាបេ** នាយករដ្ឋមន្ត្រីជប៉ុនបានមកបំពេញទស្សនកិច្ចជាមិត្តភាពផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ហើយថ្មីៗនេះ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានទៅបំពេញទស្សនកិច្ចការងារផ្លូវការនៅប្រទេសជប៉ុន ។ ម្យ៉ាងទៀតគួរកត់សម្គាល់ថា ក្នុងឆ្នាំ ២០១៣ វិនិយោគិនជប៉ុនបានមកបណ្តាក់ទុននៅកម្ពុជាមានចំនួនកាន់តែច្រើនឡើង ។ ជាក់ស្តែង លំហូរទុនវិនិយោគជប៉ុនមកកម្ពុជាពីឆ្នាំ ១៩៩៤ មកដល់ខែតុលា ឆ្នាំ ២០១៣ មានចំនួន ៥៩៣ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៣ មានប្រមាណ ៣០០ លានដុល្លារ ឆ្នាំ ២០១២ មាន ២៧១ លានដុល្លារ ។ ក្រុមហ៊ុនជប៉ុនដែលមកវិនិយោគនៅកម្ពុជាមានកំណើនខ្លាំងក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ គឺមានរហូតដល់ជាង ១០០ ក្រុមហ៊ុន ។

គម្រោងវិនិយោគធំៗរបស់ជប៉ុនត្រូវបានបើកការដ្ឋាន និងដាក់ឱ្យដំណើរការជាបន្តបន្ទាប់មានជាអាទិ៍ រោងចក្រផលិតគ្រឿងបង្គុំប្រព័ន្ធខ្សែភ្លើងរថយន្តរបស់ក្រុមហ៊ុន យ៉ាហ្សាគី ក្នុងតំបន់ឧស្សាហកម្មសេដ្ឋកិច្ចពិសេស នាងកុក ខេត្តកោះកុង ដែលមានតម្លៃជាង ២៤លានដុល្លារ ការបើកការដ្ឋានសាងសង់ផ្សារទំនើប អ៊ីអនម៉ល ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ តម្លៃជាង ២០០ លានដុល្លារ សណ្ឋាគារ តូយ៉ូកូអ៊ីន ដែលសហការវិនិយោគដោយក្រុមហ៊ុន តូយ៉ូកូអ៊ីន ជប៉ុនជាមួយក្រុមហ៊ុនក្នុងស្រុក ដោយបណ្តាក់ទុនប្រមាណជាង ២០លានដុល្លារ ។ល។

ក្រុមហ៊ុនជប៉ុន DENSO Cambodia ជាក្រុមហ៊ុនដំឡើងផលិតផលប្រព័ន្ធអគ្គិសនីសម្រាប់ដំណើរការយានយន្តបានពង្រីកការវិនិយោគរបស់ខ្លួននៅកម្ពុជា ដោយសាងសង់រោងចក្រផ្ទាល់ខ្លួននៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ បន្ទាប់ពីដំណើរការជំហានដំបូងដោយជួលអគាររោងចក្រ តាំងពីខែកក្កដា ឆ្នាំ ២០១៣។ លោក សេង ចន្ទី ប្រធានរដ្ឋបាលក្រុមហ៊ុន DENSO Cambodia បានឱ្យដឹងថា ក្រុមហ៊ុនបានចំណាយទុនវិនិយោគប្រមាណ ១០ លានដុល្លារ ដើម្បីវិនិយោគបន្ថែម ដែលរាប់ទាំងការទិញដីទំហំ១០ហិកតា និងការសាងសង់រោងចក្រផង ហើយគ្រោងនឹងបើកដំណើរការចាប់ពីឆ្នាំ ២០១៥ ទៅ។ លោកបន្តថា យើងអាចផលិត ផលិតផលដែលមានគុណភាពដូចអ្វីដែលខាងក្រុមហ៊ុន DENSO នៅថៃបានបញ្ជាទិញ។ យើងសង្ឃឹមថា បន្ទាប់ពីមានរោងចក្រខ្លួនឯងនេះ យើងនឹងអាចផលិតផលិតផលបានច្រើន ប្រភេទជាងនេះ។ នៅដំណាក់កាលដំបូងនៃការវិនិយោគ ចាប់ពីខែ កក្កដា មកក្រុមហ៊ុនផលិតប្រព័ន្ធម៉ាញេតូ តែមួយមុខប៉ុណ្ណោះហើយបញ្ជូនផលិតផលទាំងនោះទៅរោងចក្រ DENSO នៅថៃដែលជាកន្លែងផ្គុំទៅជាផលិតផលសម្រេច។ DENSO Cambodia គឺជាក្រុមហ៊ុនសម្ព័ន្ធរបស់ក្រុមហ៊ុនមេនៅជប៉ុនគឺ DENSO Corporation ដែលជាអ្នកផលិតប្រព័ន្ធអគ្គិសនី និងគ្រឿងបង្គុំ អេឡិចត្រូនិកផ្សេងៗសម្រាប់ដំណើរការយានយន្ត។ DENSO Corporation មានក្រុមហ៊ុនសម្ព័ន្ធទាំងអស់ ២០០ ក្រុមហ៊ុនប្រតិបត្តិការនៅ ៣៥ ប្រទេស។ នៅអាស៊ាន DENSO បានវិនិយោគនៅ សិង្ហបុរី ថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន វៀតណាម និងកម្ពុជា។

ក្នុងឱកាសអនុញ្ញាតឱ្យប្រធានសាជីវកម្ម Denso ចូលជួបសម្តែងការគួរសមកាលពីខែមុន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានបង្ហាញការគាំទ្រយ៉ាងពេញទំហឹងនូវការធ្វើអាជីវកម្មរបស់ ក្រុមហ៊ុននេះនៅកម្ពុជា និងជូនពរឱ្យក្រុមហ៊ុនទទួលបានជោគជ័យក្នុងអាជីវកម្មរបស់ខ្លួន ។ នៅក្នុងជំនួបនោះ សម្តេចបានស្វាគមន៍ចំពោះវត្តមានរបស់ ក្រុមហ៊ុន Denso នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានប្រសាសន៍ថា គោលនយោបាយរបស់កម្ពុជា គឺមិនត្រឹមតែទាក់ទាញវិនិយោគិនមកកាន់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឱ្យវិនិយោគិនមានការពង្រីកចង្វាក់ពាណិជ្ជកម្មកាន់តែធំទៅទៀតផង ។ សម្តេចតេជោ **ហ៊ុន សែន** មានប្រសាសន៍ថា រាជរដ្ឋាភិបាលនឹងខិតខំរក្សាបរិយាកាសឱ្យកាន់តែល្អឡើងថែមទៀតសម្រាប់ការវិនិយោគនៅក្នុងកម្ពុជា ។

លោក Nobuaki Katoh ប្រធានសាជីវកម្ម Denso របស់ប្រទេសជប៉ុនបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចតេជោ **ហ៊ុន សែន** និងរាជរដ្ឋាភិបាលកម្ពុជា ដែលកន្លងមកបានគាំទ្រក្រុមហ៊ុនរបស់លោក។ លោក Nobuaki បានជម្រាបជូនសម្តេចថា ក្រុមហ៊ុន Denso ជាក្រុមហ៊ុនដែលដំឡើងគ្រឿងបង្គុំរបស់យានយន្តកង់ ២ សម្រាប់នាំចេញទៅប្រទេសថៃ និងវៀតណាម ហើយនៅពេលអនា-

គតនឹងមានការរៀបចំផលិតគ្រឿងបង្គុំសម្រាប់យានយន្តកង់ ៤ ថែមទៀត ។ លោក Nobuaki បានបញ្ជាក់ថា ក្រុមហ៊ុនរបស់លោកធ្វើការបណ្ដុះបណ្ដាលធនធានមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែម្ដងដោយធ្វើយ៉ាងណាប្រឹងប្រែងធ្វើឱ្យអ្នកបច្ចេកទេសកម្ពុជា ដែលទទួលបានការបណ្ដុះបណ្ដាលនោះ នឹងក្លាយទៅជាអ្នកឯកទេសជំនាញ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍកម្ពុជា ។

ប្រជាជនកម្ពុជាជាទូទៅមានការនិយមយ៉ាងខ្លាំងចំពោះផលិតផលម៉ាកជប៉ុន ។ នៅកម្ពុជា តូយ៉ូតា គឺជាម៉ាករថយន្តល្បីល្បាញមួយដែលមានអ្នកប្រើប្រាស់ច្រើនជាងគេ ។ ដោយឡែកផលិតផលអេឡិចត្រូនិកម៉ាកសូនី ដ៏ល្អប្រណិត និងម៉ាកផ្សេងៗទៀតក៏ទទួលបានការស្វាគមន៍ច្រើនដែរពីអ្នកប្រើប្រាស់ក្នុងស្រុក ។ ប្រជាជនកម្ពុជាភាគច្រើនមានទស្សនៈថា ជប៉ុនគឺជាប្រទេសដ៏ល្បីមួយក្នុងការផលិតនូវផលិតផលបច្ចេកវិទ្យាខ្ពស់គុណភាពល្អ ហើយក្រុមហ៊ុនជប៉ុនមានការគ្រប់គ្រងម៉ត់ចត់អនុលោមតាមនិយាមអន្តរជាតិ ។ ដូចនេះការវិនិយោគរបស់ជប៉ុននៅកម្ពុជា នឹងនាំមកនូវគុណសម្បត្តិទាំងអស់នេះចូលមកកម្ពុជាដែលកំពុងតែលូតលាស់ ជាពិសេសគឺចូលរួមពង្រឹងសមត្ថភាពផ្នែកបច្ចេកទេស និងលើកកម្ពស់គុណភាពផលិតផលកម្ពុជាឱ្យមានភាពល្បីល្បាញ ដូចផលិតផលប្រទេសជប៉ុនដែរ ។ ជាក់ស្ដែងក្រុមហ៊ុនមីនេបៀររបស់ជប៉ុនដែលបានកសាងរោងចក្រផលិតម៉ូទ័រខ្នាតតូចនៅរាជធានីភ្នំពេញកន្លងមក បានបញ្ជូនបុគ្គលិកកម្ពុជាទៅបណ្ដុះបណ្ដាលជំនាញបច្ចេកទេសនៅប្រទេសជប៉ុន និងប្រទេសថៃមុននឹងចូលបម្រើការងារ ។ ដោយឡែកក្រុមហ៊ុនយ៉ាហ្សាគិដែលបច្ចុប្បន្នផលិតគ្រឿងបង្គុំប្រពន្ធ័ខ្សែភ្លើងរថយន្ត ហើយទៅថ្ងៃអនាគតគ្រោងផលិតសម្ភារៈកសិកម្ម និងផ្ទាំងស្រូបពន្លឺព្រះអាទិត្យនោះក៏បានចូលរួមបណ្ដុះបណ្ដាលធនធានមនុស្សដោយបញ្ជូនពលករកម្ពុជាទៅសិក្សាជំនាញនៅបរទេសផងដែរ ។ អ្វីដែលប្រជាជនកម្ពុជាចាប់អារម្មណ៍នោះ គឺការចូលរួមវិនិយោគរបស់ជប៉ុននៅកម្ពុជាបានបង្កើតឱកាសការងារជាច្រើនដល់យុវជនកម្ពុជា ។ ក្នុងចំណោមប្រជាជនជាង ១៤-លាននាក់មានប្រហែល ៥ លាននាក់ ជាយុវជនមានអាយុចាប់ ពី៣០-ឆ្នាំចុះក្រោម ហើយជារៀងរាល់ឆ្នាំ យុវជនដែលមានអាយុអាចចូលបម្រើការងារមានប្រហែលជា ៣ សែននាក់ ។ កម្លាំងពលកម្មនៅមានតម្លៃថោក បើប្រៀបធៀបជាមួយប្រទេសថៃ និងប្រទេសវៀតណាម និងភាពអនុគ្រោះផ្សេងៗទៀតកម្ពុជាជាចំណុចទាក់ទាញមួយសម្រាប់ការវិនិយោគរបស់ជប៉ុននាពេលអនាគត ។ តាមរយៈនេះ សកម្មភាពវិនិយោគរបស់ជប៉ុន នឹងរួមចំណែកកាន់តែច្រើនឡើងដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការបណ្ដុះបណ្ដាលធនធានមនុស្សរបស់កម្ពុជា ។ ប៉ុន្តែនៅទន្ទឹមនឹងនិន្នាការកើនឡើងនៃវិនិយោគបរទេសនៅកម្ពុជានោះ កម្ពុជាក៏ត្រូវតែខិតខំបង្កើនការត្រៀមខ្លួនថែមទៀតឱ្យបានល្អ ដើម្បីទទួលយកនូវនិន្នាការនេះប្រកបដោយប្រសិទ្ធភាព ជាពិសេសការបណ្ដុះបណ្ដាលបច្ចេកទេស និងមុខជំនាញដល់ពលករ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការលុបបំបាត់ការិយាធិបតេយ្យ ។/

តមកពីទំព័រទី ២១

តែកាក់កបនឹងកំណើនពីកម្ចីទិញផ្ទះ ។

នៅក្នុងរយៈពេល ១០ ខែនៃឆ្នាំ ២០១៣ ធនាគារ ANZ បានបញ្ជាក់ថាកម្ចីទិញផ្ទះនេះកើនឡើង ៣៥% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ ធនាគារអេស៊ីលីដាអះអាងថា មានអតិថិជន ១២ ៨៣៤ នាក់ នៅក្នុងទឹកប្រាក់ ១៥៩ លានដុល្លារបានរកកម្ចីទិញផ្ទះ គឺកើនឡើង ១៨% ។

### វិស័យអចលនទ្រព្យត្រីមាសទី៤

ក្រុមហ៊ុនវីត្រាស់ប្របភីធី ដែលជាក្រុមហ៊ុនរកស៊ីខាងអចលទ្រព្យដ៏ធំមួយនៅកម្ពុជាបានបញ្ជាក់ថា គិតមកដល់ត្រីមត្រីមាសទី ៤ ឆ្នាំ ២០១៣ ការផ្គត់ផ្គង់អគារអាផាតមិនថ្មីៗបានកើនឡើងដល់ចំនួនជាង ២០០ អគារ ដែលបានផ្ដល់ជាបន្ទប់សរុបប្រមាណ ៤ ០០០ បន្ទប់ ។ ដោយឡែកសេវាកម្មជួលការិយាល័យក៏រំពឹងថានឹងមានកំណើនទាំងការផ្គត់ផ្គង់ និងតម្រូវការផងដែរ ។

លោកបានឱ្យដឹងថា តម្លៃអាផាតមិនកម្រិត A សម្រាប់ជួល គឺមានតម្លៃចាប់ពី ១ ២០០ ដុល្លារអាមេរិកឡើង កម្រិត B គឺនៅក្នុងកម្រិតពី ៧០០ ដុល្លារទៅ ១ ២០០ ដុល្លារ និងកម្រិត C គឺចាប់ចាប់ពី ៧០០ ដុល្លារ ចុះក្រោម ។ ដោយឡែកការជួលការិយាល័យវិញនោះ គឺនៅក្នុងកម្រិត A តម្លៃចាប់ពី ១៤ ដុល្លារឡើង កម្រិត B គឺចាប់ពី ៨ ដុល្លារទៅ ១៤ ដុល្លារ និងកម្រិត C គឺចាប់ពីក្រោម ៨ ដុល្លារ នៅក្នុងមួយម៉ែត្រការេ ។

ដោយឡែកក្រុមហ៊ុនវីត្រាស់រៀលធី ដែលជាក្រុមហ៊ុនវិស័យអចលនទ្រព្យដូចគ្នាបានបញ្ជាក់ថា ជាទូទៅ អាផាតមិននៅទីក្រុងភ្នំពេញ នៅត្រីមត្រីមាសទី ៤ នេះ គឺមានចំនួន ២២០ កន្លែង ក្រៅពីនោះ គឺមាន ៧៣ កន្លែងទៀតកំពុងតែសាងសង់ ខណៈដែលខុនដូ គឺមាន ១២ កន្លែង ដែលសាង់សង់រួច និង ៥ កន្លែងកំពុងតែសាងសង់ ។ រីឯអគារការិយាល័យវិញ មានចំនួន ១៣៣ កន្លែង និង ៤៥ កន្លែងកំពុងតែសាងសង់ ។ ក្រៅពីនោះ នៅរាជធានី ភ្នំពេញ នៅមានតំបន់ឧស្សាហកម្មចំនួន ១០ កន្លែងទៀតដែលបានសាងសង់រួច ។ គម្រោងដែលបានសាងសង់ហើយ គឺវិនិយោគដោយក្រុមហ៊ុននៅក្នុងស្រុក និងក្រុមហ៊ុនអន្តរជាតិមានចំនួន ៤៩ គម្រោង និងកំពុងតែសាងសង់មានចំនួន ២៥ ក្រុមហ៊ុន ។

ក្រុមហ៊ុននេះបញ្ជាក់ថា គម្រោងអភិវឌ្ឍន៍ទាំងនេះក៏មានភាពវិជ្ជមានដែរ ដោយសារតែអត្រានៃការប្រើប្រាស់អគារនេះគឺមានខ្ពស់ ។ សម្រាប់អាផាតមិន អត្រានៃការប្រើប្រាស់មានចំនួន ពី ៨០ ទៅ ៩០% ខុនដូ មានពី ៦០ ទៅ ៧០% អគារការិយាល័យមានពី ៦០ ទៅ ៩០% និងតំបន់ឧស្សាហកម្មគឺមានពី ៨០ ទៅ ៩០% ។ ដោយឡែកជាទូទៅតម្លៃដីធ្លីនៅតំបន់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលជាតំបន់ថ្លៃជាងគេ បំផុតនោះ គឺជាមធ្យមគឺមានតម្លៃ ៣ ៣០០ ដុល្លារ នៅក្នុងមួយម៉ែត្រការ៉េ ។ តម្លៃដីនៅតំបន់នោះថោកបំផុតត្រឹម ១ ០០០ ដុល្លារ នៅក្នុងមួយម៉ែត្រការ៉េ ខណៈដែលថ្លៃបំផុត គឺ ៥ ៩០០ ដុល្លារ នៅក្នុងមួយម៉ែត្រការ៉េ ។/

# ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវលំជនបទដោយគ្រោះទឹកជំនន់ ឆ្នាំ ២០១៣ មានទំហំធំ





*ជំនន់ទឹកភ្លៀង និងទឹកទន្លេមេគង្គនៅក្នុងរដូវវស្សាឆ្នាំ ២០១៣ បង្កនូវការលិចលង់ខូចខាតដល់ភូមិករ ស្រែចម្ការ ផលដំណាំ និងហេដ្ឋារចនាសម្ព័ន្ធនានាជាច្រើន*

ជំនន់ទឹកភ្លៀងនិងទឹកទន្លេមេគង្គនៅក្នុងរដូវវស្សាឆ្នាំ២០១៣នេះ បានបង្កនូវការលិចលង់ខូចខាតដល់ភូមិករ ស្រែចម្ការ ផលដំណាំ ហេដ្ឋារចនាសម្ព័ន្ធនានាជាច្រើន ដែលក្នុងនោះក៏ប៉ះពាល់ និងបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរផងដែរដល់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងផ្លូវលំជនបទ ។

ទឹកជំនន់នេះបានពន្លិចស្រុក ក្រុង ខណ្ឌ ចំនួន ១២២ ស្មើ ៧១៩ ឃុំ សង្កាត់ នៅក្នុងខេត្តចំនួន ១៨ ។ខេត្តទាំង ១៨ នេះ រួមមាន ខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប បាត់ដំបង ប៉ៃលិន កំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង ស្វាយរៀង ព្រៃវែង កណ្តាល កំពង់ចាម ពោធិ៍សាត់ រតនគិរី កំពង់ឆ្នាំង ភ្នំពេញ និងមណ្ឌលគិរី ។

ខេត្តដែលប៉ះពាល់ធ្ងន់ធ្ងរជាងគេគឺខេត្តព្រៃវែង ដោយលិចលង់ឃុំចំនួន ៨៤ នៃស្រុក ក្រុងចំនួន ១៣ ។ បន្ទាប់មកខេត្តបាត់ដំបងចំនួន ៧៩ ឃុំ សង្កាត់ ខេត្តកំពង់ចាម ចំនួន ៧២ ឃុំ សង្កាត់ ខេត្តកណ្តាល ចំនួន ៦៥ ឃុំ សង្កាត់ ខេត្ត សៀមរាប ចំនួន ៥៦ ឃុំ សង្កាត់ ខេត្តកំពង់ធំ ចំនួន ៥៣ ឃុំសង្កាត់ខេត្តព្រះវិហារចំនួន៥១ឃុំសង្កាត់ ។ខេត្តដែលប៉ះពាល់តិចជាងគេគឺខេត្តមណ្ឌលគិរី ដោយមានតែឃុំចំនួន៣ប៉ុណ្ណោះដែលរងការប៉ះពាល់ ។

យោងតាមរបាយការណ៍របស់ក្រសួងធនធានទឹក និងឧតុនិយម បានបញ្ជាក់ថា ជំនន់ទឹកភ្លៀង និងជំនន់ទឹកទន្លេ បានប៉ះពាល់ និងបង្កការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រនៃរាជធានី និងខេត្តទាំង ១៨ គឺបានបង្កឱ្យខូចខាតទំនប់ចំនួន ១២៥ កន្លែង ស្មើនឹងប្រវែង ៣៩ ២០០ ម៉ែត្រ (ភាគច្រើនជាទំនប់ភ្លឺចទឹក) ខូចខាតភ្លឺ ប្រឡាយមេ និងភ្លឺប្រឡាយរងចំនួន ៦៣ ខ្សែ ស្មើនឹងប្រវែង ៩៦ ៥១០ ម៉ែត្រ សំណង់សិល្បការតូចៗ ៧៩ កន្លែង ។ ចំពោះសំណង់ធំៗពុំមានការប៉ះពាល់ទេ ដោយហេតុថាបណ្តាសំណង់ទាំងនោះកំពុងស្ថិតក្នុងដំណាក់កាលជួសជុល និងសាងសង់ ។ សរុបការខូចខាតហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ









ដោយសារទឹកជំនន់ក្នុងឆ្នាំ ២០១៣ នេះ គិតជាទឹកប្រាក់ដែលត្រូវធ្វើការជួសជុលឡើងវិញប្រមាណ ១០ លានដុល្លារ ។

គួរបញ្ជាក់ផងដែរថា ខេត្តដែលរងការប៉ះពាល់ និងខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រធ្ងន់ធ្ងរជាងគេ គឺខេត្តបន្ទាយមានជ័យ ដោយខូចខាតទំនប់ ១៤ កន្លែង ស្មើនឹង ១៦ ០១១ ម៉ែត្រ ខ្នងប្រឡាយ ១១ ខ្សែ ស្មើនឹង ២៦ ៣៧០ ម៉ែត្រ ។ បន្ទាប់មកខេត្តបាត់ដំបង ខូចខាតទំនប់ ប្រវែង ១ ២៤៧ ម៉ែត្រ និងខ្នងប្រឡាយប្រវែង ៣១ ០៧២ ម៉ែត្រ ខេត្តព្រៃវែង ខូចខាតទំនប់ចំនួន ៨ កន្លែង ប្រវែង ៤ ៨៤០ ម៉ែត្រ និងខ្នង ប្រឡាយប្រវែង ១០ ០៧០ ម៉ែត្រ ខេត្តកំពង់ធំខូចខាតទំនប់ប្រវែង ៤ ៤១៥ ម៉ែត្រ ។

ទិសដៅចំពោះមុខសម្រាប់ការស្តារ និងជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រនេះ ត្រូវបានកំណត់ចំពោះទំនប់ ប្រឡាយ សំណង់សិល្បការជាអាទិភាព ។ ពេលនេះក្រសួងធនធានទឹក និងឧតុ-និយមកំពុងតែធ្វើការសិក្សា និងវាយតម្លៃ ។ ប៉ុន្តែការស្តារ និងជួសជុលនៅទីកន្លែងមួយចំនួនក៏នឹងប្តូរនូវវិធីសាស្ត្រផងដែរ ។

ដោយឡែកយោងតាមរបាយការណ៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ បានឱ្យដឹងថា ផ្លូវលំជនបទដែលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់នេះដែរមានចំនួន ៨០១ ខ្សែ ស្មើប្រវែង ៦ ២៨០ គីឡូម៉ែត្រ ។ ផ្លូវទាំងនេះនៅក្នុង ១៩ រាជធានី និងខេត្ត ។ ក្នុងចំណោមផ្លូវរងផលប៉ះពាល់ ប្រវែង ៦ ២៨០ គីឡូម៉ែត្រនេះបានលិចទឹកទាំងស្រុង ប្រវែង ៣ ៥៦៩ គីឡូ-ម៉ែត្រ បណ្តាលឱ្យខូច ខាតតិចតួចប្រវែង ១ ៥៤៧ គីឡូម៉ែត្រ ខូច មធ្យម ប្រវែង ១ ១៥៥ គីឡូម៉ែត្រ ខូចធ្ងន់ធ្ងរ ប្រវែង ៨៤៨ គីឡូម៉ែត្រ និង ខូចសំណង់សិល្បការចំនួន ២៦ កន្លែង ។ ការខូចខាតនាឆ្នាំ ២០១៣ នេះមានទំហំធំជាងការខូចខាត ដោយទឹកជំនន់នាឆ្នាំ ២០១១ ។

ចំពោះមុខ ដើម្បីស្តារ និងជួសជុលឡើង វិញនូវផ្លូវលំជនបទទាំងនេះ គណៈកម្មការអន្តរក្រសួងនឹងជ្រើសរើសយកផ្លូវណាដែលខូចធ្ងន់ធ្ងរយកមកធ្វើមុន ដោយផ្តោតសំខាន់លើការសាងសង់លូ និងស្ពានច្រើនជាងការចាក់ដីលប់កន្លែងដែលបានបាក់ដាច់ ដោយសារទឹកជំនន់ដដែលៗនោះ ។

ការសាងសង់លូ និងស្ពាននៅលើផ្លូវលំជនបទត្រូវចំណាយថវិកាអស់ច្រើនជាងការចាក់ដីលប់ និងលើកតួផ្លូវ ។ ប៉ុន្តែអ្នកជំនាញបានពន្យល់ថា បើមិនបើកផ្លូវទឹកឱ្យបានច្រើនទេ ផ្លូវទាំងនោះនឹងនៅតែត្រូវខូចទៅវិញពេលមានទឹកជំនន់កើតឡើងដោយសារផ្លូវទឹកត្រូវបានទប់ ឬត្រូវបានគេចាក់ដីលប់អស់ ព្រមពេលជាមួយនឹងអាកាសធាតុមានការប្រែប្រួលខ្លាំង និងការអភិវឌ្ឍមិនបានព្រមគ្នា ។ ផ្លូវលំជនបទភាគច្រើនជាផ្លូវដីក្រហម និងមានសំណង់សិល្បការតូចៗ ប្រៀបបានដូចជាទំនប់ទប់ទឹកទុក ។ ពេលមានភ្លៀងធ្លាក់ខ្លាំងបណ្តាលឱ្យមានទឹកជំនន់លិចលង់ភូមិដ្ឋាន និងស្រែចម្ការ ។

ក្នុងការជួសជុលផ្លូវលំជនបទឡើងវិញនាពេលខាងមុខនេះមានបីដំណាក់កាលផ្សេងគ្នា គឺផ្លូវត្រូវធ្វើការជួសជុលបន្ទាន់ដោយថវិការបស់រដ្ឋាភិបាល ផ្លូវត្រូវស្តារឡើងវិញដោយមានការចូលរួមពីដៃគូអភិ-វឌ្ឍន៍នានា និងផ្លូវដែលត្រូវជួសជុលតិចតួច និងធ្វើការថែទាំ ។/



# ចម្រៀង និងតន្ត្រីប្រឹន ឬប្រឹន



*ចម្រៀង និងតន្ត្រី ប្រឹន ឬប្រឹន ជាការពេញនិយមរបស់ប្រជាជនកម្ពុជា មានប្រជាប្រិយភាពឡើងវិញនាឆ្នាំ ១៩៨២*

តាមការស្រាវជ្រាវអ្នកស្រុកដែលរស់នៅម្តុំសំរោងចុងកាលឡើងទៅលើគេនិយមហៅថា "ប្រឹន"។ ក្នុងប្រទេសកម្ពុជា ចម្រៀងប្រឹន មាននៅសេសសល់តែក្នុងទឹកដីខេត្តសៀមរាប-ឧត្តរមានជ័យ និងបន្ទាយមានជ័យ។ រីឯនៅខេត្តអ៊ូប៊ុន-ប៊ុរីរម្យ-ស៊ីសាកេត និងសុរិន្ទ្រប្រទេសថៃវិញ គេនិយមហៅថា "ចម្រៀងកន្ទ្រឹម" ។

ចម្រៀងនិងតន្ត្រីប្រឹននេះបានកើតមានប្រជាប្រិយភាពឡើងវិញក្នុងទូទាំងប្រទេសខ្មែរក្នុងឱកាសមហាសន្និបាតតន្ត្រីសម័យទូទាំងប្រទេសលើកទី ១ នាឆ្នាំ ១៩៨២ ដែលប្រារព្ធធ្វើនៅក្រុងភ្នំពេញ ដែលកាលនោះក្រុមសិល្បករខេត្តសៀមរាបបានលើកយកមកសម្តែងបង្ហាញជូនអង្គសន្និបាត និងបានទទួលការគាំទ្រពេញចិត្តពីទស្សនិកជន។

ការឆាប់ទទួលយកបាន និងល្បីសុះសាយបែបនេះ គឺយោងទៅលើសាច់ភ្លេងពិរោះមានទឹកដមផ្សំជាមួយទំនុកបែបកំប្លែង និងព្រមជាមួយសំឡេងគ្រៀមភាសាដ៏ស្រទន់របស់អ្នកសៀមរាបនោះផង។

"ប្រឹន ឬប្រឹន"ជាគ្រៀមភាសារបស់បងប្អូនជនជាតិភាគតិចខ្មែរលើ កួយ មានន័យថា "សប្បាយរីករាយ" ប្រភេទតន្ត្រីប្រឹននេះកើតមានក្នុងភូមិភាគឧត្តរនាសម័យមហានគរ ហើយនៅជិតស្និទ្ធនឹងប្រជារាស្ត្រខ្មែររហូតមកដល់បច្ចុប្បន្ន។

ប្រភេទតន្ត្រីប្រឹននេះ គេច្រើនច្រៀងលើកទំនុក របៀបកំប្លុកកំប្លែង បន្តុះបង្អាប់ចំពោះដៃគូដើម្បីឱ្យរំភើបតបតគ្នាវិញ ចោទឆ្លើយគ្នាដូចជាច្រៀងអាយ៉ៃ ។ ចុងបញ្ចប់គេនិយមប្រើពាក្យ "តាឡុក" ជាគ្រៀមភាសារបស់អ្នកសៀមរាប មានន័យថា "កំប្លុកកំប្លែង" ។ពាក្យតាឡុកនេះ អ្នកចម្រៀងម្នាក់ៗខិតខំលើកទំនុកប្លែកៗមួយល្បះ ពីរល្បះម្នាក់ម្តងៗប្រដេញជាមួយដៃគូ។ ជួនកាលគេចែកជាក្រុមដូចប្រប់កៃដើម្បីជួយដោះទាល់គ្នា។ ឯការជោគជ័យ ឬបរាជ័យ គឺនៅត្រង់អ្នកស្តាប់ដែលហោកញ្ជ្រៀវ ឬស្ងៀមស្ងាត់។ ពេលកំពុងច្រៀងឆ្លងឆ្លើយ ក៏ត្រូវរាំដូចអាយ៉ៃដែរ ប៉ុន្តែទន់ភ្លន់បង្អួសតាមដង្ហើមសាច់ភ្លេង ។

កាលពីសម័យមុន "អំឡុងទសវត្សឆ្នាំ១៩៤០" នៅរដូវច្រូតកាត់ប្រមូលផល ជាពិសេសជិតរដូវចូលឆ្នាំខ្មែរ (ខែចេត្រ) អ្នកស្រុកវ៉ារិនតែងប្រមូលគ្នាចេញដំណើរមកកាន់ប្រាសាទអង្គរធំ និងអង្គរតូច ដើម្បីមកលេងភ្លេងប្រឹនថ្វាយវត្ថុស័ក្តិសិទ្ធិនៅអង្គរ ។ គេតែងធ្វើដំណើរបណ្តើរ ច្រៀងរាំតាមផ្លូវបណ្តើរ និងសម្តែងស្វាគមន៍ដល់អ្នកភូមិស្រុកប្រសិនបើមានការគួរសមចំពោះពួកគេ។ តាមចាស់ៗដំណាលតគ្នាថា នៅសម័យអង្គរគេក៏យកប្រភេទតន្ត្រីនេះមកសម្តែងថ្វាយស្តេចនៅទីប្រាសាទទាំងពីរនេះដែរ ។ ឯអ្នកស្រុកខ្លះក៏យកតន្ត្រីនេះទៅលេងថ្វាយវត្ថុស័ក្តិសិទ្ធិដើម្បីលាបំណន់ផ្សេងៗផងដែរ ហើយតន្ត្រីនេះក៏លេងសំដៅបន់ស្រន់សុំទឹកភ្លៀងសម្រាប់ឆ្នាំថ្មី ដើម្បីធ្វើស្រែចម្ការឱ្យបានគ្រប់គ្រាន់។ គឺខុសប្លែកពីរបាំត្រុដិនាងមេវ រាំថ្វាយវត្ថុស័ក្តិសិទ្ធិសុំទឹកភ្លៀងនៅពេលកំពុងមានភាពរាំងស្ងួត ។

## របៀបសម្តែងតន្ត្រីប្រឹន

-សម្លៀកបំពាក់ : គេច្រើននិយមស្លៀកហូលជីបភ្លីមុខ អាវកមូលដៃវែង ឬខ្លី នៅពេលមកលេងថ្វាយនៅអង្គរ គេបន្ថែមពាក់មកុដដែលរចនាពីក្រដាសពណ៌មាស និងមានពាក់កងដៃកងជើងទៀតផង ។

-ឧបករណ៍តន្ត្រី:កាលពីដើមគេផ្លុំគែនក្រោយមកដោយមានការខ្វះខាត គេយកប៉ីអ ឬទ្រមកជំនួស។ ឧបករណ៍ដែលសំខាន់បំផុតសម្រាប់តន្ត្រីនេះ គឺគែន ឈឹង ក្រាប និងស្គរ ដោយសារតន្ត្រីនេះមានជីវិតជិតស្និទ្ធទៅនឹងជីវភាពស្រុកស្រែ គេក៏បន្ថែមឧបករណ៍មួយទៀត គឺចងដំបែនឹងឈើ ឬឫស្សីពីងពង់កម្ពស់ប្រហែល ១,៦០ម ពីលើមួយពីក្រោមមួយ ចងដោយខ្សែគោចន្លោះដំបែគេចងចង្រ្កង់ ហើយកាន់ឈើនោះដូចជាអង្រែបុកទៅដីតាមចង្វាក់ភ្លេង ។

-របៀបរាំ :ការរាំមានចលនាដៃលើកបង្វិលកាច់ឡើងទៅលើរួចចុះក្រោម ដៃឆ្វេង និងស្តាំមានលំនាំដូចគ្នា ធ្វើដំណើរស្ថិតក្នុងចលនាស្របដៃស្របជើង ពេលខ្លះឈរហ្នឹងមួយកន្លែង គេគោះចុងជើងបន្តើតកែង និងយកកែងគោះអុកទៅវិញទាល់តែខូងដី ។

-ទំនុកច្រៀង:ផ្តើមដំបូង (ភាសាបែបរដឹន)

-ខ្ញាតសូមគោរពពុកម៉ែទាំងអស់គ្នា យាយ តាមីងមា បងប្អូនទាំងឡាយ ញាតិមិត្ត តូចធំរស់នៅជិតឆ្ងាយ ដោយក្តីរីករាយ អស់ពីដួងចិត្ត ។

-ម្តាយអើយ..... ខ្ញាតមកពីនាយ ដល់ជាយរបង សុំផ្លូវទៅផង បាន ឬមិនបាន ។

-ជើងជាន់របង ដៃគងសម្រាស់ស្រែកហៅ

លោកម្ចាស់ ច្រកចូលខាងណា ? ផ្ទះធំស្រឡះ ស្រែកហៅលោកម្ចាស់ ពួកខ្ញុំសុំចូលរោង .... ។

បើម្ចាស់ផ្ទះអបអរទទួលហើយ គេក៏ផ្ដើមច្រៀង ទំនុកផ្សេងតាមបរិយាកាសអំណោយផល ។ នៅពេលបញ្ចប់ច្រៀង និងរាំ ម្ចាស់ផ្ទះគោរព និងស្វាគមន៍ដល់ក្រុមសិល្បៈ ដោយជូនស្លាម្លូ ទៀន ៥ ធូប ៥ និងប្រាក់កាសទៅតាមលទ្ធភាព ដាក់លើជើងពានជូនសិល្បករ ។ អ្នកច្រៀងជាអ្នកទទួលហើយជូនពានទៅម្ចាស់ផ្ទះវិញដោយច្រៀងថា :

-ត្រង់បាត់ត្រង់គង់ ទ្រព្យមានសំណាង
ទុកដាក់ចែកផង របស់ផងអ្នក ។

-គេឱនគោរពបន្តិចហើយទើបច្រៀងបន្តទៀតបែបកំប្លែង

ម្ដាយអើយ ...ផ្គរលាន់តាលីទី ...អ្នកស្រុកមិនដែលឮ ... ប្រពន្ធវៃប្ដី ...វៃទៅវៃមក ...បែកក្រឡទឹកត្រី ...ប្រពន្ធវៃប្ដីបែកឆ្នាំងត្រីខ ...។

-ម្ដាយអើយ ...ស្រីអើយស្រីស ...សអាំងឡាំង ...បាយនៅពេញឆ្នាំង អង្គុយអាំងផេះ ដៃប្រឡេះកំពឹងពួយ ...មិនយកវែកជួយ...បាយឆៅពេញឆ្នាំង ...។

-សន្ទូចបងមួយ ពត់វង់ត្រឡោក ...បង្កៃលើគោក ...ជាប់ត្រីកញ្ជនដៃ សន្ទូចបងធំ ...ស្ទូចត្រីដីរ ... ស្ទូចបឹងអូនស្រី ... ជាប់ត្រីកន្ត្រប់ ។

-ម្ដាយអើយ...ស្ដើងអើយស្រីស្ដើង...អូនធំឆាប់ឡើង ...ឱ្យទាន់ឆ្នាំបង ហូបបាយផឹកទឹក មួយថ្ងៃប្រាំពីរដង ... ឱ្យទាន់ឆ្នាំបង ... ឆ្នាំក្រោយរៀបការ ។

-ឆ្នាំនេះទឹកធំ ... ឆ្នាំក្រោយទឹកតូច ...យើងរួចហើយណា ...ឆ្នាំក្រោយរៀបការ អូនហើយនិងបង ។

-បើមិត្តយកប្ដី ...កុំយកប្ដីសក់ញែក...យកក្បាលក៏ទំពែក ...ចេះប៉ុនធន់ថ្ងៃ ទំពែកក៏ទំពែកចុះ ...ឱ្យតែទំពែកជា ...ទំពែកដល់លលាដ៏...មិត្តអើយកំព្រាចៃ ទំពែកចាំងថ្ងៃ ... ចៃរត់កំប៉ាងជើង ។

-ម្ដាយអើយ...ផ្គរលាន់ម្ខាងដុប...ស្រីឈប់ម្ខាងអូរ...បងអើយកុំមកអូនស៊ីធំណាស់ស៊ីជ្រូកប្រាំផ្លូង (១) ស៊ីទន្សោងប្រាំបុះ (២) បើមិនបានប៉ុណ្ណោះ ស្រីស្បថមិនយកប្ដី ។

-ម្ដាយអើយ...ផ្គរលាន់ឯលើមេឃ...បានប្ដីខ្វាក់ភ្នែក...ប៉ិនដាំបាយឆ្ងាញ់ ចេះស្លត្រីផ្លក់...ចេះបុកត្រីក្រាញ់...ចេះដាំបាយឆ្ងាយ...ខ្លោចផងឆៅផង ... ។

-ម្ដាយអើយ...កន្ទុប..កន្ទុបអើយ...កន្ទុបបាយផ្អូម....បណ្ដាច់ក្បិននោម...ក្រោមកុដិលោកតា ...លោកគ្រូឃើញភ្លាម...ដេរបន្ទុចបណ្ដាសារ...នោមដាក់វត្តវ៉ា...លង់លោកតាបីអង្គ ។

-ម្ដាយអើយ...តាក់ទីងកណ្ដៀង។...តាក់ទីងកណ្ដៀង។ បានប្ដីពីក្មេង មិនដែលបានលេង ម្លាក់ម្លូង (៣) ។

-ស្រីសជង្គង់កុក...អូនល្អតែមុខ...គគូទដូចឆ្នាក់ទ្រ(៤) ប្រុសណាហ៊ានយក៏សម្បូរតែកូនងាប់...។

-មាសអើយស្រីមាស...ក្រយៅក្រោមថ្ងាស ហៅមាសកន្ទ្រាយទ្រាក់...បើបានទៅអ្នកណាចម្រើនបុណ្យចម្រើនសក្ដិ...ហៅមាសកន្ទ្រាយទ្រាក់...ចម្រើនសក្ដិប្ដី ។

-នួនអើយស្រីនួន...ដូចផ្កាត្រកួន...ដុះលើខ្នងថ្នល់...បងចាប់ទំពក់...ថ្ពក់នួនមិនដល់...ដុះលើខ្នងថ្នល់...រីកឯងរោយឯង ។

-សួសអើយស្រីសួស...បងលាទៅបួស...មើលម្ដាយបងផង...ប្រទះអុសស្រីកាប់ ប្រទះទឹកស្រីដង...មើលម្ដាយបងផង....ទំរាំដល់បងសឹក ។

-បងសឹកស្ដាយផ្នួស...បងបួសស្ដាយស្រី...ស្ដាយស្រែកាប់ថ្មី...មិនទាន់បានបិទភ្លឺ ។

-ពពិចសស្លាប...ចាបសកន្ទុយ...ស្រីនៅធ្វើអ៊ុយ...ក្រមុំសៅកែ...ដូចផ្លែនទោងសាញ ។

-ផ្គរលាន់ឯជើង ត្រពាំងមានឈ្លើង បងយកជើងជាន់ត្រពាំងឯទៀត រាប់រយម៉ឺនពាន់ បងយកជើងជាន់ ផស់ (៥) គេទៅហើយ ។

-ច្រៀងមកដល់ត្រឹមនេះគេផ្អាកបន្តិចហើយច្រៀងជូនពរបញ្ចប់ ។

-លាហើយលាលាត...លាអស់មិត្តញាតិ...សន្ដានប្រុសស្រី សូមជូនពរអ្នក...ត្រជាក់អង្វែង ...អាយុសុំវែង ១២០ ឆ្នាំប្លាយ លាហើយលាឡង...លាគ្រប់បីដង...លាឈប់លេងហើយ ។/

(១) ប្រាំផ្លូង = ប្រាំងហ្លួង (២) បុះ = ៨ ក្បាល
(៣) ម្លាក់ម្លូង = ម្លូង (៤) ឆ្នាក់ទ្រ = ឆាកទ្រ

"ស្រាវជ្រាវពីសៀវភៅតន្ត្រី និងជីវិតខ្មែរ"

តមកពីទំព័រទី ៤

*សមិទ្ធផលដែលយើងសម្រេចបាន នឹងធ្វើឱ្យខ្លួនយើងបាត់បង់ការប្រុងប្រយ័ត្ន ហើយឈរនៅទ្រឹងមួយកន្លែង ដែលជាស្ថានភាពថយក្រោយនៅចំពោះមុខដំណើរវិវត្តន៍រីកចម្រើន ។ ៣៥ ឆ្នាំ នៃការដឹកនាំគណបក្សយើងមានគុណសម្បត្តិធំធេងណាស់ ប៉ុន្តែចៀសមិនផុតពីចំណុចខ្វះខាតផ្សេងៗដោយកត្តាសត្យានុម័តផង និងអត្តនោម័តផងនោះឡើយ ជាពិសេសកត្តាអត្តនោម័ត ។ យើងគប្បីមើលឱ្យឃើញថា ឆ្លងតាមលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ នេះ បានបង្ហាញថា ប្រជាជនកម្ពុជាចង់ឱ្យរាជរដ្ឋាភិបាលថ្មីដោះស្រាយបញ្ហាជាមូលដ្ឋានដែលទាក់ទងទៅនឹងជីវភាពផ្ទាល់របស់គេ ព្រមទាំងការពង្រឹងនូវភាពស្អាតស្អំ យុត្តិធម៌ និងសមធម៌ក្នុងសង្គម ។ អាស្រ័យហេតុនេះ គណបក្សគ្រប់ថ្នាក់ មន្ត្រីគ្រប់រូបនៃគណបក្សប្រជាជនកម្ពុជា គប្បីយល់ដឹងអំពីបរិបទថ្មីនេះ ខិតខំពង្រឹងការឯកភាពទាំងខាងទស្សនៈ គោលជំហរ និងសកម្មភាព ដើម្បីប្រមូលផ្ដុំកម្លាំងអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ជាពិសេស ការបន្តអនុវត្តដោយដាច់ខាតបណ្ដាកំណែទម្រង់រដ្ឋដ៏ទូលំទូលាយ និងស៊ីជម្រៅ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយឱ្យទទួលបានលទ្ធផលខ្ពស់ ។ ឆ្ពោះទៅ គោលដៅនេះ ស្មារតី ៧ មករា នៅតែជាកម្លាំងដ៏ខ្លាំងក្លា និងមុតស្រួច ដែលជួយជំរុញឱ្យយើងសម្រេចបានលទ្ធផលធំៗថ្មីៗទៀតជូនប្រទេសជាតិ និងប្រជាជន ហើយវាយបំបាក់បាននូវរាល់ល្បិចកលប្រទូសរ៉ាយនានារបស់ពួកប្រឆាំងនៅគ្រប់ស្ថានភាព និងគ្រប់កាលៈទេសៈ ។*

*គឺមានតែផ្អែកលើមូលដ្ឋាននេះ ទើបធានាបាននូវការលើកកម្ពស់ជានិច្ចនូវអត្ថន័យនៃជ័យជម្នះ ៧ មករា និងធានាតួនាទីជាប្រវត្តិសាស្ត្ររបស់គណបក្សយើងនៅក្នុងសង្គមជាតិ ។/*

**ទស្សនាវដ្ដីប្រជាជន**

# បទសម្ភាសន៍ ស្មារតី ៧ មករា ស្ថិតនៅជានិច្ចក្នុងបេះដូងរបស់ប្រជាជនកម្ពុជា

*៧ មករាគឺជាប្រភពនៃជ័យជម្នះ និងការអភិវឌ្ឍ ។ ស្មារតី៧មករានៅតែរស់រវើក និងភ្លឺចិញ្ចាចចិញ្ចែង ជានិច្ចក្នុងបេះដូងរបស់ប្រជាជនកម្ពុជាគ្រប់ៗរូប និងគ្រប់ជំនាន់ ។ ៧មករាបានបំភ្លឺផ្លូវយើងគ្រប់ៗគ្នានៅក្នុងជំហានឆ្ពោះទៅកាន់ជោគជ័យដែលបានប្រែក្លាយមាតុភូមិយើងពីគំនរផេះផង់ឱ្យមានជីវិតរស់ឡើងវិញ មានការរីកចម្រើនរហូតដល់បច្ចុប្បន្ន ។ អបអរសាទរខួបអនុស្សាវរីយ៍លើកទី ៣៥នៃទិវាជ័យជម្នះ៧មករា (៧ មករា ១៩៧៩-៧ មករា ២០១៤) ទស្សនាវដ្តីប្រជាជនបានជួបសម្ភាសន៍ជាមួយប្រជាជនដោយរំឭកឡើងវិញនូវអតីតកាល ដែលយើងធ្លាប់បានឆ្លងកាត់ និងបច្ចុប្បន្នកាលដែលជីវិតរបស់យើងកំពុងតែស្ថិតនៅក្នុងសុភមង្គល ទឹកដីយើង ស្ថិតក្នុងការអភិវឌ្ឍយ៉ាងរស់រវើក។ ខ្លឹមសារនៃបទសម្ភាសន៍មានដូចខាងក្រោម :*



❀ព្រះតេជគុណ **ម៉េង ប៊ុនធឿន** ព្រះជន្ម ៣០ ព្រះវស្សា គង់នៅវត្តអង្គតាចាន់ ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានមានសង្ឃដីកាថា : អាត្មាភាព គឺជាពលរដ្ឋម្នាក់ដែលបាននិងកំពុងរស់នៅក្នុងបរិយាកាសមួយប្រកបដោយសុខសន្តិភាពពេញបរិបូរណ៍ មានសិទ្ធិសេរីភាពសព្វបែបយ៉ាង។ អាត្មាបានឃើញជាក់ស្តែងនូវការអភិវឌ្ឍនានាទាំងទីក្រុងទាំងជនបទ ជាពិសេសគឺវត្តអារាមត្រូវបានកសាងនៅគ្រប់ទីកន្លែងដើម្បីឱ្យពុទ្ធបរិស័ទបានទៅគោរពបូជា ។ អាត្មាភាពមិនអាចបំភ្លេចបានឡើយនូវគុណបំណាច់របស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ដែលបានរំដោះប្រទេសជាតិពីរបបប្រល័យពូជសាសន៍ និងដឹកនាំការអភិវឌ្ឍប្រទេសប្រកបដោយភាពសម្បូររុងរឿង។ អាត្មាកើតមិនទាន់របបប្រល័យពូជសាសន៍នោះទេ ប៉ុន្តែឆ្លងកាត់ការរៀនសូត្រ និងការនិយាយប្រាប់ពីសំណាក់ចាស់ៗទើបដឹងច្បាស់លាស់អំពីភាពសាហាវយង់ឃ្នងរបស់ពួកខ្មែរក្រហម។ គេសម្លាប់ប្រជាពលរដ្ឋគ្មានញញើតដៃ ហើយជនរងគ្រោះសុទ្ធតែជាខ្មែរដូចគ្នា មិនគួរលាបពណ៌គ្នា ចោទគ្នាថាជាខ្មាំង រួចយកទៅសម្លាប់បែបនេះសោះ ។ ដោយសារគុណបំណាច់នៃថ្ងៃ ៧ មករា ទើបប្រជាជនយើងបានសុខសន្តិភាព ប្រទេសជាតិមានការរីកចម្រើន ហើយប្រជាជនបានចាត់ទុកថ្ងៃ ៧ មករា ជាថ្ងៃកំណើតទី ២ របស់គាត់។



*❀លោកយាយ **ហ៊ាង លី** អាយុ ៧៥ ឆ្នាំ រស់នៅសង្កាត់មនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី មានប្រសាសន៍ថា : ថ្ងៃ ៧ មករា ១៩៧៩ គឺជាថ្ងៃដ៏មានគុណធំធេងមិនអាចកាត់ថ្លៃបាន ព្រោះថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាបានរំដោះប្រជាជនទូទាំងប្រទេសឱ្យមានជីវិតរស់រានឡើងវិញ មានសុខសន្តិភាព សេរីភាព និងជីវភាពប្រសើរ។ កាលពីមុននោះក្នុងពេលដែលប្រទេសធ្លាក់ក្នុងសង្គ្រាម យើងមានតែការរត់លូន ព្រាត់ប្រាស់ និរាសគ្មានទីបញ្ចប់ ឪពុកម្តាយ ព្រាត់កូន ប្តីព្រាត់ប្រពន្ធ មួយថ្ងៃៗមានតែការបង្ហូរឈាម ការកាប់សម្លាប់សឹងតែគ្មានទីបញ្ចប់។ ប៉ុន្តែទិវា ៧ មករា បញ្ចប់ទាំងស្រុងនូវថ្ងៃអពមង្គលទាំងនោះ។ ឥឡូវនេះមានមនុស្សខ្លះគេចង់បំផ្លាញសុខសន្តិភាពរបស់កម្ពុជាដោយពួកគេញុះញង់ បំបែកបំបាក់ សង្គមជាតិទៀតហើយ។ ខ្ញុំមិនយល់ព្រមសោះឡើយ ហើយខ្ញុំនៅតែគាំទ្រទិវា ៧ មករា គាំទ្រសម្តេចទាំងបីឱ្យបន្តដឹកនាំប្រទេសទៅមុខទៀត។*



❀ អ្នកស្រី **សើ សម្រស់** អាយុ ៤៧ ឆ្នាំ រស់នៅភូមិរោងម៉ាស៊ីន សង្កាត់អូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយ-មានជ័យ ជាជនជាតិចាមបានបញ្ជាក់ថា : ៣៥ ឆ្នាំកន្លងមកនេះជីវិតខ្ញុំបានឆ្លងកាត់នូវរឿងរ៉ាវជាច្រើនក្នុងការកសាងជីវភាពរស់នៅ។ ក្រោយរំដោះភ្លាម គ្មានអ្វីទាំងអស់ ប៉ុន្តែ ៣៥ ឆ្នាំក្រោយជីវភាពគ្រួសារខ្ញុំមានភាពប្រសើរ មិនជួបការលំបាកខ្វះមុខខ្វះក្រោយទៀតទេ។ ក្នុងរយៈពេលនេះខ្ញុំឃើញថាមានតែគណបក្សប្រជាជនកម្ពុជាទេ ក្រោមការដឹកនាំរបស់សម្តេចទាំងបីដែលធ្វើឱ្យប្រទេសជាតិបានរីកចម្រើន ធ្វើឱ្យជីវភាពប្រជាជនបានធូរធារ។ អ្វីដែលយើងមានក្នុងដៃហើយនោះសូមកុំបោះបង់ចោលឱ្យសោះ។ ពួផ្គរកុំចាក់ទឹកពាងចោល ព្រោះយើងធ្លាប់បានឆ្លងកាត់រឿងរ៉ាវទាំងនោះសព្វគ្រប់អស់ហើយ។ ខ្ញុំបានរស់ដោយសារថ្ងៃ ៧ មករា ប្រជាជនកម្ពុជាទាំងអស់ក៏បានរួចរស់ជីវិតឡើងវិញដោយសារថ្ងៃ ៧ មករានេះដែរ។ ហេតុអ្វីយើងត្រូវបំភ្លេច? ធម្មតាទេ ក្នុងការរស់នៅវាតែងតែជួបរឿងនេះជួបរឿងនោះដោយចៀសមិនផុត ប៉ុន្តែយើងក៏មិនត្រូវយករឿងកំប៉ិកកំប៉ុកមួយមកធ្វើជាដើមចម ហើយបោះបង់ចោលនូវផលប្រយោជន៍ជាអាយុជីវិតរបស់យើងនោះទេ។



*❀កញ្ញា **សុភ័ណ្ឌ** អាយុ ១៨ ឆ្នាំ រស់នៅភូមិលេខ ២ សង្កាត់លេខ ៤ ក្រុងព្រះសីហនុ បានឱ្យដឹងថា : ថ្វីត្បិតខ្ញុំកើតមិនទាន់ថ្ងៃ ៧ មករា ប៉ុន្តែខ្ញុំជាមនុស្សម្នាក់ដែលបានចាប់បដិសន្ធិពីឪពុកម្តាយខ្ញុំដែលបានរួចរស់ជីវិតដោយគុណបុណ្យថ្ងៃ ៧ មករា ។ បច្ចុប្បន្ននេះក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ជាពិសេសសម្តេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី*

*ប្រទេសជាតិយើងមានការរីកចម្រើន និងអភិវឌ្ឍន៍យ៉ាងច្រើនឥតគណនា។ មានផ្លូវ ថ្នល់ សាលារៀន ស្ពានថ្ម វត្តអារាម និងសមិទ្ធផលជាច្រើនដទៃទៀតត្រូវបានកសាងឡើងជាហូរហែរ។ ប្រជាជនទូទៅមានសិទ្ធិសេរីភាពពេញលេញ មានការងារធ្វើមានជីវភាពធូរធារដោយអ្នកខ្លះមានផ្ទះថ្ម ផ្ទះឈើតូចធំរស់នៅយ៉ាងសមរម្យ។ ឯសម្ភារៈប្រើប្រាស់មធ្យោបាយធ្វើដំណើរជាទូទៅសូម្បីតែប្រជាជន ខ្លះដែលនៅក្រក៏គាត់មានម៉ូតូ ១ គ្រឿងដែរក្នុងគ្រួសារ។ សរុបសេចក្ដីមក អ្វីៗទាំងអស់នេះពិតជាកើតឡើងក្រោយថ្ងៃ ៧ មករា ក្រោមការដឹកនាំរបស់គណបក្សប្រជាជន និងការខិតខំប្រឹងប្រែងមិនចេះនឿយហត់របស់ប្រជាជនយើងទាំងអស់គ្នា។*



❋លោក **ប្រែង ផល្លា** អាយុ ៤៧ ឆ្នាំ រស់នៅក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី បានមានប្រសាសន៍ថា: ថ្ងៃ ៧ មករា គឺជាពេលវេលាមួយដែលរូបខ្ញុំ ក្រុមគ្រួសារខ្ញុំមានជីវិតរស់រានរួចផុតពីការស្លាប់។ ខ្ញុំគិតថាប្រជាជនកម្ពុជាទូទាំងប្រទេសក៏មិនខុសពីរូបខ្ញុំដែរ គឺត្រូវបានរំដោះរួចផុតពីរបបប្រល័យពូជសាសន៍ ហើយសព្វថ្ងៃកំពុងរស់នៅក្នុងសុខសន្តិភាពយ៉ាងពេញលេញ ។ មានមនុស្សខ្លះបានបំភ្លេចអនុស្សាវរីយ៍ទាំងអស់នេះបាត់ទៅហើយ ជាពិសេសប្អូនៗយុវជនជំនាន់ក្រោយមួយចំនួនក៏មិនបានដឹងច្បាស់អំពីព្រឹត្តិការណ៍ទាំងនេះ ។ ប៉ុន្តែសច្ចធម៌នៃប្រវត្តិសាស្ត្រមិនអាចអ្នកណាបំភ្លេចបានទេ ទោះអ្នកនោះមកពីជើងមេឃណាក៏ដោយ។ មានថ្ងៃនេះទេ បើគ្មានថ្ងៃ ៧ មករា? បើគ្មានថ្ងៃ ៧ មករា យើងទាំងអស់គ្នាមុខជាស្លាប់បាត់ទៅហើយ ដូច្នេះតើយើងបានថ្ងៃនេះពីណាមក ? ធ្វើជាមនុស្សមិនត្រូវបំភ្លេចអតីតកាលរបស់ខ្លួនទេ ព្រោះសុទ្ធតែជារឿងរ៉ាវដែលជីវិតយើងបានឆ្លងកាត់។ ខ្ញុំសូមគាំទ្រ និងនៅតែបន្តគាំទ្រអ្នកជួយរំដោះខ្ញុំឱ្យរួចផុតពីរបបប្រល័យពូជសាសន៍។ ខ្ញុំនៅតែស្រឡាញ់ថ្ងៃ ៧ មករា របស់ខ្ញុំរហូតដល់ខ្ញុំស្លាប់។



*❋ លោកស្រី **សាត់ ចន្ធី** អាយុ ៤៩ឆ្នាំ ជនជាតិគួយ រស់នៅភូមិកេស ឃុំកាំងចាម ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង បានបញ្ជាក់ថា: "ខ្ញុំគឺជាជនជាតិភាគតិចក្នុងចំណោមបងប្អូនជនជាតិគ្រឹង កាវ៉ែត កាចក់ ទំពួន ព្រៅ ព្នង គួយ ខិក លន់ និងឡាវ ដែលរស់នៅភូមិក្បែរគ្នាដែលពីមុនៗមកមិនចេះលក់ដូរអ្វីទេ ធ្វើតែស្រែចម្ការ ធ្វើស្រាពាង ស្ពាយកំផា ដើរបោចវល្លិ៍ បេះផ្លែឈើ និងបរបាញ់សត្វចិញ្ចឹមជីវិត។ ប៉ុន្តែបច្ចុប្បន្ន បងប្អូនជនជាតិយើងខ្ញុំចេះកែច្នៃមុខរបររបស់ខ្លួនចេះច្នៃប្រឌិត ផលិតផលចំណីអាហាររកប្រាក់ចំណូលដោះស្រាយជីវភាពបានធូរធារ។ មិនត្រឹមតែប៉ុណ្ណោះ ភូមិ-ឃុំក៏មានការអភិវឌ្ឍ មានផ្លូវ មានសាលារៀន មានមណ្ឌលសុខភាព បងប្អូនជនជាតិសង់ផ្ទះបានធំៗ មានស្រែ ចម្ការគ្រប់គ្នា។ តើយើងទៅរកឯណាឱ្យហួសនេះទៅទៀត។ ខ្ញុំស្រឡាញ់គណបក្សប្រជាជន។ ក្នុងថ្ងៃបុណ្យ ៧ មករានេះ ខ្ញុំសូមជូនពរឱ្យសម្ដេចទាំងបីមានសុខភាពល្អបរិបូរណ៍ដើម្បីដឹកនាំប្រទេសជាតិទៅមុខទៀត"។*



❋ លោកស្រី **គីម យឹម** អាយុ ៥៨ ឆ្នាំ រស់នៅសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បាននិយាយថា: "ខ្ញុំពិតជាមានសេចក្ដីសប្បាយរីករាយណាស់ ក្នុងពេលដែលយើងនាំគ្នាធ្វើបុណ្យរំឭកខួបថ្ងៃរំដោះជាតិ ៧ មករា នាពេលនេះ។ ជាពិសេសទៅទៀតនោះ ក្នុងថ្ងៃបោះឆ្នោតកន្លងមក គណបក្សប្រជាជនកម្ពុជាបានទទួលជ័យជម្នះដើម្បីដឹកនាំប្រទេសបន្តទៀតធ្វើឱ្យខ្ញុំកាន់តែរំភើបរីករាយមែនទែន។ ប្រទេសយើងមានភ័ព្វសំណាង ដោយបានសម្ដេចតេជោ **ហ៊ុន សែន** ធ្វើជានាយករដ្ឋមន្ត្រីដឹកនាំប្រទេសឱ្យមានសុខសន្តិភាព ប្រជាជនមានជីវភាពធូរធារ។ អតីតកាលរបស់យើងជូរចត់ណាស់។ ប៉ុន្តែ ៣៥ ឆ្នាំកន្លងមកនេះ យើងបានស្ដារប្រទេសជាតិឱ្យប្រែមុខមាត់ថ្មី ។ នេះគឺដោយសារតែគណបក្សប្រជាជនកម្ពុជាដឹកនាំប្រទេសមានចក្ខុវិស័យវែងឆ្ងាយ មានប្រជាជនគាំទ្រយ៉ាងច្រើន។ មានមនុស្សខ្លះចង់បំផ្លាញសមិទ្ធ-ផលរបស់យើង ប៉ុន្តែគេមិនអាចធ្វើបានទេ ទោះជាមហិច្ឆតារបស់គេធំធេងយ៉ាងណាក៏ដោយ ពីព្រោះសមិទ្ធផលទាំងអស់នេះកើតឡើងដោយស្នាដៃរបស់ប្រជាជន ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា"។



*❋ យុវជន **សុខ ពិសិដ្ឋ** អាយុ ២១ ឆ្នាំ បម្រើការងារនៅធនាគារ មានទីលំនៅនៅសង្កាត់លេខ ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនថា "ខ្ញុំជាយុវជនម្នាក់មិនខុសពីយុវជនដទៃទៀតទេ ពិតជាមានមោទនភាពណាស់ ដែលឃើញប្រទេសជាតិមានការរីកចម្រើនយ៉ាងលឿនបែបនេះ បើប្រៀបធៀបទៅនឹងអ្វីដែលកើតមានក្រោយរំដោះភ្លាម គឺខុសគ្នាដូចមេឃនឹងដី។ ខ្ញុំបានសិក្សារៀនសូត្រស្រាវជ្រាវដឹងយ៉ាងច្បាស់លាស់អំពីប្រវត្តិសាស្ត្រចុងក្រោយរបស់ប្រទេសកម្ពុជា។ ប្រទេសយើងពិតជារងគ្រោះធ្ងន់ធ្ងរមែនទែន សង្គ្រាមផង ប្រល័យពូជសាសន៍ផង ប្រជាជនបែកបាក់គ្នាជាបក្ខជាពួក ទម្រាំតែបង្រួបបង្រួមបានជាធ្លុងឯកភាពជាតិដូចបច្ចុប្បន្ននេះគឺពិតជាលំបាកណាស់ ។ បើគ្មានគណបក្សប្រជាជនកម្ពុជាទេ គ្មាននយោបាយ ឈ្នះ ឈ្នះ របស់សម្ដេចតេជោ **សែន** ទេ ម្ល៉េះសមសង្គមយើងនៅតែប្រេះឆា នៅតែបែកបាក់គ្មានទីបញ្ចប់ឡើយ។ ដោយហេតុនេះទើបខ្ញុំគាំទ្រគណបក្សប្រជាជនកម្ពុជា គាំទ្រសម្ដេចតេជោ **ហ៊ុន សែន** ជារៀងរហូត"។*



*កញ្ញា **ហឿងឃុនណារី** អាយុ ១៧ឆ្នាំរស់នៅស្រុកថាឡាបរិវ៉ាត់ខេត្តស្ទឹងត្រែងរៀនថ្នាក់ទី១០វិទ្យាល័យព្រះគោ បានឱ្យដឹងថា "នាងខ្ញុំជាជនជាតិភាគតិចក្ទួយកំពុងរៀនសូត្រក្រេបយកចំណេះដឹង ហើយបងប្អូនជនជាតិដទៃយ៉ាងច្រើនលើសលប់នាំគ្នាភ្ញាក់រឭកចូលរៀនគ្រប់ៗគ្នា ។ ពីដើមឡើយបងប្អូនជនជាតិមិនថាចាស់ក្មេងទេ មិនសូវយល់ពីអ្វីឡើយ ការរស់នៅបានត្រឹមតែមួយឆ្អែតមិនចង់មានមិនចង់បាន រកស៊ីដោះស្រាយឱ្យគ្រាន់តែគ្រប់ប៉ុណ្ណោះ ។ ប៉ុន្តែមកដល់ឥឡូវនេះ មិនថាចាស់ មិនថាក្មេង ក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** ដែលលោកតែងតែយកចិត្តទុកដាក់ដល់ប្រជាជនបានធ្វើឱ្យបងប្អូនជនជាតិរស់នៅតំបន់ដាច់ស្រយាល បញ្ជូនកូនបញ្ជូនចៅទៅរៀនសូត្រគ្រប់គ្នា ដើម្បីក្លាយជាធនធានមនុស្សដ៏សំខាន់អាចប្រកបរបររកស៊ីចិញ្ចឹមជីវិតបានធូរធារ ។ យើងឈឺនាំគ្នាទៅមន្ទីរពេទ្យ មិនបែរបន់បញ្ជាន់អារក្សទៀតទេ ការដាំដុះធ្វើស្រែចម្ការក៏មិនធ្វើជាលក្ខណៈពនេចរទៀតដែរ គឺធ្វើតាមបច្ចេកទេសកសិកម្មត្រឹមត្រូវ ផលបានមកក៏ច្រើនអាចលក់ដូរបង្កើនជីវភាពរស់នៅល្អប្រសើរ ។ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា បានធ្វើឱ្យជនជាតិដើមភាគតិចប៉ែកព្រៃសានរបស់នាងខ្ញុំប្រែមុខមាត់ថ្មីក្នុងសម័យតេជោ" ។*



លោក **សោម សមសក្តិ** សមាជិកសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តសៀមរាបបានឱ្យដឹងថា "មានសមិទ្ធផលលេចធ្លោជាច្រើនគ្រប់ទីកន្លែងបានកកើតជារូបរាងឡើងដោយស្នាដៃរបស់ប្រជាជនក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា ។ យើងត្រូវទទួលស្គាល់ការពិតនេះ ។ ក្នុងនាមជាយុវជនម្នាក់ក៏ដូចជាយុវជនដទៃទៀតដែរ ដែលសុទ្ធតែជាមនុស្សជំនាន់ ថ្មី ជាទំពាំងស្នងឫស្សី យើងត្រូវធ្វើការបែងចែកឱ្យបានច្បាស់អ្វីដែលជាការពិត អ្វីដែលជាការបោកប្រាស ។ ជនអគតិមួយចំនួនកំពុងតែបោកប្រាសប្រជាជន កំពុងកែកាឡៃប្រវត្តិសាស្ត្រ ។ បើយើងចាញ់បោកការឃោសនារបស់ពួកនេះ មិនមែនត្រឹមតែធ្វើឱ្យវាសនារបស់យើងជួបនូវភាពអាក្រក់នោះទេ ប៉ុន្តែគឺប្រទេសយើងទាំងមូលប្រាកដជាធ្លាក់ទៅក្នុងហាយនភាពម្តងទៀតជាមិនខាន ។ ដូចជាមិនចាំបាច់មានអ្វីដែលត្រូវពិចារណាច្រើននោះទេ ។ អ្វីៗជាក់ស្តែងយើងបានឃើញនឹងភ្នែកហើយ ។ គ្មានគណបក្សប្រជាជនដឹកនាំប្រទេសជាតិនឹងជួបមហន្តរាយ ពីព្រោះថា សូម្បីតែថ្ងៃ ៧ មករាជាទិវារំដោះជាតិក៏ពួកគេចេះបំភ្លៃទៅកើតដែរ ? នេះជារឿងដែលប្រជាជនកម្ពុជាទូទាំងប្រទេស និងប្រជាជនទូទាំងពិភពលោកបានឮបានដឹងគ្រប់ៗគ្នា ចុះទម្រាំរឿងលាក់កំបាំងដទៃទៀតតើវាគ្រោះថ្នាក់ប៉ុណ្ណាទៅ ?" ។



*កញ្ញា **លាក់ សូម៉ាឡា** សមាជិកាអចិន្ត្រៃយ៍សហភាពសហព័ន្ធយុវជនកម្ពុជាខេត្តសៀមរាបបានបង្ហាញពីចំណាប់អារម្មណ៍ថា :"ខ្ញុំមានការពេញចិត្តចំពោះការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ព្រោះជាគណបក្សតែមួយគត់ដែលបានធ្វើឱ្យប្រទេសមានការរីកចម្រើនលើគ្រប់វិស័យ មានសុខសន្តិភាព សង្គមប្រកបដោយលក្ខណៈប្រជាធិបតេយ្យសេរីភាពមានបរិបូរណ៍ ។ យុវជនយើងបានសិក្សារៀនសូត្រក្រេបយកចំណេះដឹងគ្រប់គ្នា ។ កូនចៅប្រជាជនមិនថានៅទីក្រុង មិនថានៅទីជនបទ សុទ្ធតែបានចូលរៀនទាំងអស់គ្នា ។ មានគណបក្សប្រជាជនដឹកនាំ គឺពិតជាមានក្តីសង្ឃឹម ។ ជាយុវជនម្នាក់ ខ្ញុំត្រូវតែផ្តល់យុត្តិធម៌ជូនគណបក្សប្រជាជនកម្ពុជា និងផ្តល់សច្ចធម៌ជូនគណបក្សប្រជាជនកម្ពុជា" ។*



លោក **អូន កក្កដា** អាយុ ៣០ ឆ្នាំ ជាមន្ត្រីបម្រើការងារនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានប្រសាសន៍ថា : ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះគណបក្សប្រជាជនកម្ពុជាដែលបានរំដោះគ្រួសារខ្ញុំ ក៏ដូចជាប្រជាជនទូទាំងប្រទេសឱ្យរស់រានសារមានជីវិតជាថ្មីពីរបបប្រល័យពូជសាសន៍ ។ ខ្ញុំចាត់ទុកគណបក្សប្រជាជនកម្ពុជាគឺជាជីវិតខ្ញុំ និងប្រជាជនទូទាំងប្រទេស ។ ខ្ញុំកត់សម្គាល់ឃើញថា តាមរយៈការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ប្រមុខដឹកនាំទាំងបី ប្រទេសជាតិមានការរីចម្រើនាលីគ្រប់វស័យ មានសាលារៀនមាននៅគ្រប់ឃុំ-ស្រុក ខេត្ត ទូទាំងប្រទេស បង្កលក្ខណៈងាយស្រួលឱ្យកូនចៅប្រជាជនបានចូលរៀនគ្រប់ៗគ្នា ។



*កញ្ញា **លឿង ស្រស់** អាយុ ២២ ឆ្នាំ រស់នៅខណ្ឌចំការមន រាជធានីភ្នំពេញ ជានិស្សិតវិទ្យាស្ថានវ៉ាន់ដាមានចំណាប់អារម្មណ៍ថា : តាមការរៀបរាប់ពីឪពុកម្តាយខ្ញុំ កាលក្នុងរបបអាវខ្មៅ រូបគាត់ ក៏ដូចប្រជាជនទាំងអស់ រស់នៅលំបាកវេទនា ខ្លោចផ្សារ មិនអាចរកពាក្យអ្វីមកបរិយាយបានឡើយ ។ ប៉ុន្តែ ចាប់តាំងពីក្រោយថ្ងៃជ័យជំនះ ៧ មករា ១៩៧៩ រហូតមកដល់បច្ចុប្បន្ន គណបក្សប្រជាជនកម្ពុជាដែលដឹកនាំដោយម្តេចទាំងបី មិនត្រឹមតែជួយសង្គ្រោះអាយុជីវិតប្រជាជនឱ្យរស់ឡើងវិញប៉ុណ្ណោះទេ ថែមទាំងនធ្វើឱ្យមានការអភិវឌ្ឍនៅទូទាំងប្រទេស ខ្ញុំមានឱកាសបានសិក្សារៀនសូត្រ មានចំណេះដឹង អាចនឹងបានធ្វើការទទួលប្រាក់កម្រៃចិញ្ចឹមជីវិតល្អប្រសើរ ។ ខ្ញុំមានជំនឿថា គណបក្សប្រជាជនកម្ពុជាបន្តដឹកនាំ នោះប្រទេសជាតិនឹងបន្តអភិវឌ្ឍន៍ សំបូររុងរឿងជារៀងរហូត ។/*

## បទចម្រៀងអបអរសាទរខួបទី ៣៥ ទិវាជ័យជម្នះ ៧ មករា

*បទទី ១*

ជយោ ប្រាំពីរមករា    ជយោ ជយោ សន្តិភាព
ជយោ ប្រាំពីរមករា    ជីវភាពប្រជារុងរឿង ។

*បទទី ២*

ព្រាបអើយព្រាបសបរិសុទ្ធ    សុភាពបំផុតលើលោកា
មនុស្សក្នុងពិភពសែនស្នេហា    ចិត្តយើងប្រាថ្នាឱបជាប់ហឫទ័យ ។
ព្រោះតែចង់បានសន្តិភាព    ព្រាបអើយនៅឆ្នាំ៩៨
នយោបាយឈ្នះ ឈ្នះ សម្ដេចទាំងបី    សម្រេចជោគជ័យបញ្ចប់ទុក្ខសោក ។

*បទទី ៣*

មាតាមករាមាតាតែមួយ    លោកម្ដាយនេះហើយផ្ដល់កំណើតយើង
រក្សាព្រលឹងខ្មែរថែជាតិបានថ្កើង    កម្ពុជាឈានឡើងព្រោះមានសន្តិភាព ។
មាតាមករាចារជាប់ក្នុងចិត្ត    ចារក្នុងជីវិតកូនខ្មែររៀងរៀប
គុណលោកធ្ងន់ណាស់អ្នកម្ដាយសន្តិភាព    គុណគ្មានអ្វីប្រៀបសម្រាប់ប្រជាជន ។
មាតាមករាមេត្តាករុណា    ឧបិមុទិតាព្រហ្មវិហារទាំងបួន
បម្រើប្រយោជន៍ជូនជាតិប្រជាជន    អ្នកម្ដាយមានបុណ្យគុណលោកមិនបាត់ ។
គុណធមិឧត្តមប្រាំពីរមករា    ជ្រោងជាតិសាសនាព្រះមហាក្សត្រ
សាមសិបប្រាំឆ្នាំខេត្តក្រុងជនបទ    បានអភិវឌ្ឍ រស់គ្រប់វិស័យ ។

*ពោល*

គោរពជូនពរ    សម្ដេចទាំងបី    ពោធិសាលចក្រី    តេជោតេជះ
ខួបសាមសិបប្រាំ    ជួយបន្តឈ្នះ    កម្ពុជារីករះ    ត្រចះលើលោក ។

*បទទី ៤*

ខួបសាមសិបប្រាំ    ខួបសាមសិបប្រាំ    ដែលខ្មែរចងចាំ    សាមប្រាំប្រាកដ
ប្រាំពីរមករា    ចារជាប្រវត្តិ    សាមប្រាំចារកត់    កំណត់កំណើត ។
ខួបសាមសិបប្រាំ    ប្រាំពីរមករា    ឱអង្គទេវតា    ឆព័នឆោមឆើត
ប្រាំពីរមករា    ស្ដារយោងកំណើត    មាតាបង្កើត    កំណើតទីពីរ ។
ខួបសាមសិបប្រាំ    ប្រាំពីរមករា    ពរពីទេវតា    រោយបាចផ្កាភ្ញី
ជាពរជ្រះថ្លា    បាចផ្កាប្រាំពីរ    សព្វគ្រប់ទិសទី    ទូទាំងរដ្ឋា ។
ខួបសាមសិបប្រាំ    ចំណាំផ្លូវដើរ    បន្តដំណើរ    ក្រោមម្លប់ទេវតា
ប្រមុខដឹកនាំ    សម្ដេចអគ្គមហា    ឈ្លាសវៃអស្ចារ្យ    ស្ដារជាតិរុងរឿង ។

**ជយោ ៧ មករា**
**ជយោ សន្តិភាព**
**ជយោ គណបក្សប្រជាជនកម្ពុជា**

## កត្តិកនឹកស្រែ



*( បទពាក្យ ៧ )*

- ក្រោយទឹកជំនន់ជន់លង់លិច    គ្រោះមួយពព្រិចរំលងទៅ
  វស្សាឆ្លងផុតភាពអាស្រូវ    ដល់មកឥឡូវត្រូវបានស្បៀយ ។
- ហេមន្តរដូវស្រូវពេញស្រែ    ជំនោរដើមខែបក់ប៉ើយៗ
  បងបានសន្យាអូនរួចហើយ    ឆ្នាំថ្មីបង្កើយបងចូលស្ដី ។
- យប់បងស្រមៃថ្ងៃបងនឹក    ទន្ទឹងល្ងាចព្រឹកព្រោះស្នេហ៍ស្រី
  នឹកក្រមាផ្ទក់ដក់ដូងខ្ចី    អំបុកស្រូវថ្មីស្រីផ្ញើបង ។
- បងឃ្វាលក្របីស្រីដេញចាប    ក្បែរថ្នាលសំណាបស្រស់ទួនល្អង
  អូនបក់បោយដៃហៅប្រុសបង    ជ្រកម្លប់ផ្ដោះផ្ដងផ្សងវាសនា ។
- ស្រមៃថ្ងៃមុខជាតិរុងរឿង    ជីវភាពយើងថ្កើងគ្រប់គ្រួសារ
  យើងរួមកសាងគ្រប់ចលនា    ចាប់ដៃរៀបការស្ម័គ្រស្មោះសរ ។
- ថ្ងៃបាក់រសៀលវាលកន្ទ្រើយ    ខ្យល់បក់រហើយពីឧត្តរ
  ស្រណោះកាលជួបថ្លៃបវរ    ក្រោមម្លប់ស្រម៉ទួលសង្កែ ។
- បងកាយអំពកយកទឹកថ្មី    ជីកអន្លង់បីយកត្រីស្រែ
  កំភ្លាញក្រាញ់ក្រឹមក្ដាមស្រងែ    កត្តិកចុងខែស្រូវស្រែទុំ ។
- បងជិះក្របីស្ពាត់រកពៅ    តាមស្រែជម្រៅក្បែរត្នោតជ្រុំ
  យកត្រីអន្លង់ផ្ញើស្រីម៉ុម    កក្កូរស្លឹកម្រំលាយត្នោតខ្ចី ។
- កត្តិកនឹកស្នេហ៍ចង់ថ្នាក់ថ្នម    នឹកដល់ក្លិនម្អមជាប់ដៃស្រី
  នឹកគ្រាអូនជិះរទេះសាឡី    កឋិនវត្តថ្មីអូនទៅនឹងបង ។/

**ដោយ សុខ សុធន**

បោះពុម្ពដោយរោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

## អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៥១

| | | | | |
|---|---|---|---|---|
| ១- | ឯ.ឧ | **កែ គឹមយ៉ាន** | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ២- | ឯ.ឧ | **ចម ប្រសិទ្ធ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោកជំទាវ | ២០០ ដុល្លារ |
| ៣- | ឯ.ឧ | **មិន ឃិន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ឆួន** | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | **ត្រាំ អ៊ីវតឹក** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | **ថោង ខុន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | **ហ៊ុន ណេង** | តំណាងរាស្ត្រមណ្ឌលកំពង់ចាម | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | **ជៀង អំ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | **ស្បោង សារ៉ាត** | ប្រធានគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | **ខូយ សុខា** | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តពោធិ៍សាត់ | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | **អ៊ូស្ការ ហាស្សាន់** | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | **សរ ចាំរ៉ុង** | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | **ឆាំ សុជាតិវង្ស** | អនុប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | **ម៉ម ប៊ុននាង** | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | **ប្រាក់ ចំរើន** | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | **យូ តិរម្យ** | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់ | ១០០ ដុល្លារ |
| ១៧- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | ៥០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | ៥០ ដុល្លារ |
| ២១- | ឯ.ឧ | **លឹម គានហោ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ២០០.០០០ ៛ |
| ២២- | ឯ.ឧ | **ឃឹម សារិទ្ធ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៥០ដុល្លារ |
| ២៣- | ឯ.ឧ | **ម៉ម ប៊ុនហេង** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៤- | ឯ.ឧ | **ថា យ៉ាវ** | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ២៥- | ឯ.ឧ | **យូ ស៊ុនឡុង** | រដ្ឋមន្ត្រីប្រតិភូអមសម្ដេចនាយករដ្ឋមន្ត្រី | ៥០ ដុល្លារ |
| ២៦- | ឯ.ឧ | **ជូ យ៉ែនស៊ុម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៧- | ឯ.ឧ | **អ៊ុក ប្រាជ្ញា** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ២០០.០០០ ៛ |
| ២៨- | ឯ.ឧ | **ប៉ាវ ហាមផាន** | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តរតនគិរី | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | **សូ ជុងហួរ** | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | **ចាយ បូរិន្ទ** | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ | **នរៈ រតនៈវឌ្ឍនោ** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣២- | ឯ.ឧ | **ឃួន រ៉ានីន** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣៣- | ឯ.ឧ | **ប៊ុន លឹមហេង** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៣៤- | ឯ.ឧ | **សេង ទៀង** | ជំនួយការផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ២០០.០០០៛ |
| ៣៥- | ឧកញ៉ា | **ម៉ក់ គឹមហុង** | ប្រធានអគ្គនាយកចំការកៅស៊ូជប់ | ២០០.០០០៛ |
| ៣៦- | ឯ.ឧ | **គឹម ណាំង** | | ១០០.០០០៛ |
| ៣៧- | ឯ.ឧ | **ម៉ៅ ប៊ុនណារិន** | សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា | ១០០.០០០៛ |
| ៣៨- | ឯ.ឧ | **ម៉ែន ស៊ុំផាន់** | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៣៩- | ឯ.ឧ | **សុន គន្ធរ** | រដ្ឋមន្ត្រីប្រតិភូអមសម្ដេចនាយករដ្ឋមន្ត្រី | ១០០.០០០៛ |
| ៤០- | ឯ.ឧ | **ប៉ាន ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៤១- | លោកជំទាវ | **ស៊ឹង ស៊ុំយុត** | | ១០០.០០០៛ |
| ៤២- | ឯ.ឧ | **គឹម ធា** | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៣- | ឯ.ឧ | **គាំម កុសល** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៤- | ឯ.ឧ | **ប៊ិច សុវណ្ណ** | | ១០០.០០០៛ |
| ៤៥- | ឯ.ឧបណ្ឌិត | **មាស ប៉ូ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៤៦- | លោកជំទាវ | **និត្យ ច័ន្ទតារីន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៧- | ឯ.ឧ | **អ៊ុំ វណ្ណា** | | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | **ឆា ច័ន្ទលីដា** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៩- | ឯ.ឧ | **ឃិន សុង** | ទីប្រឹក្សាឯកឧត្ដម **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៥០- | ឯ.ឧ | **ម៉ែន វិបុល** | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០.០០០៛ |
| ៥១- | ឯ.ឧ | **អោម ចន** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៥២- | ឯ.ឧ | **ជួន ថេរ៉ាវ៉ាត** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី ហេង សំរិន | ១០០.០០០៛ |
| ៥៣- | ឯ.ឧ | **ម៉ៅ ឡាំង** | ទីប្រឹក្សាឯកឧត្ដម **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៥៤- | ឯ.ឧ | **ឆន់ ចន** | ទីប្រឹក្សាឯ.ឧរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០.០០០៛ |
| ៥៥- | លោក | **ឆាយ ឫទ្ធិសែន** | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងសុរិយោដីរាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥៦- | លោក | **សាំ ពិសិដ្ឋ** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥៧- | ឯ.ឧ | **អ៊ុន ឆាលី** | អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង | ១០០.០០០៛ |
| ៥៨- | លោក | **សុខ វិសាលសម្បត្តិ** | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំព្នៅ១ ស្រុកស៊ីធរកណ្ដាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល ... | ១០០.០០០៛ |
| ៥៩- | លោកជំទាវ | **ស៊ុន សារឿន** | សមាជិករដ្ឋសភាមណ្ឌលក្រចេះ | ៥០.០០០៛ |
| ៦០- | ឯ.ឧ | **សៀង សុខឃុនឌី** | អគ្គនាយកនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០.០០០៛ |
| ៦១- | ឯ.ឧ | **សាយ បូរិន** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ៥០.០០០៛ |

## អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៥១

៦២- ឯ.ឧ **សេង គឹមសាន** ជំនួយការសម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ...... ៥០.០០០៛
៦៣- ឯ.ឧ **ពត ចាន់នី** សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម ...... ៥០.០០០៛
៦៤- ឯ.ឧ **ហេង វណ្ណា** សមាជិកក្រុមការងារគណបក្សចុះជួយខេត្តព្រះសីហនុ ...... ៥០.០០០៛
៦៥- លោកជំទាវ **ស៊ឿ ច័ន្ទថា** ...... ៥០.០០០៛
៦៦- លោក **ហួត ពៅ** ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ...... ៥០.០០០៛
៦៧- កញ្ញា **ផាង និតហ្វើរ** មន្ត្រីក្រសួងទេសចរណ៍ ...... ៥០.០០០៛
៦៨- លោក **ង៉ោ ម៉េងជ្រួន** អភិបាលក្រុងប៉ោយប៉ែត ...... ៥០.០០០៛
៦៩- លោក **អ៊ុំ រាត្រី** ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ...... ៥០.០០០៛
៧០- លោក **កែវ សែន** ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ...... ៥០.០០០៛
៧១- លោក **សួន សុធី** ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ ...... ៥០.០០០៛
៧២- លោក **គឹម ប៊ុណ្ណា** ប្រធានសាខាបក្សមន្ទីរសាធារណៈការ និងដឹកជញ្ជូន ខេត្តសៀមរាប ...... ៥០.០០០៛
៧៣- លោក **គាត ហ៊ុល** ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ ...... ៥០.០០០៛
៧៤- ឯ.ឧ **វេង សាខុន** រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ...... ៤០.០០០៛
៧៥- លោក **លី សារី** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ ...... ៤០.០០០៛
៧៦- លោក **គឹម សុវណ្ណ** ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ ...... ៤០.០០០៛
៧៧- គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម ...... ៤០.០០០៛
៧៨- ឯ.ឧ **ស៊ិន វុទ្ធី** សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក ...... ៣០.០០០៛
៧៩- ឯ.ឧ **ឈុំ វណ្ណារិទ្ធ** អភិបាលរងខេត្តបន្ទាយមានជ័យ ...... ៣០.០០០៛
៨០- លោក **ម៉ៅ សុខលឹម** អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ ...... ៣០.០០០៛
៨១- លោក **ចាន់ ស៊ុំណាត** សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក ...... ៣០.០០០៛
៨២- ឯ.ឧ **ឯម ប៊ុនធឿន** សមាជិកគណៈកម្មាធិការគណបក្ស ក្រសួងធនធានទឹក និងឧតុនិយម...... ៣០.០០០៛
៨៣- លោក **ឃុ ពៅ** អភិបាលស្រុកស្វាយចេក...... ៣០.០០០៛
៨៤- លោក **ទេព វិសិដ្ឋ** អនុប្រធានសាខាពន្ធដារ ខេត្តព្រះសីហនុ ...... ២៥.០០០៛
៨៥- ឯ.ឧ **ចុង ផែត** អភិបាលរងខេត្តបន្ទាយមានជ័យ ...... ២០.០០០៛
៨៦- លោក **ឈរា ប៊ុនរិទ្ធ** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ២០.០០០៛
៨៧- លោក **ម៉ៅ ហាក់** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ២០.០០០៛
៨៨- លោក **លឹម វីរក្សា** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ២០.០០០៛
៨៩- លោក **លឹម ថេង** សមាជិកក្រុមការងារចុះខេត្តកណ្ដាល...... ២០.០០០៛
៩០- លោក **ឃ្លោក សំអាង** សមាជិកក្រុមការងារចុះខេត្តកំពង់ចាម ...... ២០.០០០៛
៩១- លោក **ឡឹក សាន** អនុប្រធានមន្ទីរគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង ...... ២០.០០០៛
៩២- លោក **ជា គឹមលីន** ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា ...... ២០.០០០៛
៩៣- កញ្ញា **កែវ សុជាតា** មន្ត្រីជំនួយការគណៈកម្មការទី ៤ នៃព្រឹទ្ធសភា ...... ២០.០០០៛
៩៤- ឯ.ឧ **ទេស ច័ន្ទគីរី** សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប ...... ២០.០០០៛
៩៥- លោក **ទូច សារ៉េត** ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ ...... ២០.០០០៛
៩៦- លោក **ហុង ជ្រិន** ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង ...... ២០.០០០៛
៩៧- លោក **គួច ចាន់និត្យ** អាជីវករ ខេត្តបន្ទាយមានជ័យ ...... ២០.០០០៛
៩៨- លោក **លី សារុន** មន្ត្រីក្រសួងហិរញ្ញវត្ថុ ...... ១៥.០០០៛
៩៩- លោក **អ៊ុច សាវន** អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ ...... ១៥.០០០៛
១០០- ឯ.ឧ **សេង សុមុនី** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា ...... ១០.០០០៛
១០១- លោក **ម៉ី លីហួត** សមាជិកក្រុមការងារចុះខេត្តកំពង់ចាម ...... ១០.០០០៛
១០២- លោក **ជួន វណ្ណរិទ្ធ** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១០៣- លោក **មឹម ប្ញុស** អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម ...... ១០.០០០៛
១០៤- លោក **សៅ សម្ផស្ស** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១០៥- លោក **ឈុន ប៊ុនឈឿន** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១០៦- លោក **ថេង ប៊ុនតេង** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១០៧- លោក **ស្វាយ សុគន្ធី** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១០៨- លោក **សុខ ចំណាន** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១០៩- លោក **សុខ តារា** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១០- លោក **ស៊ុ ផល្លី** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១១- លោក **ហួត ធាន** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១២- លោក **ទឹម វុដ្ឋារី** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១៣- លោក **ណុប អៀមណី** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១៤- លោក **សារុន សម្បត្តិ** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១៥- លោក **សរ វិចិត្រ** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១៦- លោក **ទូច សុផល្លា** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១៧- លោក **ជុំ ឧត្តរ៉ា** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១៨- លោក **ឈ្លាង ប៊ុយ** សមាជិកក្រុមការងារចុះខេត្តកណ្ដាល ...... ១០.០០០៛
១១៩- លោក **យស់ ធុល** សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង ...... ១០.០០០៛
១២០- លោក **ឡុង ចន្ធា** សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង ...... ១០.០០០៛
១២១- លោក **ម៉ុ វុទ្ធា** មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង ...... ១០.០០០៛
១២២- លោក **ឡាច តីរ៉ាត់** សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង ...... ១០.០០០៛
១២៣- លោក **ឈាង សុវណ្ណារ៉ា** មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង ...... ១០.០០០៛





មិទ្ទិញអបអរខួបអនុស្សាវរីយ៍
លើកទី ៣៥ ថ្ងៃបង្កើតរណសិរ្ស
សាមគ្គីសង្គ្រោះជាតិកម្ពុជា
៧



កម្ពុជា-ជប៉ុន បង្កើន
កិច្ចសហប្រតិបត្តិការ.......
❖ កិច្ចប្រជុំកំពូលរំឭកខួប
អនុស្សាវរីយ៍លើកទី ៤០ ......
និងកិច្ចប្រជុំកំពូលមេគង្គ-ជប៉ុន លើកទី ៤
៩



សម្តេចតេជោ :
❖គ្មានការបោះឆ្នោតឡើងវិញទេ
❖រួមគ្នាការពារការពុកផុយនៃប្រាសាទ
❖ផ្តល់ឱកាសដល់ជនពិការដើម្បីសង្គម
មួយសម្រាប់យើងទាំងអស់គ្នា
១២



បុណ្យសមុទ្រនៅខេត្តកែប
និងកិច្ចប្រជុំអន្តរជាតិនៅ
រមណីយដ្ឋានឋានសួគ៌បូកគោ
បង្ហាញនូវជំហានដ៏រឹងមាំ
នៃវិស័យទេសចរណ៍កម្ពុជា
១៥

**និពន្ធនាយក :**
**លោក តាក ស៊ុនអ៊ី**
**គណៈកម្មការនិពន្ធ**
១. លោក ខៀវ ណារី
២. លោក អ៊ឹម សុន្ទរៈ
៣. លោក វង្ស សារ៉ុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន
**លេខានិពន្ធ**
១. លោក ជុំ សម្បត្តិ
២. លោក ម៉ក់ ឈិន
**អ្នកបកប្រែភាសា**
១. លោកស្រី ម៉ែន នារីសោភ័គ
**អ្នកថតរូប**
១. លោក សុផាត វីរៈមុនី
**វិចិត្រករ**
១. លោក ធា សារ៉ុធ

អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥
**Address :**
**No 203 Preah**
**Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**

## ក្របមុខ

ស្មារតី ២ ធ្នូ និង
ជ័យជម្នះ ៧ មករា
ស្ថិតនៅជានិច្ចក្នុងបេះដូង
របស់ប្រជាជនកម្ពុជា

# មាតិកា
# Contents

*វិចារណកថា : ពូនជ្រំស្មារតី៧មករា បន្តអនុវត្តកំណែទម្រង់ដោយដាច់ខាត......................................* ៣
*Editorial : Further Growing 7 January Spirit, Resolutely Implementing Reforms...................*
➪ ធាតុពិតនៃល្បិចកលប្រទូសរ៉ាយរបស់គណបក្សប្រឆាំង ............................................... ៥

➪ សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៩
➪ គោលដៅយុទ្ធសាស្ត្រ ៤ និងវិស័យអាទិភាព ៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣............ ២០
➪ លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច.................................................................... ២១
➪ ឆ្នាំ ២០១៣ ការវិនិយោគរបស់ជប៉ុននៅកម្ពុជាកើនឡើងគួរឱ្យកត់សម្គាល់.............................. ២២
➪ ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវលំជនបទដោយគ្រោះទឹកជំនន់ ឆ្នាំ ២០១៣ មានទំហំធំ......... ២៤
➪ វប្បធម៌ : ចម្រៀង និងតន្ត្រីប្រីន ឬប្រ៊ីន.................................................................. ២៦
➪ បទសម្ភាសន៍ : ស្មារតី ៧ មករា ស្ថិតនៅជានិច្ចក្នុងបេះដូងរបស់ប្រជាជនកម្ពុជា ...................... ២៨
➪ បទចម្រៀង : អបអរសាទរខួបទី ៣៥ ទិវាជ័យជម្នះ ៧ មករា..... កំណាព្យ .....កត្តិកនឹកស្រែ..... ៣១

# ប្រជាជន

THE PRACHEACHUN MAGAZINE















ឆ្នាំទី១៣ លេខ ១៤១ ខែធ្នូ ឆ្នាំ ២០១៣





























ទិដ្ឋភាពផ្សេងៗក្នុងពិធីបុណ្យសមុទ្រនៅឆ្នេរសមុទ្រកែប និងរមណីយដ្ឋានឋានសួគ៌បូកគោ
(ថ្ងៃទី ៥-៨ ខែធ្នូ ឆ្នាំ ២០១៣)

ចែកជូនដោយឥតគិតថ្លៃ